ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ម៉ូឌុលទី ៣ សមត្ថភាពធ្វើការងារ



**កម្មវិធីសិក្សា Gap Inc. P.A.C.E.**

**សម្រាប់សិស្សពេញវ័យ (អាយុ១៤ ដល់ ១៧ឆ្នាំ)**

គាំទ្រដោយក្រុមហ៊ុន Gap Inc.

រៀបចំដោយ អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប)

# កម្មវិធីសិក្សា Gap Inc. P.A.C.E.

# ការដាក់ទុនលើជំនាញថ្មីដើម្បីអនាគត

Personal Advancement and Career Enhancement

## កម្មវិធីសម្រាប់ក្មេងស្រីពេញវ័យ
## (អាយុ១៤ ដល់ ១៧ឆ្នាំ)

 សៀវភៅណែនាំសម្រាប់គ្រូបង្រៀន

# មាតិកា

*សេចក្តីណែនាំស្តីពីការប្រើប្រាស់សៀវភៅ* ........................................................ *i*

*ផ្នែក ៖ សមត្ថភាពធ្វើការងារ* ........................................................................ *1*

*ម៉ូឌុលទី៣ ៖ សមត្ថភាពធ្វើការងារ / ភាពវាងវៃ* ................................................ *2*

**ជំពូកទី១ ៖ យេនឌ័រ និងបំណងប្រាថ្នា** ........................................................ 6

**មេរៀនទី១ ៖ តើការងារបង្កើតឱ្យមានតួនាទីយេនឌ័រដូចម្តេច?** ........................................ 7

**មេរៀនទី២ ៖ ស្ត្រី និងការងារ** ........................................................................ 19

**ជំពូកទី២ ៖ ការរៀបចំផែនទីស្តីពីបំណងប្រាថ្នា និងការកំណត់គោលដៅ** ............. 28

**មេរៀនទី៣ ៖ ខ្ញុំប្រាថ្នាចង់បាន** ........................................................................ 29

**មេរៀនទី៤ ៖ គោលដៅ និងការកំណត់គោលដៅ** ................................................ 35

**ជំពូកទី៣ ៖ ជំនាញ (បំណិន) ដែលប្អូនចង់បាន** ................................................ 50

**មេរៀនទី៥ ៖ តើ កញ្ញា គួរធ្វើអ្វីខ្លះ?** ........................................................................ 52

**មេរៀនទី៦ ៖ ការគ្រប់គ្រងពេលវេលា** ........................................................................ 62

**មេរៀនទី៧ ៖ ការគ្រប់គ្រងអារម្មណ៍តានតឹង** ................................................................ 67

**មេរៀនទី៨ ៖ នរណាជាអ្នកដឹកនាំ?** ........................................................................ 81

*ឧបសម្ព័ន្ធទី១៖ សន្លឹកកិច្ចការសិស្ស* ........................................................ *88*

*ឧបសម្ព័ន្ធទី២៖ ទម្រង់វាយតម្លៃសិស្សមុន និងក្រោយពេលបង្រៀន* ........... *107*

# សេចក្តីណែនាំស្តីពីការប្រើប្រាស់សៀវភៅនេះ

## ១. សេចក្តីផ្តើម

សៀវភៅម៉ូឌុលទី៣សម្រាប់ក្មេងស្រីពេញវ័យ(អាយុពី១៤-១៧ឆ្នាំ)មានគោលបំណងធ្វើឱ្យសិស្សមានលទ្ធភាពធ្វើឱ្យដំណើរការផ្លាស់ប្តូរនានាកាន់តែមានលទ្ធភាពថែមទៀត ព្រមទាំងផ្តល់ភាពអង់អាចដល់ពួកគេដើម្បីឱ្យពួកគេមានទំនុកចិត្តថែមទៀតក្នុងការបំពេញគន្លងអាជីពនាពេលអនាគតរបស់ខ្លួន។ ម៉ូឌុលនេះមាន៣ជំពូកគឺ ៖ ១) សមត្ថភាពធ្វើការងារ ឬភាពវាងវៃ ២) ការរៀបចំផែនទីស្តីពីបំណងប្រាថ្នា និងការកំណត់គោលដៅ និង ៣) ជំនាញ(បំណិន)ដែលសិស្សចង់បានដោយជំពូកនីមួយៗមានមេរៀនដាច់ៗដោយឡែកពីគ្នាចំនួន៨មេរៀន។ ជំពូកនីមួយៗមានកំណត់ពីលទ្ធផលសិក្សាដែលរំពឹងទុកសម្រាប់សិស្សរៀងៗខ្លួន។

ជំពូកស្តីពីយេនឌ័រ និងបំណងប្រាថ្នាជួយសិស្សឱ្យយល់កាន់តែទូលំទូលាយពីរបៀបដែលយេនឌ័រមានឥទ្ធិពលលើអនាគតរបស់គេទាក់ទងនឹងការងារវិជ្ជាជីវៈ និងអាជីពដែលជាបំណងប្រាថ្នានៃអាជីពរបស់ពួកគេ។ ជំពូកស្តីពីការរៀបចំផែនទីស្តីពីបំណងប្រាថ្នា និងការកំណត់គោលដៅធ្វើឱ្យសិស្សយល់ពីរបៀបកំណត់គោលដៅដែលមានលក្ខណៈជាក់លាក់ពិតប្រាកដ និងអាចសម្រេចបាន ព្រមទាំងរបៀបដែលពួកគេអាចគិត និងធ្វើការឆ្ពោះទៅរកការសម្រេចបានគោលដៅរបស់ខ្លួន។ ចំពោះជំពូកស្តីពី ជំនាញ(បំណិន)ដែលសិស្សចង់បានផ្តល់ឱកាសឱ្យសិស្សរៀនសូត្រពីជំនាញដែលទាក់ទងនានាតាមវិធីមួយដែលធ្វើឱ្យពួកគេមានអារម្មណ៍កាន់តែប្រាកដលើខ្លួនឯង និងបំណងប្រាថា ពេលអនាគតរបស់ពួកគេ ព្រមទាំងមានលទ្ធភាពធ្វើការងារជាប់ជាប្រចាំឆ្ពោះទៅរកការសម្រេចបានគោលដៅនាពេលអនាគតរបស់ខ្លួន។

## ២. វត្ថុបំណងរបស់ម៉ូឌុល

នៅចុងបញ្ចប់នៃម៉ូឌុលនេះសិស្ស ៖

- មានចក្ខុវិស័យច្បាស់លាស់ពីគោលដៅរបស់ពួកគេ និងមានលទ្ធភាពរៀបចំផែនការច្បាស់លាស់មួយសម្រាប់ការអប់រំបន្ថែមទៀត ឬសម្រាប់ការងារ។
- មានលទ្ធភាពកំណត់ព័ត៌មានដែលត្រូវការដើម្បីសម្រេចបានគោលដៅរបស់ខ្លួន និងទីកន្លែងដែលអាចទទួលព័ត៌មានទាំងនោះបាន។
- មានការយល់ដឹងពីហិរញ្ញវត្ថុជាមូលដ្ឋានដែលរួមមាន ៖ សេវាធនាគារ ការសន្សំប្រាក់ និងការចំណាយប្រាក់។

- យល់ថាតើបណ្ដុំជំនាញណាខ្លះដែលគេត្រូវការសម្រាប់អាជីពនានាដែលគេជ្រើសរើស
- មានលទ្ធភាពកំណត់ពីបុគ្គលគំរូនានានៅក្នុងសហគមន៍ដែលអាចផ្ដល់ឱ្យពួកគេនូវការណែនាំសម្រាប់អនាគតរបស់ខ្លួន។
- ដឹងពីការអនុវត្តការងារដែលមានលក្ខណៈសមស្រប មានសុវត្ថិភាព យុត្តិធម៌ និងមានក្រមសីលធម៌។

## ៣. សេចក្តីពន្យល់ពីការប្រើប្រាស់ម៉ូឌុល

សៀវភៅនេះគឺជាសៀវភៅសម្រាប់គ្រូដែលបានរៀបចំរួចជាស្រេចនូវផែនការ ឬលំនាំនៃការបង្រៀនសម្រាប់ជំនួយដល់គ្រូក្នុងការបង្រៀនសិស្ស។ វាចែកចេញជា៦ផ្នែកធំៗតាមលំដាប់លំដោយពោលគឺ ១) ផ្នែក ២) ម៉ូឌុល ៣) ជំពូក ៤) មេរៀន ៥) ឧបសម្ព័ន្ធទី១ សន្លឹកកិច្ចការសិស្ស និង ៦) ឧបសម្ព័ន្ធទី២ ទម្រង់វាយតម្លៃសិស្សមុន និងក្រោយពេលបង្រៀន។ នៅក្នុងម៉ូឌុលមានបែងចែកជាជំពូកធំៗចំនួន៥ ហើយនៅក្នុងជំពូកនីមួយៗមានចំនួនមេរៀនជាក់លាក់ទៅតាមភាពចាំបាច់របស់ជំពូក។

**ផ្នែកនៃម៉ូឌុល** ផ្ដល់នូវការណែនាំទូទៅទាក់ទងនឹងខ្លឹមសារទាំងមូលនៃប្រធានបទ ជំពូក និងមេរៀន។ ដូច្នេះនៅក្នុងផ្នែកនេះ បានដាក់បញ្ចូលនូវ៖ ទិដ្ឋភាពទូទៅនៃម៉ូឌុល រយៈពេលឬចំនួនម៉ោងបង្រៀនសរុប ចំនួនលំនាំបង្រៀន និងវត្ថុបំណងរបស់ម៉ូឌុលដើម្បីឱ្យគ្រូបង្រៀនយល់ដឹងបានទូលំទូលាយពីខ្លឹមសារទូទៅរបស់ប្រធានបទទាំងមូល។

**ផ្នែកនៃជំពូក** ផ្ដល់នូវការណែនាំជាក់លាក់សម្រាប់ប្រធានបទរួមរបស់មេរៀនទាំងមូលនៅក្នុងជំពូកនីមួយៗ។ ដូចគ្នានឹងផ្នែកម៉ូឌុលដែរ បានដាក់បញ្ចូលនូវ៖ ទិដ្ឋភាពទូទៅ រយៈពេលឬចំនួនម៉ោងបង្រៀនសរុប ចំនួនលំនាំបង្រៀន និងវត្ថុបំណងដាច់ដោយឡែកសម្រាប់ជំពូកនីមួយៗ ដើម្បីឱ្យគ្រូបង្រៀនយល់ដឹងពីខ្លឹមសារទូទៅរបស់ជំពូកនីមួយៗ។

**ផ្នែកនៃមេរៀន** ផ្ដល់នូវព័ត៌មានលម្អិតសម្រាប់ការងាររៀបចំជាមុនរបស់គ្រូបង្រៀន។ នៅក្នុងមេរៀននីមួយៗមានកំណត់ និងរៀបចំតាមលំដាប់លំដោយនូវ៖ វត្ថុបំណង រយៈពេលសារសំខាន់ៗ សម្ភារៈដែលត្រូវការ សេចក្ដីណែនាំ និងចំណុចសម្រាប់ការពិភាក្សា។ នៅខាងដើមនៃសកម្មភាពនីមួយៗក៏បានបញ្ចូលនូវ«គន្លឹះសម្រាប់គ្រូបង្រៀន»ដើម្បីជាជំនួយដល់គ្រូបង្រៀនផងដែរ។

**ផ្នែកឧបសម្ព័ន្ធទី១** សន្លឹកកិច្ចការសិស្សមានបញ្ជាក់ច្បាស់លាស់ពីកិច្ចការសម្រាប់សិស្ស ដែលត្រូវបំពេញនៅក្នុងថ្នាក់ និងកិច្ចការផ្ទះផងដែរ។

**ផ្នែកឧបសម្ព័ន្ធទី២** ទម្រង់វាយតម្លៃសិស្សមុន និងក្រោយពេលបង្រៀន គឺជាទម្រង់ស្តង់ដារដែលសិស្សត្រូវបំពេញមុនពេលរៀន និងក្រោយពេលបញ្ចប់ដើម្បីឱ្យគ្រូងាយស្រួលក្នុងការពិនិត្យមើលលទ្ធផលសិក្សារបស់សិស្សក្រោយពេលបញ្ចប់ម៉ូឌុលនេះ។

- **ការត្រៀមលក្ខណៈមុនពេលបង្រៀនសិស្ស**

មានព័ត៌មានទាក់ទងនឹងរបៀបចាប់ផ្តើមបង្រៀនសិស្ស ឬផ្នែកដែលទាក់ទងនឹងសកម្មភាពនៃការបង្រៀន និងរៀន។ វាក៏ផ្តល់នូវការណែនាំពីការរៀបចំសម្ភារៈ និងឯកសារដែលគ្រូបង្រៀនត្រូវការសម្រាប់ការបង្រៀន និងរៀន។

- **សម្ភារឧបទេ្ទស**

ផ្នែកនេះផ្តល់នូវសេចក្តីសង្ខេបពីសម្ភារឧបទ្ទេស ដែលភាគច្រើនជាសម្ភារៈមូលដ្ឋានដូចជា ក្តារខៀន ដីស ឬហ្វឺត ស្កុត កន្ត្រៃ ប៊ិក សៀវភៅ ក្រដាសទំហំផ្សេងៗគ្នា ក្រដាសព័ត៌មាន ឬឯកសារផ្សេងៗជាដើម។ សម្ភារៈ ឯកសារផ្សេងៗទៀតនៅក្នុងសៀវភៅនេះក៏ត្រូវបានផ្តល់ឱ្យសិស្សសម្រាប់អនុវត្តដែរតាមរយៈសន្លឹកកិច្ចការសម្រាប់សិស្សដែលមានភ្ជាប់នៅក្នុងសៀវភៅនេះ។

- **វត្ថុបំណង**

ផ្តល់នូវឃ្លា ឬប្រយោគជាក់លាក់មួយចំនួនពីអ្វីដែលត្រូវសម្រេចឱ្យបាន។ សម្រាប់ចំណុចនេះ វត្ថុបំណងចែកចេញជា៣ផ្នែកធំៗដូចរៀបរាប់ខាងលើ ពោលគឺ ៖ ១) វត្ថុបំណងទូទៅដែលមានកំណត់នៅក្នុងផ្នែកនៃម៉ូឌុល ២) វត្ថុបំណងដែលមានលក្ខណៈជាក់លាក់ដែលមានកំណត់នៅក្នុងផ្នែកនៃជំពូក និង ៣) វត្ថុបំណងជាក់លាក់សម្រាប់មេរៀននីមួយៗ។

- **ជំហាន និងលំនាំនៃការបង្រៀន និងរៀន**

នេះជាផ្នែកមេរៀនពិតប្រាកដ។ នៅក្នុងផ្នែកនេះមានផ្តល់ព័ត៌មានទាក់ទងនឹងរយៈពេលបង្រៀន និងរៀន វត្ថុបំណង សារសំខាន់ៗ សម្ភារៈដែលត្រូវការ សេចក្តីណែនាំនិងគន្លឹះសម្រាប់គ្រូបង្រៀន ដែលជាផ្នែកដ៏សំខាន់សម្រាប់គ្រូបង្រៀនក្នុងការធ្វើសកម្មភាពក្នុងពេលបង្រៀន និងរៀន។ នៅក្នុងផ្នែកនៃ«សេចក្តីណែនាំ»មានបញ្ជាក់នូវសកម្មភាពដែលគ្រូបង្រៀនត្រូវធ្វើសំណួរបំផុសគំនិត ឧទាហរណ៍ និងព័ត៌មានផ្សេងៗទៀត។ ដូចដែលបានបញ្ជាក់ពីខាងលើ «គន្លឹះសម្រាប់គ្រូបង្រៀន»

ដែលនៅក្នុងមេរៀននីមួយៗ ក៏ផ្តល់នូវការណែនាំបន្ថែមសម្រាប់ដំណើរការបង្រៀន និងរៀន និងខ្លឹមសារផ្សេងៗដែលគ្រូបង្រៀនអាចណែនាំ និងពន្យល់សិស្សបន្ថែមទៀតទៅលើខ្លឹមសារមេរៀន។

- **ការប្រើប្រាស់និមិត្តសញ្ញា**

និមិត្តសញ្ញាមួយចំនួនត្រូវបានគេដាក់បញ្ចូលនៅក្នុងសៀវភៅនេះដើម្បីឱ្យគ្រូបង្រៀនមានការចាប់អារម្មណ៍ និងងាយស្រួលយល់ និងប្រើប្រាស់។ និមិត្តសញ្ញាទាំងនោះរួមមាន ៖

| | | |
|---|---|---|
| 🏆 វត្ថុបំណងម៉ូឌុល ឬជំពូក | ៖ | ចំណេះដឹងក្រោយរបស់សិស្សដែលទទួលបាននៅក្នុងម៉ូឌុលទាំងមូល និងជំពូកនីមួយៗ។<br>☺ ចំណេះដឹងលម្អិតនីមួយៗដែលសិស្សទទួលបាន។ |
| ❐ ចំនួនលំនាំបង្រៀន | ៖ | ចំនួនលំនាំបង្រៀនសរុបសម្រាប់ជំពូកនីមួយៗ។ |
| 🕘 រយៈពេល | ៖ | ចំនួនម៉ោងសម្រាប់មេរៀននីមួយៗ។ |
| ➲ វត្ថុបំណងមេរៀន | ៖ | លទ្ធផលសិក្សាដែលសិស្សសម្រេចបានក្រោយពីបញ្ចប់មេរៀននីមួយៗ។ |
| ✉ សារសំខាន់ៗ | ៖ | ខ្លឹមសារសង្ខេបរបស់មេរៀននីមួយៗដែលគ្រូបង្រៀនត្រូវបញ្ជាក់ប្រាប់សិស្ស។<br>🗎 ខ្លឹមសារសង្ខេបនីមួយៗ។ |
| 🕮 សម្ភារៈដែលត្រូវការ | ៖ | មានសរសេរនៅក្នុងមេរៀននីមួយៗដែលតម្រូវឱ្យគ្រូបង្រៀនរៀបចំទុកជាមុន។ |
| 📢 សេចក្តីណែនាំ | ៖ | ចំណុចនានាដែលគ្រូបង្រៀនត្រូវអនុវត្តជាទូទៅក្នុងពេលបង្រៀននិងរៀន។<br>☞ ចំណុចនីមួយៗដែលគ្រូបង្រៀនត្រូវធ្វើ។ |
| 🗣 ចំណុចសម្រាប់ការពិភាក្សា | ៖ | បញ្ជាក់ពីចំណុចសម្រាប់ការពិភាក្សាក្រុមតូច ឬក្រុមធំ។<br>◈ សំណួរបំផុសគំនិត ឬពិភាក្សាក្នុងពេលបង្រៀន និងរៀន។<br>☝ ចម្លើយសម្រាប់សំណួរនីមួយៗ ឬការពន្យល់ទូទៅ។ |
| ⊶ គន្លឹះសម្រាប់គ្រូបង្រៀន | ៖ | ចំណុចបន្ថែមដែលគ្រូបង្រៀនត្រូវរៀបចំ អនុវត្ត ឬពន្យល់បន្ថែមក្នុងពេលបង្រៀន និងរៀន។<br>🕯 ចំណុចដែលគ្រូបង្រៀនត្រូវរៀបចំ អនុវត្តឬពន្យល់បន្ថែម។ |

**កិច្ចការផ្ទះ** ៖ កិច្ចការដែលគ្រូបង្រៀនដាក់ឱ្យសិស្សបំពេញនៅផ្ទះ។

**កិច្ចការក្នុងថ្នាក់** ៖ កិច្ចការដែលគ្រូបង្រៀនដាក់ឱ្យសិស្សបំពេញនៅក្នុងថ្នាក់។

## ៤. សន្លឹកកិច្ចការសិស្ស

នៅខាងក្រោយនៃសៀវភៅនេះមានដាក់បញ្ចូលនូវសន្លឹកកិច្ចការសិស្ស*(ឧបសម្ព័ន្ធទី១)*។ មេរៀនមួយចំនួនក្នុងចំណោមមេរៀនទាំងនេះមានឯកសារ និងលំហាត់សម្រាប់សិស្ស។ តាមការដាក់ស្តែងគ្រូអាចថតចម្លងលំហាត់ ឬអាចរៀបចំសន្លឹកកិច្ចការសិស្សនីមួយៗសម្រាប់ចែកជូនដល់សិស្ស។ តាមការអនុវត្តជាក់ស្តែង និងលក្ខណៈពិសេសរបស់ម៉ូឌុល សន្លឹកកិច្ចការសិស្សគប្បីដាក់បញ្ចូលគ្នាទាំង៤ម៉ូឌុលដើម្បីឱ្យសិស្សអាចមើលឡើងវិញបាននៅពេលដែលត្រូវការ ព្រោះថាម៉ូឌុលទាំង៤ពាក់ព័ន្ធនឹងការប្រតិបត្តិល្អច្រើនក្នុងជីវិតប្រចាំថ្ងៃ។

## ៥. ខ្លឹមសារសង្ខេបរបស់ម៉ូឌុល

ខាងក្រោមនេះគឺជាសេចក្តីសង្ខេបរបស់មេរៀនទាំង៨ដែលមាននៅក្នុងម៉ូឌុលនេះ ៖

| ចំណងជើងមេរៀន | រយៈពេល | សេចក្តីសង្ខេប |
|---|---|---|
| **ជំពូកទី១ ៖ យេនឌ័រ និងបំណងប្រាថ្នា** | | |
| ១. តើការងារបង្កើតឱ្យមានតួនាទីយេនឌ័រដូចម្តេច? | ៤៥នាទី | - សិស្សសិក្សាពីផលប៉ះពាល់របស់យេនឌ័រទៅលើទិដ្ឋភាពខុសៗគ្នានៃការងារ។ |
| ២. ស្ត្រី និងការងារ | ៤៥នាទី | - សិស្សយល់ពីសារៈសំខាន់នៃការងារដែលទទួលបានប្រាក់កម្រៃ។ |
| **ជំពូកទី២ ៖ ការរៀបចំផែនទីស្តីពីបំណងប្រាថ្នា និងការកំណត់គោលដៅ** | | |
| ៣. ខ្ញុំប្រាថ្នាចង់បាន | ៤៥នាទី | - សិស្សបែងចែកដាច់ពីគ្នារវាងការចាប់អារម្មណ៍ និងបំណងប្រាថ្នា ព្រមទាំងជួយពួកគេឱ្យកំណត់ពីជំនាញ (បំណិន)ជាលក្ខណៈបុគ្គលម្នាក់ៗដើម្បីរៀបចំផែនទីបង្ហាញផ្លូវសម្រាប់គោលដៅផ្ទាល់ខ្លួន។<br>- សិស្សកំណត់ធនធាន និងជម្រើសជាក់ស្តែងដែលអាចអនុវត្តបានក្នុងការរៀបចំគោលដៅ និងបំណងប្រាថ្នាសម្រាប់អាជីពរបស់ខ្លួន។ |

| | | |
|---|---|---|
| ៤. គោលដៅ និងការកំណត់គោលដៅ | ៤៥នាទី | - សិស្សយល់ពីអត្ថន័យនៃគោលដៅ និងផ្តល់ធាតុចូលពីរបៀបកំណត់គោលដៅនោះ។ |
| **ជំពូកទី៣ ៖ ជំនាញ(បំណិន)ដែលប្អូនចង់បាន** | | |
| ៥. តើ កញ្ញា គួរធ្វើអ្វីខ្លះ? | ៤៥នាទី | - សិស្សយល់ពីការធ្វើសេចក្តីសម្រេចចិត្ត ជំហានទាក់ទងនឹងការធ្វើសេចក្តីសម្រេចចិត្ត និងសារៈសំខាន់នៃការថ្លឹងថ្លែងពីផលវិបាកនៃការសម្រេចចិត្ត។ |
| ៦ ៖ ការគ្រប់គ្រងពេលវេលា | ៤៥នាទី | - សិស្សយល់ពីតម្លៃពេលវេលា និងរៀនពីរបៀបគ្រប់គ្រងវាឱ្យកាន់តែមានប្រសិទ្ធភាព។ |
| ៧ ៖ ការគ្រប់គ្រងអារម្មណ៍តានតឹង | ៤៥នាទី | សិស្សយល់ពីរបៀបដែលអារម្មណ៍តានតឹងមានឥទ្ធិពលដល់ជីវិតរបស់មនុស្ស និងរៀនរបៀបដោះស្រាយវាឱ្យមានប្រសិទ្ធភាពនៅផ្ទះ និងនៅកន្លែងធ្វើការ។ |
| ៨ ៖ នរណាជាអ្នកដឹកនាំ? | ៤៥នាទី | - សិស្សពិភាក្សា និងយល់ពីគុណសម្បត្តិរបស់អ្នកដឹកនាំ និងមានលទ្ធភាពទទួលស្គាល់គុណសម្បត្តិទាំងនោះចំពោះបុគ្គលណាម្នាក់។<br>- សិស្សរៀនពីការធ្វើជាអ្នកដឹកនាំនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់មនុស្សម្នាក់។ |

## ៦. ការវាយតម្លៃសិស្ស

នៅខាងចុងនៃសៀវភៅនេះមានដាក់បញ្ចូលនូវទម្រង់នៃការវាយតម្លៃសិស្ស*(ឧបសម្ព័ន្ធទី២)* ដែលទម្រង់នេះត្រូវបានរៀបចំឡើងសម្រាប់វាស់វែងចំណេះដឹងរបស់សិស្ស។ ការវាយតម្លៃនេះត្រូវធ្វើជាពីរដំណាក់កាល ពោលគឺ ការវាយតម្លៃមុនពេលបង្រៀន *(Pre-test)* និងក្រោយពេល បង្រៀន *(Post-test)* ដើម្បីពិនិត្យមើលលើការរីកចម្រើនផ្នែកចំណេះដឹងរបស់សិស្ស។

## ៧. ឯកសារយោង (**បន្ថែម**)

នៅក្នុងមេរៀននីមួយៗមានបញ្ចូលនូវឯកសារយោង ឬបន្ថែមសម្រាប់ការអានរបស់សិស្ស និងការពន្យល់បន្ថែមរបស់គ្រូ។ ឯកសារទាំងនេះមានចំនួន២ប្រភេទគឺ «ឧបសម្ព័ន្ធ និងក្របខណ្ឌចំណេះដឹង»។ វាមានសារៈសំខាន់ណាស់ដែលគ្រូបង្រៀនត្រូវអានចំណុចទាំងនេះជាមុន ព្រោះវាផ្តល់នូវការពន្យល់ទូទៅនូវចំណេះដឹងមួយចំនួន។

# ផ្នែក ៖ សមត្ថភាពធ្វើការងារ

**ទិដ្ឋភាពទូទៅ**

ផ្នែកស្តីពី «សមត្ថភាពធ្វើការងារ» មាន២ម៉ូឌុល ៖

- សមត្ថភាពធ្វើការងារ / ភាពវាងវៃ
- សមត្ថភាពរកការងារធ្វើ

ម៉ូឌុលទី២ «សមត្ថភាពរកការងារធ្វើ» ចែកចេញជា២ផ្នែកទៀត ៖

- ផ្នែកទី១ ៖ សមត្ថភាពរកការងារធ្វើ
- ផ្នែកទី២ ៖ សហគ្រិនភាព

វត្ថុបំណងរបស់ផ្នែកនេះគឺដើម្បីធ្វើឱ្យសិស្សមានបំណិន និងភាពជឿជាក់ដែលចាំបាច់ដើម្បី អាចអនុវត្តនូវជំហានជាក់លាក់សម្រាប់អនាគតរបស់ពួកគេ។

ជំពូកនានាដែលរៀបចំឡើងនៅក្រោមផ្នែកនេះជួយឱ្យសិស្សរៀនពីរបៀបដែលការងារបង្កើត តួនាទីយេនឌ័រ និងរបៀបដែលពួកគេអាចអភិវឌ្ឍជំនាញដែលនឹងធ្វើឱ្យពួកគេកាន់តែមានភាពវាងវៃ ថែមទៀតដូចជាការរៀបចំផែនទីបំណងប្រាថ្នានិងការកំណត់គោលដៅ ការគ្រប់គ្រងពេលវេលា ការគ្រប់គ្រងការតានតឹងអារម្មណ៍ និងជំនាញភាពជាអ្នកដឹកនាំ។ ពួកគេក៏នឹងរៀនពីរបៀបបង្កើត ប្រវត្តិរូបសង្ខេប ឬដាក់ពាក្យសុំធ្វើការងារដែលត្រូវនឹងចំណាប់អារម្មណ៍របស់ខ្លួន របៀបរៀបចំសម្រាប់ការសម្ភាសន៍ របៀបសន្សំប្រាក់ និងគ្រប់គ្រងថវិកា ។ល។ សិស្សក៏ទទួលបានការណែនាំពីទស្សនៈស្តីពីសហគ្រិនភាព និងជំនាញដែលមនុស្សម្នាក់ត្រូវការដើម្បីក្លាយជាសហគ្រិនជោគជ័យ និងចាប់ផ្តើមបើកសហគ្រាស។

ការរួមបញ្ចូលគ្នានូវម៉ូឌុលទាំងពីរស្តីពីសមត្ថភាពធ្វើការងារ / ភាពវាងវៃ និង សមត្ថភាពរកការងារធ្វើនៅក្នុងផ្នែកនេះអាចឱ្យសិស្សមានភាពជឿជាក់ និងមានជំនាញកាន់តែច្រើនដើម្បីរៀបចំផែនការសម្រាប់អនាគតរបស់ពួកគេ។

# ម៉ូឌុលទី៣ ៖ សមត្ថភាពធ្វើការងារ / ភាពខាងវៃ

### ទិដ្ឋភាពទូទៅ

នៅក្នុងម៉ូឌុលទី១ ស្តីពី ៖ «ខ្លួនឯង» សិស្សបានរៀនពីយេនឌ័រ អំណាច និងបិតាធិបតេយ្យ និងរបៀបដែលចំណុចទាំងនេះកំណត់ពីឥទ្ធិពល និងផលជះលើអត្តសញ្ញាណ និងជីវិតរបស់ពួកគេ។ ម៉ូឌុលទី២ ស្តីពី ៖ «ស្វ័យប្រសិទ្ធភាព» ផ្តោតលើការជួយសិស្សឱ្យអភិវឌ្ឍបំណិនជាក់លាក់នានាជុំវិញការប្រាស្រ័យទាក់ទងដែលអាចលើកកម្ពស់សមត្ថភាពក្នុងការគិតដោយឯករាជ្យ និងការចរចារបស់ពួកគេ។ ម៉ូឌុលទាំងពីរដែលស្ថិតក្នុងផ្នែកនេះ «ការផ្តល់ភាពអង់អាច» ក៏ជួយសិស្សឱ្យរៀនសូត្រពីប្រភេទនានានៃការទំនាក់ទំនង របៀបដែលអំណាចដំណើរការក្នុងការទំនាក់ទំនង ព្រមទាំងរបៀបកត់សម្គាល់អំពើហិង្សានិងកត្តាទូទៅរបស់វានៅក្នុងបរិយាកាសរបស់ខ្លួន និងនៅក្នុង ទំនាក់ទំនងផ្សេងៗ។

នៅត្រង់ចំណុចនេះ ការយល់ដឹង និងការសិក្សាស្វែងយល់ដែលសិស្សទទួលបាននឹងជួយពួកគេឱ្យបង្កើតនូវភាពនៃខ្លួនឯងកាន់តែរឹងមាំថែមទៀត ហើយបន្ទាប់មកពួកគេអាចចាប់ផ្តើមមាន គំនិតមួយចំនួនជុំវិញទីកន្លែងដែលពួកគេមើលឃើញពីខ្លួនឯងនៅថ្ងៃអនាគត។

ម៉ូឌុលទី៣ស្តីពី ៖ សមត្ថភាពធ្វើការងារ «កម្មវិធីសិក្សា Gap Inc.P.A.C.E.» សម្រាប់ក្មេងស្រីពេញវ័យនឹងធ្វើឱ្យដំណើរការផ្លាស់ប្តូរនេះកាន់តែមានលទ្ធភាពថែមទៀត ព្រមទាំងផ្តល់ភាពអង់អាចដល់សិស្សមានទំនុកចិត្តថែមទៀតក្នុងការបំពេញគន្លងអាជីពនាពេលអនាគតរបស់ខ្លួន។ វានឹងជួយពួកគេឱ្យរៀនសូត្រពីរបៀបធ្វើឱ្យខ្លួនមានភាពវាងវៃនៅក្នុងជីវិតផ្ទាល់របស់ខ្លួនតាមរយៈការធ្វើឱ្យពួកគេមានលទ្ធភាព ៖

- យល់ពីរបៀបដែលការងារកំណត់ពីយេនឌ័រ
- រៀបចំផែនទីគោលដៅអាជីពរបស់ខ្លួន
- រៀនពីរបៀបធ្វើការសម្រេចចិត្តដោយមានព័ត៌មានគ្រប់ជ្រុងជ្រោយ
- គ្រប់គ្រងពេលវេលា និងភាពតានតឹងរបស់ខ្លួន
- អភិវឌ្ឍជំនាញភាពជាអ្នកដឹកនាំ

តាមរយៈការចូលរួមនៅក្នុងម៉ូឌុលទី៣ សិស្សនឹងរៀបចំខ្លួនបានកាន់តែប្រសើរឡើង ក្នុងការរៀបចំផែនការ និងធ្វើឱ្យបានសម្រេចនូវបំណងប្រាថ្នានាពេលអនាគតរបស់ខ្លួន។

រយៈពេលរបស់ម៉ូឌុល ៖ ៦ ម៉ោង

ចំនួនលំនាំបង្រៀនសរុប ៖ ៨

| វត្ថុបំណង ៖ |
| --- |
| ១. ដើម្បីមានចក្ខុវិស័យច្បាស់លាស់ពីគោលដៅរបស់ពួកគេ និងមានលទ្ធភាពរៀបចំផែនការច្បាស់ លាស់មួយសម្រាប់ការអប់រំបន្ថែមទៀត ឬសម្រាប់ការងារ។ |
| ២. ដើម្បីមានលទ្ធភាពកំណត់ព័ត៌មានដែលត្រូវការដើម្បីសម្រេចបានគោលដៅរបស់ខ្លួន និងទីកន្លែងដែលអាចទទួលព័ត៌មានទាំងនោះបាន។ |
| ៣. ដើម្បីមានការយល់ដឹងពីហិរញ្ញវត្ថុជាមូលដ្ឋានដែលរួមមាន ៖ សេវាធនាគារ ការសន្សំប្រាក់ និងការចំណាយប្រាក់។ |
| ៤. ដើម្បីយល់ថាតើបណ្តុំជំនាញណាខ្លះដែលគេត្រូវការសម្រាប់អាជីពនានាដែលគេជ្រើសរើស។ |
| ៥. ដើម្បីមានលទ្ធភាពកំណត់ពីបុគ្គលគំរូនានានៅក្នុងសហគមន៍ដែលអាចផ្តល់ឱ្យពួកគេនូវការណែនាំសម្រាប់អនាគតរបស់ខ្លួន។ |
| ៦. ដើម្បីដឹងពីការអនុវត្តការងារដែលមានលក្ខណៈសមស្រប មានសុវត្ថិភាព យុត្តិធម៌ និងមានក្រមសីលធម៌។ |

# សំណុំឯកសារសម្រាប់គ្រូបង្រៀន

## ឯកសារអំណានទី១ ៖ ព័ត៌មានបន្ថែមសម្រាប់គ្រូបង្រៀនក្នុងម៉ូឌុលនេះ

សន្ទានុក្រមពាក្យបច្ចេកទេស

☞ **ធនធាន** ៖ ទីកន្លែង ឬវត្ថុដែលផ្តល់អ្វីមួយដែលមានប្រយោជន៍។

☞ **ភាពវាងវៃ** ៖ សមត្ថភាពដោះស្រាយស្ថានភាពថ្មី ឬលំបាក និងសមត្ថភាពស្វែងរកដំណោះស្រាយចំពោះបញ្ហាផ្សេងៗ។

.................................................................................................................................
.................................................................................................................................

◈ **ហេតុអ្វីបានជាយើងត្រូវការធនធាន?**

- យើងត្រូវការធនធានដើម្បីឱ្យជីវិតរស់នៅរបស់យើងមានសក្តានុពលពេញលេញបំផុត។
- យើងអាចមានធនធាននានាជាឧបករណ៍មួយដើម្បីសម្រេចគោលដៅរបស់យើង។
- ធនធានគឺជាលក្ខខណ្ឌ ដោយសារតែវាពឹងផ្អែកលើស្ថានភាពរបស់យើង និងលទ្ធភាពដែលយើងទទួលបានធនធានដែលយើងត្រូវការបានកម្រិតណា។
- ជារឿយៗ ធនធាននានាមានទំនាក់ទំនងគ្នាពីមួយទៅមួយ។ វាមានសារៈសំខាន់ក្នុងការស្វែងរក និងប្រើប្រាស់ធនធានទាំងនោះឱ្យមានប្រសិទ្ធភាព។

◈ **តើឧទាហរណ៍មួយចំនួនស្តីពីធនធានមានអ្វីខ្លះ?**

- ឱកាស
- ពេលវេលា
- ការអប់រំ
- ប្រាក់
- មនុស្ស
- ទ្រព្យសម្បត្តិ
- ធនធានធម្មជាតិ
- បច្ចេកវិទ្យា
- អំណាច
- ព័ត៌មាន

**ហេតុអ្វីបានជាក្មេងស្រីចាំបាច់ត្រូវរៀនដើម្បីឱ្យមានភាពរាងវៃ?**

- ការរៀនពីជំហាននានាដើម្បីឱ្យមានភាពវាងវៃគឺជាគន្លងដ៏សំខាន់មួយសម្រាប់ក្មេងស្រីក្នុងការអនុវត្តតាមផែនការ និងគោលដៅដែលពួកគេបានកំណត់សម្រាប់អនាគតរបស់ខ្លួន។
- ប្រសិនបើក្មេងស្រីរៀនពីរបៀបធ្វើឱ្យមានភាពវាងវៃ ពួកគេនឹងមានការសម្រេចចិត្តដោយឯករាជ្យក្នុងការស្វែងរកធនធានផ្សេងៗដែលពួកគេត្រូវការ និងរៀនពីរបៀបសម្រេចបានគោលដៅរបស់ខ្លួន ដោយឯករាជ្យ បើទោះបីជាពួកគេអាចជួបប្រទះការលំបាកណាមួយនៅក្នុងដំណើរការនេះក៏ដោយ។

# ជំពូកទី១ ៖ យេនឌ័រ និងបំណងប្រាថ្នា



**ទិដ្ឋភាពទូទៅ**

ជំពូកទី១នៅក្នុងម៉ូឌុលទី៣ ផ្តោតលើ «យេនឌ័រ និងបំណងប្រាថ្នា»។

ជំពូកនេះនឹងជួយសិស្សឱ្យយល់កាន់តែទូលំទូលាយពីរបៀបដែលយេនឌ័រមានឥទ្ធិពលលើអនាគតរបស់ពួកគេទាក់ទងនឹងការងារវិជ្ជាជីវៈ និងអាជីពដែលជាបំណងប្រាថ្នានៃអាជីពរបស់ពួកគេ។ ជំពូកនេះក៏ជម្រុញឱ្យសិស្សគិតពីភាពសំខាន់របស់ស្ត្រីដើម្បីចូលរួមក្នុងការងារដែលមានប្រាក់ឈ្នួលដែលជាជម្រើសរបស់គេដែរ។

**រយៈពេលរបស់ជំពូក ៖ ៩០ នាទី**

**ចំនួនលំនាំបង្រៀនសរុប ៖ ២**

| **វត្ថុបំណង** |
|---|
| ១. ដើម្បីរៀនពីរបៀបដែលការងារបង្កើតតួនាទីយេនឌ័រ និងរបៀបដែលយេនឌ័រអាចប៉ះពាល់ដល់ប្រភេទការងារ ឬអាជីពដែលពួកគេប្រាថ្នាចង់បាន ឬជ្រើសរើសដើម្បីសម្រេចឱ្យបាន។ |
| ២. ដើម្បីរៀនពីសារៈសំខាន់នៃការងារដែលទទួលបានកម្រៃ។ |

# មេរៀនទី១ ៖ តើការងារបង្កើតឱ្យមានតួនាទីយេនឌ័រដូចម្តេច?

➲ **វត្ថុបំណងមេរៀន ៖** ដើម្បីបង្ហាញដល់សិស្សពីផលប៉ះពាល់របស់យេនឌ័រទៅលើទិដ្ឋភាពខុសៗគ្នានៃការងារ។

🕘 **រយៈពេលមេរៀន ៖** ៤៥ នាទី

✉ **សារសំខាន់ៗ ៖**

១. ការងារគឺជាផ្នែកដែលមានការកំណត់ពីតួនាទីយេនឌ័រ ប៉ុន្តែវាក៏មានវិធីជាច្រើនដើម្បីប្រើប្រាស់លំហរក្នុងការទទួលបានអ្វីដែលប្អូនចង់បាននៅថ្ងៃអនាគត។

២. ក្នុងនាមជាក្មេងស្រី ប្អូនមិនគួរមានអារម្មណ៍ថាទទួលរងការបង្ខិតបង្ខំក្នុងការជ្រើសរើសការងារដោយសារបទដ្ឋានយេនឌ័រដែលសង្គមបានកំណត់ពីមុនមកទេ។ ប្អូនត្រូវមានការប្តេជ្ញាចិត្តឱ្យបានមុតមាំចំពោះអ្វីដែលប្អូនចង់បានពិតប្រាកដទោះបីជាវាមិនអនុលោមទៅតាមប្រភេទការងារដែលប្រពៃណីបានកំណត់ថាសម្រាប់តែស្ត្រីក៏ដោយ។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ ៖**

- ☞ សម្រាប់គ្រូបង្រៀន ៖ ក្រដាស A4 មួយសន្លឹក ក្រដាសផ្ទាំងធំមួយសន្លឹក ម៉ាស៊ីនថតចម្លង ក្តារខៀនហ្វឺត ឬដីស ហ្វឺតលុបមិនជ្រះចំនួនពីរដើម ស្កុត បន្ទាត់ និងកន្ត្រៃ។
- ☞ សម្រាប់សិស្ស ៖ សន្លឹកកិច្ចការ ៖ កិច្ចការក្នុងថ្នាក់ទំព័រទី៩១ និងកិច្ចការយកទៅផ្ទះទំព័រទី៩២-៩៣ និងប្រដាប់ប្រដាសរសេរ។

**ការរៀបចំទុកជាមុន ៖**

- ☞ អានទិដ្ឋភាពទូទៅស្តីពីផ្នែក«សមត្ថភាពធ្វើការងារ» ម៉ូឌុលទី៣ ៖ សមត្ថភាពធ្វើការងារ / ភាពវាងវៃ ម៉ូឌុលទី៣ ជំពូកទី១៖ យេនឌ័រ និងបំណងប្រាថ្នា និងព័ត៌មានបន្ថែមស្តីពីប្រធានបទនៃភាពវាងវៃ (សូមមើលឯកសារអំណានទី១ នៅក្នុងសំណុំឯកសារ សម្រាប់គ្រូបង្រៀន)។
- ☞ អានលំនាំបង្រៀននិងយល់ឱ្យច្បាស់ពីលំនាំការបង្រៀននោះ។

- បង្កើតតារាង «នរណាធ្វើកិច្ចការនេះ?[1]» នៅលើក្តារខៀន (សូមមើលឯកសារអំណានទី២ នៅក្នុងសំណុំឯកសាររបស់គ្រូបង្រៀន)។
- បង្កើតតារាងរឿងពិត «ការងាររបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា» នៅលើក្រដាសផ្ទាំងធំ (សូមមើលឯកសារអំណានទី ៣ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។
- ថតចម្លងឯកសារស្តីពី «ពន្យល់ការពិត ៖ ការងាររបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា» មួយច្បាប់ (សូមមើលឯកសារអំណានទី៤នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។
- ប្រមូលសម្ភារៈ ដែលត្រូវការផ្សេងៗទាំងអស់។
- សរសេរចំណងជើងមេរៀននៅលើក្តារខៀន។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- រំឭកសិស្សឱ្យចុះវត្តមានរបស់ពួកគេនៅពេលពួកគេចូលថ្នាក់រៀន។
- ពិនិត្យមើលថាតើសិស្សមានយកសន្លឹកកិច្ចការមកជាមួយដែរឬទេ។
- សួរសិស្សថាតើពួកគេបានធ្វើកិច្ចការផ្ទះរបស់ខ្លួនរួចរាល់ហើយឬនៅ។
- ឱ្យសិស្សម្នាក់ៗយកប្រដាប់ប្រដាសរសេរមុនពេលចូលរៀន។

## ២. ដំណើរការបង្រៀន

### សេចក្តីណែនាំ

- ស្វាគមន៍សិស្ស បន្ទាប់មកណែនាំពួកគេពីផ្នែកទី២ស្តីពី «សមត្ថភាពធ្វើការងារ» របស់កម្មវិធីសិក្សា Gap Inc. P.A.C.E.។
- សង្ខេបប្រាប់សិស្សពីទិដ្ឋភាពនៃម៉ូឌុលទី៣ និងអ្វី(មេរៀន)ដែលមាននៅក្នុងម៉ូឌុលនេះ។
- ណែនាំសិស្សពីជំពូកទី១នៃម៉ូឌុលទី៣។
- អាននិងចង្អុលចំណងជើងមេរៀននៅលើក្តារខៀន។ ឱ្យសិស្សទាយថាតើថ្ងៃនេះពួកគេនឹងរៀនពីមេរៀនអ្វី។ ឱ្យសិស្សស្ម័គ្រចិត្ត ២-៣នាក់ ចែករំលែកពីគំនិតរបស់ពួកគេនៅក្នុងក្រុម។
- ប្រាប់សិស្សថា នៅថ្ងៃនេះពួកគេនឹងផ្តោតលើរឿងសំខាន់ចំនួន២ ៖
  - របៀបដែលយេនឌ័រមានឥទ្ធិពលលើឱកាសការងារដែលស្ត្រីមានសិទ្ធិទទួលបាន។
  - របៀបដែលយេនឌ័រប៉ះពាល់ដល់ជីវិតផ្ទាល់ខ្លួន និងវិជ្ជាជីវៈរបស់ស្ត្រី។
- បែងចែកសិស្សនៅក្នុងថ្នាក់ជា៤ក្រុមស្មើៗគ្នា។

[1] ដកស្រង់ចេញពីអង្គការ Naz Foundations កម្មវិធីសិក្សា "គោលដៅសម្រាប់ក្មេងស្រី៖ ជាខ្លួនរបស់អ្នក"

- ឱ្យពួកគេអង្គុយតាមក្រុមដែលបានកំណត់ដោយបែរមុខទៅរកតារាងដែលបិទនៅក្នុងថ្នាក់។
- ប្រាប់ពួកគេថា ទាំងស្ត្រី និងបុរសធ្វើកិច្ចការខុសៗគ្នាទាំងនៅផ្ទះ និងនៅកន្លែងធ្វើការ។
- ចង្អុលទៅកាន់តារាង «នរណាធ្វើកិច្ចការនេះ?» បន្ទាប់មកនិយាយថា «ដំបូង យើងនឹងផ្តោតលើកិច្ចការដែលគេធ្វើនៅក្នុងផ្ទះ»។
- ផ្តល់ការណែនាំដូចខាងក្រោម ៖
  - ខ្ញុំ(លោកគ្រូ / អ្នកគ្រូ)នឹងអានភារកិច្ចម្តងមួយៗដែលមាននៅក្នុងតារាង។
  - ក្រុមរបស់ប្អូនមានពេល ១៥ នាទី ដើម្បីពិភាក្សាថាតើនរណាដែលធ្វើកិច្ចការជាក់លាក់នេះនៅផ្ទះ ៖ «បុរស» «ស្ត្រី» ឬ «ទាំងបុរស និងស្ត្រី»។
  - គិតពីបទដ្ឋានសង្គមជុំវិញកិច្ចការនីមួយៗដែលបានអាន។ ឧទាហរណ៍ នៅពេលដែលយើងគិតពីអ្នកធ្វើម្ហូបនៅផ្ទះ យើងគិតពីស្ត្រីនៅក្នុងគ្រួសារ *(ឧ. ម្តាយ បងប្អូនស្រី មីង ខ្លួនឯងផ្ទាល់)*។ នៅពេលយើងគិតពីអ្នកធ្វើម្ហូបនៅក្នុងភោជនីយដ្ឋាន ជាទូទៅយើងគិត ពីបុរស។
- ចាប់ផ្តើមសកម្មភាព។ ដាក់ឈ្មោះកិច្ចការនីមួយៗនៅក្នុងតារាង។ ឱ្យក្រុមនីមួយៗឆ្លើយម្នាក់ម្តងៗ។ កត់ត្រាចម្លើយទាំងអស់ដោយប្រៀបធៀបជាមួយនឹងភារកិច្ចនីមួយៗដោយប្រើអក្សរ «ប» សម្រាប់បុរស «ស» សម្រាប់ស្ត្រី និង «ប+ស» សម្រាប់ទាំងបុរស និងស្ត្រីនៅលើក្តារខៀន។
- អនុវត្តតាមដំណើរការដូចគ្នានេះដែរសម្រាប់ «កន្លែងធ្វើការ»។

> **គន្លឹះសម្រាប់គ្រូបង្រៀន ៖**
>
> - លើកទឹកចិត្តសិស្សក្នុងក្រុមនីមួយៗឱ្យផ្តល់ចម្លើយរបស់ខ្លួនឱ្យបានលឿនតាមដែលអាចធ្វើទៅបានមុនពេលពួកគេឯកភាពគ្នាដើម្បីចាប់យកអ្វីដែលពួកគេគិតដោយប្រើអារម្មណ៍ជាជាងគិតពីការពិត។ ពេលវេលាសម្រាប់ផ្ទុះបញ្ចាំងអាចផ្លាស់ប្តូរការឆ្លើយតបរបស់ពួកគេបានក្នុងការកែតម្រូវចម្លើយដែលពួកគេគិតថាគេចង់ឱ្យពួកគេឆ្លើយ។

- នៅពេលការឆ្លើយបានបញ្ចប់ អានចម្លើយទាំងអស់នៅលើក្តារខៀនឱ្យបានលឿន។

**កិច្ចការក្នុងថ្នាក់ ៖**

- សុំឱ្យសិស្សបើកសន្លឹកកិច្ចការរបស់ខ្លួននៅទំព័រទី៩១។
- អានសេចក្តីណែនាំ បន្ទាប់មកពន្យល់ពីអ្វីដែលពួកគេត្រូវធ្វើ ៖
  - អានអាជីពវិជ្ជាជីវៈដែលសរសេរនៅក្នុងកូឡោនទី១ និងផ្ទុះបញ្ចាំងពីបុគ្គលដែលជាទូទៅធ្វើការងារប្រភេទនេះ ៖ «បុរស» «ស្ត្រី» ឬ «ទាំងបុរស និងស្ត្រី»។

– គូសសញ្ញាធិក(✓)នៅក្នុងកូឡោនដែលត្រឹមត្រូវដើម្បីឆ្លុះបញ្ចាំងពីចម្លើយរបស់ប្អូន។
– ប្អូនមានពេល៣នាទីដើម្បីបំពេញកិច្ចការនេះ។

☞ ឱ្យសិស្សឆ្លុះបញ្ចាំងពីចម្លើយនៅក្នុងសន្លឹកកិច្ចការរបស់គេ បន្ទាប់មកឆ្លើយសំណួរខាងក្រោម ដើម្បីបំពេញកិច្ចការនៅក្នុងសន្លឹកកិច្ចការរបស់ពួកគេ ៖

– តើប្រភេទការងារជាក់លាក់មួយចំនួនជាទូទៅស្ត្រីជាអ្នកធ្វើនៅផ្ទះ ហើយបុរសជាអ្នកធ្វើនៅក្រៅផ្ទះមែនដែរឬទេ? គូសរង្វង់ «បាទ / ចាស» ឬ «ទេ» និងបន្ទាប់មកសរសេរប្រយោគ២ ឬ៣ ពាក់ព័ន្ធនឹងមូលហេតុដែលប្អូនគិតថាអាចនឹងមានការអនុវត្តបែបនេះ។
– ប្រាប់សិស្សថា ពួកគេមានពេល៥នាទីដើម្បីធ្វើកិច្ចការនេះ។

☞ សួរសិស្ស នូវសំណួរដូចខាងក្រោម ៖

– ទាក់ទងជាមួយនឹងសកម្មភាពក្នុងសន្លឹកកិច្ចការដែលយើងទើបតែបានធ្វើ តើមានប្រភេទភារកិច្ចជាក់លាក់មួយចំនួនដែលស្ត្រីធ្វើនៅផ្ទះ ប៉ុន្តែជាការងារអាជីពដែលបុរសធ្វើនៅក្រៅផ្ទះដែរឬទេ? ប្រសិនបើមាន តើមានហេតុផលអ្វីខ្លះសម្រាប់ភាពខុសគ្នាទាំងនេះ?

☞ ទទួលយកចម្លើយ២-៣ បន្ទាប់មកពន្យល់ដូចខាងក្រោម ៖

– ដូចបានពិភាក្សានៅម៉ូឌុលទី១ បិតាធិបតេយ្យគឺជាប្រព័ន្ធសង្គមមួយដែលគេផ្ដល់អាទិភាពឱ្យបុរស។ ប្រព័ន្ធនេះគ្រប់គ្រងលើទិដ្ឋភាពជាច្រើននៃជីវិតរបស់ស្ត្រីដូចជាសេរីភាព និងការដើរហើរ បញ្ហាផ្លូវភេទ និងការបន្តពូជ ទ្រព្យសម្បត្តិ ធនធាន និងការងាររបស់ពួកគេ។
– ភាពនៃបិតាធិបតេយ្យនេះធ្វើឱ្យមានប្រព័ន្ធទាំងមូលមួយដែលស្ត្រីត្រូវនៅផ្ទះដើម្បីធ្វើការងារដែលគេមិនទទួលស្គាល់ និងមិនមានប្រាក់កម្រៃ (ឧទាហរណ៍ ការមើលថែកូន និង ការទទួលខុសត្រូវក្នុងគ្រួសារ) ដែលរារាំងពួកគេមិនឱ្យស្វែងរកធនធាន ធ្វើការសម្រេចចិត្តក្នុងគ្រួសារ និងការបង្កើតទ្រព្យសម្បត្តិ (ឧទាហរណ៍ ការវិនិយោគលើទ្រព្យសម្បត្តិ)។
– ដោយសារបទដ្ឋានទាំងនេះ គេកំណត់ឱ្យស្ត្រី និងក្មេងស្រីបំពេញកិច្ចការក្នុងផ្ទះ ចំណែកបុរស និងក្មេងប្រុសជាអ្នករកប្រាក់។
– ជារឿយៗ បុរសធ្វើកិច្ចការស្រដៀងគ្នានេះដែរដូចជាការកាត់ដេរ ការចំអិនម្ហូបអាហារដើម្បីរកប្រាក់ចំណូល ចំណែកឯស្ត្រីបំពេញកិច្ចការទាំងនេះដែរនៅក្នុងផ្ទះរបស់ខ្លួនដោយមិនបានទទួលប្រាក់ឈ្នួលអ្វីទាំងអស់។
– សមាជិកគ្រួសារដែលជាអ្នករកប្រាក់ចំណូល (ក្នុងករណីនេះសំដៅលើបុរសជាចម្បង) មានអំណាចធ្វើការសម្រេចចិត្តនៅក្នុងគ្រួសារ។ ប្រព័ន្ធនេះធ្វើឱ្យស្ត្រីក្លាយជាបន្ទុកជាប់ជានិច្ចរបស់បុរស និងធ្វើឱ្យស្ត្រីមានតួនាទីជាអ្នកនៅក្រោមបង្គាប់តទៅទៀត។

– នៅគ្រប់សង្គមទាំងអស់ការទទួលខុសត្រូវចម្បងនៃកិច្ចការនៅក្នុងគ្រួសារគឺធ្លាក់ទៅលើស្ត្រី ចំណែកបុរសវិញទទួលខុសត្រូវចំពោះការរកប្រាក់សម្រាប់គ្រួសារ។ ខណៈពេលដែលបុគ្គលមួយចំនួនអាចធ្វើការបែងចែងការងារនេះតាមជម្រើសក៏ដោយ ក៏ជាញឹកញាប់បំផុតវាទទួលរងឥទ្ធិពលពីបទដ្ឋានយេនឌ័រ ដែលវប្បធម៌សង្គមទទួលយកសម្រាប់សង្គមនោះ។ ឧទាហរណ៍ ៖ គេចាត់ទុកថា ការដែលស្ត្រីចម្អិនម្ហូបអាហារនៅផ្ទះគឺជាកាតព្វកិច្ចរបស់គេ ស្របពេលដែលកិច្ចការដូចគ្នានេះដែលបុរសធ្វើនៅក្រៅផ្ទះដោយទទួលបានប្រាក់កម្រៃ ក្លាយជាការងារ និងទទួលបាននូវការគោរពច្រើន។
– យើងចាំបាច់ត្រូវចោទសួរពីសម្ពាធដែលស្ត្រី និងបុរសប្រឈមដើម្បីឱ្យស្របទៅតាម លក្ខណៈការងារដែលគេរំពឹងទុកផ្អែកយេនឌ័ររបស់ពួកគេ។ ការចរចានេះមានសារៈសំខាន់ណាស់ក្នុងការទាមទារមកវិញនូវសិទ្ធិសម្រេចចិត្តដោយខ្លួនឯងនិងសិទ្ធិក្នុងការជ្រើសរើស ដើម្បីធ្វើការសម្រេចចិត្តសម្រាប់គោលដៅរយៈពេលវែងរបស់ពួកគេ។

☞ សួរសំណួរដូចខាងក្រោម ៖

– ប្រសិនបើទាំងស្ត្រី និងបុរសធ្វើការនៅក្រៅផ្ទះ តើគេអាចគ្រប់គ្រងការទទួលខុសត្រូវនៅក្នុងគ្រួសារបានដោយរបៀបណា?

☞ ទទួលយកចម្លើយ បន្ទាប់មកបញ្ជាក់ថា ទំនួលខុសត្រូវនៅក្នុងគ្រួសារ នៅពេលដែលគេបែងចែកកំណត់ និងគ្រប់គ្រងជាមួយគ្នា និងទៅតាមការជ្រើសរើសរវាងសមាជិកទាំងបុរស និងស្ត្រី វាជាដំណើរការរីកចម្រើនមួយឆ្ពោះទៅរកលំហរនៃសមភាពយេនឌ័រ។

**🗝 គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ប្រើចម្លើយរបស់សិស្សដើម្បីបង្កើតឱ្យមានការពិភាក្សាពីរបៀបដែលគេបែងចែកការងារតាមយេនឌ័រនៅក្នុងផ្នែកខាងក្រោម។

## ៣. ការពង្រីកចំណេះដឹង

### 🗣 ចំណុចសម្រាប់ការពិភាក្សា

☞ ទាញការចាប់អារម្មណ៍របស់សិស្សទៅរកចម្លើយនៅក្នុងសន្លឹកកិច្ចការរបស់គេវិញ។ ឱ្យពួកគេឆ្លុះបញ្ចាំង និងឆ្លើយសំណួរដូចខាងក្រោម។

– តើប្អូនជឿថា មានប្រភេទការងារមួយចំនួនដែលបុរសគួរធ្វើ និងប្រភេទការងារមួយចំនួនដែលស្ត្រីគួរធ្វើដែរឬទេ? ប្រសិនបើជឿ ហេតុអ្វី? ប្រសិនបើមិនជឿ ហេតុអ្វី?

- តើប្រភេទការងារនោះមានអ្វីខ្លះ? ចូររៀបរាប់។
- តើការងារប្រភេទណាខ្លះដែលក្រុមមនុស្សភេទទីបី ឬក្រុមមនុស្សអន្តរភេទធ្វើបាន?

☞ ទទួលយកចម្លើយមួយចំនួន បន្ទាប់មកចែករំលែកចំណុចដូចខាងក្រោម ៖

- បទដ្ឋានយេនឌ័រមាននៅក្នុងសង្គមរបស់យើង និងមានផលប៉ះពាល់ទាំងបុរស និងស្ត្រីនៅពេលដែលវាក្លាយទៅជាជម្រើសនៃប្រភេទការងារដែលពួកគេចង់ស្វែងរក។ ឧទាហរណ៍ ៖ ជាធម្មតា បុរសចាប់យកអាជីពដូចជាកម្មករសំណង់ អ្នកបើកយន្តហោះ ជាងទុយោរទឹក ជាងភ្លើង មន្ត្រីកងកម្លាំងប្រដាប់អាវុធ អ្នកដឹកជញ្ជូន ម្ចាស់អាជីវកម្ម អ្នកវិទ្យាសាស្ត្រ វិស្វករ ជាដើម ចំណែកស្ត្រីជាទូទៅចាប់យកការងារទាក់ទងនឹងសេវាផ្ទាល់ខ្លួន ឧទាហរណ៍ ការថែទាំ ការបង្រៀន អ្នកកែសម្ផស្ស ការងារលេខាជាដើម។
- ទោះបីជាមានបទដ្ឋានទាំងនេះក៏ដោយ ក៏វាមិនមានន័យថា វាមិនអាចសម្រេចបានទេសម្រាប់ស្ត្រីក្នុងការធ្វើការងារក្នុងវិស័យការងារដែលបុរសធ្វើភាគច្រើន។ វាក៏មានលក្ខណៈដូចគ្នាដែរសម្រាប់បុរសក្នុងការធ្វើការងារដែលភាគច្រើនស្ត្រីជាអ្នកធ្វើ។
- នៅក្នុងពិភពលោកបច្ចុប្បន្ន ក្មេងស្រីកាន់តែច្រើនឡើងៗកំពុងឈានចូលទៅក្នុងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា គណិតវិទ្យា និងវិស្វកម្ម។ មានក្រុមហ៊ុនច្រើនដែរដែលបានដាក់ឱ្យអនុវត្តនូវពិធីសារផ្សេងៗដើម្បីលើកទឹកចិត្តឱ្យមានស្ត្រីកាន់តែច្រើនមកធ្វើការជាមួយខ្លួន។
- សម្រាប់បុគ្គលដែលមានភេទផ្សេង វាជារឿងត្រឹមត្រូវដែលមនុស្សម្នាក់មានការភាន់ច្រឡំ និងមិនអាចគិតបានភ្លាមៗពីបញ្ហានេះ។ រឿងនេះកើតឡើងដោយសារតែពួកគេប្រឈមមុខនឹងការរើសអើង និងស្លាកស្នាមទុយិស ដែលធ្វើឱ្យពួកគេជួបការលំបាកសូម្បីតែសិទ្ធិ ទទួលបានឱកាសអប់រំ និងការងារ។ ដូច្នេះ យេនឌ័រមានផលប៉ះពាល់លើមនុស្សគ្រប់រូប។

**🗝 គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- បន្ទាប់ពីផ្តល់ព័ត៌មាននេះឱ្យសិស្សហើយ លោកគ្រូ អ្នកគ្រូត្រូវទាញការយកចិត្តទុកដាក់របស់ពួកគេទៅរកការចងចាំទុកក្នុងចិត្តថាតើការកំណត់ពីយេនឌ័រនៅកន្លែងធ្វើការមានភាពស៊ីជម្រៅកម្រិតណា ហើយថាតើវាមិនគ្រាន់តែមានសារៈសំខាន់សម្រាប់ស្ត្រីក្នុងការធ្វើការដើម្បីរកប្រាក់ចំណូលទេ តែថែមទាំងទទួលបានការងារប្រកបដោយអត្ថន័យនៅកន្លែងធ្វើការដែលមានការយកចិត្តទុកដាក់ផ្នែកយេនឌ័រដូចម្តេច។

☞ សួរសំណួរដូចខាងក្រោម ៖

◈ តើចំណុចសំខាន់មួយចំនួនក្នុងចំណោមចំណុចសំខាន់នានាមានអ្វីខ្លះដែលប្អូនត្រូវស្វែងរកនៅកន្លែងធ្វើការដែលមានការលើកទឹកចិត្ត និងឱកាសជោគជ័យក្នុងអាជីព?

☞ រង់ចាំឱ្យពួកគេឆ្លើយ បន្ទាប់មកចែករំលែកចំណុចដូចខាងក្រោម ៖

– នៅពេលស្វែងរកអាជីព និងកន្លែងធ្វើការសមស្រប ត្រូវមើលលើចំណុចដូចខាងក្រោម ៖
  - តើមានបន្ទប់ទឹកសម្រាប់ស្ត្រីនៅកន្លែងធ្វើការងារដែរឬទេ?
  - តើមានច្បាប់លំហែមាតុភាពដែរឬទេ?
  - តើមានការផ្តល់ជូនអ្វីខ្លះសម្រាប់ការមើលថែទាំទារក?
  - តើស្ត្រីទទួលបានការគោរពនៅកន្លែងធ្វើការដែរឬទេ?
  - តើកន្លែងធ្វើការនេះស្ថិតនៅតំបន់មានសុវត្ថិភាពដែរឬទេ?
  - តើមានសេវាធ្វើដំណើរដែលគាំទ្រដល់តម្រូវការធ្វើដំណើរប្រចាំថ្ងៃដែរឬទេ?

☞ និយាយដោយសង្ខេបពីរបៀបដែលគេកំណត់ពីយេនឌ័រនៅក្នុងការងារតាមរយៈវិសមភាពនៃប្រាក់ឈ្នួលទូទាំងពិភពលោក នៅពេលដែលបុរស និងស្ត្រីមានគុណវុឌ្ឍិ និងមុខតំណែងការងារដូចគ្នា ប៉ុន្តែស្ត្រីទទួលបានប្រាក់ឈ្នួលទាបជាងបុរសដោយសារតែយេនឌ័ររបស់ពួកគេ។ ប្រាប់សិស្សថា នៅក្នុងប្រទេសកម្ពុជា វិសមភាពប្រាក់ឈ្នួលកើតមានចំពោះស្ត្រីក្នុងវិស័យ សាធារណៈ ឯកជន និងវិស័យក្រៅផ្លូវការ[2]។

☞ ចង្អុលទៅកាន់តារាង«ការពិតពីការងាររបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា» បន្ទាប់មកអានការពិតនីមួយៗ និងពន្យល់សិស្សពីចំណុចនោះដោយសង្ខេប។

**🗝 គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ដើម្បីពន្យល់ពីការពិតពី «ការងាររបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា» ដោយប្រើឯកសារថតចម្លងស្តីពី«ការពិតដែលបានពន្យល់ ៖ ការងាររបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា» (សូមមើលឯកសារអំណានទី៤ នៅក្នុង សំណុំឯកសារសម្រាប់គ្រូបង្រៀន)

☞ សរុបការពិភាក្សាដោយចែករំលែកចំណុចដូចខាងក្រោម ៖

[2] Das ២០១២ វិសមភាពប្រាក់ឈ្នួលក្នុងប្រទេសឥណ្ឌា សេដ្ឋកិច្ច និងនយោបាយប្រចាំសប្តាហ៍

- តើការងារអ្វីដែលសង្គមកំណត់ថា «សមស្រប» សម្រាប់ក្មេងស្រី និងស្ត្រី ហើយដែលកើតចេញពីឫសគល់នៃតួនាទី និងការទទួលខុសត្រូវផ្អែកយេនឌ័រដែលមានលក្ខណៈជាបទដ្ឋាន?
- គេផ្តល់ការងារឱ្យស្ត្រីដើម្បីរក្សាឋានានុក្រមរបស់បុរស និងធ្វើឱ្យស្ត្រីស្ថិតនៅក្រោមបង្គាប់ ជានិច្ច។ ការផ្តល់ឱ្យនេះធ្វើឱ្យមានគម្លាតច្រើនចំពោះគុណតម្លៃការងារដែលស្ត្រី និងបុរស ធ្វើ។ ដោយសារការផ្តល់ការងារ និងវិសមភាពប្រាក់ឈ្នួលដោយផ្អែកលើផ្នត់គំនិតយេនឌ័រ ការងាររបស់ស្ត្រី *(មិនថាមាន ឬគ្មានប្រាក់ឈ្នួល)*ជារឿយៗគេឱ្យតម្លៃទាបជាងការងារ របស់បុរស សូម្បីតែស្ត្រីកំពុងតែធ្វើការងារច្រើនដូចបុរសក៏ដោយ។ គេអាចតវ៉ាចំពោះគុណតម្លៃដែលបានកំណត់ជាមុននេះបានតែនៅពេលណាដែលបុគ្គលនានាចាប់ផ្តើមមានក្តីប្រាថ្នា ចំពោះការងារដែលពួកគេចង់ធ្វើទៅតាមជម្រើស និងមិនមែនទៅតាមការអនុវត្តតាមទម្លាប់របស់សង្គមនោះទេ។
- វាមានសារៈសំខាន់ក្នុងការចងចាំថា គ្មានការងារណាជាការងាររបស់បុរស ឬរបស់ស្ត្រីទេ។ ការងារគឺការងារ។ បុរសអាចធ្វើម្ហូបបានពូកែដូចស្ត្រីដែរ ហើយស្ត្រីក៏អាចប្តូរអំពូលភ្លើងបានយ៉ាងមានប្រសិទ្ធភាពដូចបុរសដែរ។
- ជានិច្ចកាលត្រូវចងចាំថា ក្នុងនាមប្អូនជាក្មេងស្រី..... ជាសិស្ស..... ជាអ្នកដឹកនាំនៅថ្ងៃអនាគតរបស់ពិភពលោក ប្អូនមិនត្រូវមានអារម្មណ៍ថាទទួលរងការដាក់កំហិតចំពោះបំណងប្រាថ្នា និងក្តីសុបិនរបស់ប្អូនសម្រាប់អាជីពមួយដោយសារការយល់ឃើញរបស់សង្គមដែលថាអ្វីដែល «សមស្រប» សម្រាប់ក្មេងស្រីឡើយ។ ភាពជាស្ត្រីភេទមិនគួរជាឧបសគ្គមួយក្នុងការសម្រេចបំណង ប្រាថ្នា និង ការរៀបចំផែនការសម្រាប់អនាគតរបស់ខ្លួនឡើយ។

☞ ប្រសិនបើមានពេល សុំឱ្យសិស្សស្ម័គ្រចិត្តចែករំលែកពីអ្វីដែលពួកគេបានរៀនពីជំពូកនេះ។




**កិច្ចការនៅផ្ទះ**

☞ មុនពេលសិស្សបំបែកគ្នាសូមលោកគ្រូអ្នកគ្រូចំណាយពេល៥នាទីពន្យល់កិច្ចការផ្ទះដល់ពួកគេ។

☞ ឱ្យសិស្សបើកសន្លឹកកិច្ចការរបស់គេនៅទំព័រទី៩២ និងទី៩៣ រួចអានការណែនាំ និងពន្យល់ពីអ្វីដែលពួកគេត្រូវធ្វើ។

☞ រំឭកសិស្សពីសារៈសំខាន់នៃការយកសន្លឹកកិច្ចការរបស់គេមកវិញនៅម៉ោងក្រោយ។

# សំណុំឯកសារសម្រាប់គ្រូបង្រៀន

ឯកសារអំណានទី២ ៖ តារាងគំរូ ៖ តើនរណាធ្វើកិច្ចការនេះ?

| តើនរណាធ្វើកិច្ចការនេះ? | | |
|---|---|---|
| ប្រភេទកិច្ចការ(ការងារ) |  |  |
| ដេរប៉ាក់ / កាត់ដេរ | | |
| ចម្អិនអាហារ | | |
| បោសសម្អាត / បោសជូត | | |
| បម្រើសេវាកម្មក្នុងភោជនីយដ្ឋាន | | |
| បោកគក់ / បោកអ៊ុត | | |
| បង្រៀនកូនៗ | | |

**សេចក្តីណែនាំ ៖**

- ថតចម្លងឯកសារទំព័រនេះមួយច្បាប់។ ប្រើប្រាស់វាជាឯកសារយោងពេលគូរតារាងនៅលើក្តារខៀន ឬប្រើប្រាស់សៀវភៅណែនាំ និងយោងលើទំព័រនេះ។
- គូរតារាងដែលមានកូឡោន៣ និង និងជួរដេក១ សម្រាប់ដាក់ចំណងជើង និងជួរដេកចំនួន៧ ផ្សេងទៀតនៅពីក្រោមដូចបង្ហាញខាងលើ។
- សរសេរ«តើនរណាធ្វើកិច្ចការនេះ?» នៅក្នុងជួរដេកសម្រាប់ចំណងជើង។
- សរសេរ និងគូររូបនៅក្នុងជួរដេកទី២ដូចរូបដែលបានបង្ហាញ។
- នៅក្នុងជួរឈរទី១សរសេរ ពាក្យ/ ឃ្លាដូចដែលបានបង្ហាញ។
- ត្រូវធានាថាអក្សរសរសេរឱ្យបានជិតល្អ ដែលសិស្សទាំងអស់គ្នាអាចមើលឃើញ។
- កូឡោនទី ២ និងទី៣ ត្រូវបំពេញក្នុងពេលធ្វើសកម្មភាពនេះ។

## ឯកសារអំណានទី៣ ៖ តារាងរឿងពិត ៖ ការងារស្ត្រីនៅក្នុងប្រទេសកម្ពុជា

| **ការពិតស្តីពីការងារស្ត្រីនៅក្នុងប្រទេសកម្ពុជា** |
|---|
| ការពិតទី១.<br>មានតែស្ត្រី ២៩% ប៉ុណ្ណោះនៅក្នុងប្រទេសកម្ពុជាដែលមានការងារ ឬ មុខតំណែងដែលមាន ប្រាក់ឈ្នួល។ អត្រានេះបានធ្លាក់ចុះពីខ្ពស់ជាង ៣៧% នៅឆ្នាំ ២០០៤-០៥ មក ២៩% នៅឆ្នាំ២០០៩-១០។ |
| ការពិតទី២.<br>កម្លាំងពលកម្មនារីនៅទីក្រុងមានកម្រិតទាបខ្លាំង គឺត្រឹមតែ ១៨.៥% បើធៀបជាមួយកម្លាំង ពលកម្មបុរសនៅទីក្រុងដែលមានដល់ ៧៥%។ |
| ការពិតទី៣.<br>អត្រានៃការចូលរួមក្នុងការងាររបស់ស្ត្រីមានកម្រិតទាប ព្រោះក្មេងស្រីត្រូវបានគេរើសអើង ហើយជារឿយៗ ត្រូវបានបដិសេធឱកាសក្នុងការសិក្សា និងរៀនសូត្រ។ |
| ការពិតទី៤.<br>ស្ត្រីទំនងជាធ្វើការនៅក្នុងវិស័យដែលមិនរៀបរយ ជាកន្លែងដែលមានការងារត្រូវការជំនាញទាប ដោយពុំមានទទួលផលប្រយោជន៍ ឬសិទ្ធិជាផ្លូវការច្រើនទេ។ |
| ការពិតទី៥.<br>តាមវប្បធម៌ ជារឿយៗ ការងាររបស់ស្ត្រីជាការងារមិនមានប្រាក់ឈ្នួលនេះដោយសារតែការ ងារភាគច្រើនគឺជាការងារនៅក្នុងគ្រួសារ។ |
| ការពិតទី៦.<br>ការងារមិនមានប្រាក់ឈ្នួលរបស់ស្ត្រីនៅទីក្រុងចូលរួមចំណែក ៣០០.០០០រៀល ក្នុងមួយខែនៃតម្លៃសេដ្ឋកិច្ចកម្ពុជា ទោះបីស្ត្រីមិនទទួលបានសំណងសម្រាប់ការងាររបស់ខ្លួនក៏ដោយ។ |

**សេចក្តីណែនាំ ៖**

- គូរតារាងដូចបង្ហាញខាងលើដាក់លើក្រដាសផ្ទាំងធំ។
- សរសេរចំណងជើងធំនៅកណ្តាលជួរដេកទី១។
- សរសេរឃ្លាសមស្របក្នុងជួរដេកនីមួយៗ ដោយមានការពិតទាំង ៦ ដូចបង្ហាញនៅក្នុងតារាងខាងលើ។
- ត្រូវធានាថាឃ្លា/ប្រយោគនីមួយសរសេរបានច្បាស់ល្អ។

| |
|---|
| – បិទតារាងនៅលើជញ្ជាំងក្នុងថ្នាក់រៀន។ ត្រូវធានាថាសិស្សទាំងអស់ មើលតារាងឃើញច្បាស់ល្អនៅពេលអនុវត្តសកម្មភាព។ |

**ឯកសារអំណានទី៤ ៖ ពន្យល់ការពិត ៖ ការងារស្ត្រីនៅក្នុងប្រទេសកម្ពុជា**

| |
|---|
| **ពន្យល់ពីការពិតទី១ និង ទី២** |
| មានតែស្ត្រី ២៥.៨% ប៉ុណ្ណោះនៅក្នុងប្រទេសរបស់យើង ដែលមានការងារ ឬមុខតំណែងដែលមានប្រាក់ឈ្នួលនៅក្នុងវិស័យកសិកម្មនៅជនបទ។ អត្រានៃការចូលរួមនៅទីក្រុងរបស់ស្ត្រីមានកម្រិតទាបត្រឹមតែ ១៨.៥% ប៉ុណ្ណោះ បើធៀបជាមួយអត្រានៃការចូលរួមនៅទីក្រុងរបស់បុរសដែលមានដល់ទៅ៧៤%។ |
| **ពន្យល់ពីការពិតទី៣** |
| អត្រានៃការចូលរួមការងាររបស់ស្ត្រីមានកម្រិតទាបដោយសារតែការរើសអើងដែលជារឿយៗបដិសេធមិនឱ្យពួកគេបានសិក្សា ឬរៀនសូត្រ។ កង្វះការអប់រំ និងមានជំនាញទាបធ្វើឱ្យស្ត្រីបាត់បង់អត្ថប្រយោជន៍បើធៀបជាមួយនឹងដៃគូដែលជាបុរសរបស់គេ។ ស្ត្រីដែលមានលទ្ធភាពពុះពារឧបសគ្គទាំងនេះបានជារឿយៗត្រូវតស៊ូនឹងការរឹតត្បិតផ្សេងៗនៃការមិនអនុញ្ញាតឱ្យចេញក្រៅដើម្បីធ្វើការងារ។ |
| **ពន្យល់ពីការពិតទី៤** |
| ស្ត្រីទំនងជាធ្វើការនៅក្នុងការងារក្រៅផ្លូវការនៅក្នុងវិស័យមិនរៀបរយច្រើនជាងបុរសដែលភាគច្រើនជាការងារប្រើជំនាញទាប ដោយមិនទទួលបានអត្ថប្រយោជន៍ និងសិទ្ធិស្របច្បាប់ច្រើន។ |
| **ពន្យល់ពីការពិតទី៥** |
| អ្វីដែលគេមើលឃើញថា «ជាការងារសមស្រប» សម្រាប់ស្ត្រីគឺសង្គមជាអ្នកកំណត់ ហើយកើតចេញពីឫសគល់នៃតួនាទីនិងទំនួលខុសត្រូវយេនឌ័រ។ គេកំណត់យ៉ាងដូច្នេះ ដើម្បីរក្សានូវឋានានុក្រមរបស់បុរស និងធ្វើឱ្យស្ត្រីនៅក្រោមបង្គាប់ជានិច្ច ដូច្នេះវាបង្កើតឱ្យមានគម្លាតចំពោះគុណតម្លៃការងារដែលស្ត្រី និងបុរសធ្វើ។ ដោយសារការរៀបចំការងារនិងវិសមភាពប្រាក់ឈ្នួលតាមផ្នត់គំនិតយេនឌ័រការងាររបស់ស្ត្រីជារឿយៗត្រូវបានគេឱ្យតម្លៃតិចជាងការងាររបស់បុរស។ គេអាចជម្នះចំណុចទាំងអស់នេះបាននៅពេលដែលកម្លាំងពលកម្មរបស់ស្ត្រីកើនឡើងកាន់តែច្រើន និងកាន់តែរឹងមាំ។ |

**ពន្យល់ពីការពិតទី ៦**

តាមវប្បធម៌ការងារក្នុងគ្រួសារដែលស្ត្រីធ្វើមិនមានប្រាក់ឈ្នួលទេ និងត្រូវបានគេយល់ឃើញថាស្ត្រីដែលនៅផ្ទះមិនធ្វើការទេ។ ប៉ុន្តែ ការវិភាគសេដ្ឋកិច្ចនៃការងាររបស់ស្ត្រីត្រូវបានវាស់វែង និងបង្ហាញថាវាមានសារៈសំខាន់។ គេប៉ាន់ប្រមាណថា ស្ត្រីគ្រប់រូបនៅក្នុងតំបន់ជនបទ និងទីក្រុង នៃប្រទេសកម្ពុជាចូលរួមចំណែកចំនួន ១,៣៥០រៀល ទៅក្នុងសេដ្ឋកិច្ចតាមរយៈការងារមិនមានប្រាក់ឈ្នួលរបស់ពួកគេក្នុងមួយខែៗ ហើយទឹកប្រាក់ដែលបានចូលរួមចំណែករបស់ស្ត្រីនៅទីក្រុងមានចំនួន ២,៧៥០រៀលសម្រាប់រឿងដូចគ្នានេះ។

**សេចក្តីណែនាំ ៖**

– ថតចម្លងឯកសារទំព័រនេះមួយច្បាប់។ ប្រើវាជាឯកសារយោងនៅពេលអនុវត្តសកម្មភាព ដើម្បីពន្យល់ពីការពិតដល់សិស្ស ឬប្រើប្រាស់សៀវភៅណែនាំ ដោយយោង លើទំព័រនេះប្រសិនបើចាំបាច់។

# មេរៀនទី២ ៖ ស្ត្រី និងការងារ

➲ **វត្ថុបំណងមេរៀន ៖** ដើម្បីយល់ពីសារៈសំខាន់នៃការងារដែលទទួលបានប្រាក់កម្រៃ។

🕘 **រយៈពេលនៃមេរៀន ៖** ៤៥ នាទី

✉ **សារសំខាន់ៗ ៖**

១. ការចូលរួមក្នុងការងារមានប្រាក់ឈ្នួលធ្វើឱ្យស្ត្រីមានលទ្ធភាពបង្កើនភាពជឿជាក់ និងឯករាជ្យភាព មានសិទ្ធិទទួលបានអំណាច និងធនធានកាន់តែប្រសើរ ព្រមទាំងបង្កើនសិទ្ធិធ្វើសេចក្តីសម្រេចចិត្តនៅក្នុងគ្រួសារ។

២. វាមានសារៈសំខាន់ដែលក្មេងស្រីមានក្តីប្រាថ្នាចង់មានអាជីព មានការទទួលស្គាល់លើការងារ និងមានប្រាក់ឈ្នួលរបស់ខ្លួនព្រមទាំងជម្នះបាននូវបទដ្ឋានបិតាធិបតេយ្យទាំងនៅក្នុងគ្រួសារ និងកន្លែងធ្វើការ។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ ៖**

- ☞ សម្រាប់គ្រូបង្រៀន៖ ក្រដាសផ្ទាំងធំមួយសន្លឹក ម៉ាស៊ីនថតចម្លង ក្រដាស A4 ចំនួន១សន្លឹក ក្តារខៀន ហ្វឺត ឬដីស ហ្វឺតលុបមិនជ្រះពណ៌ខ្មៅ២ដើម ស្កុត បន្ទាត់ និងកន្ត្រៃ។
- ☞ សម្រាប់សិស្ស៖ ក្រដាស A4 ចំនួន៤សន្លឹក និងសម្ភារៈសរសេរផ្សេងទៀត។

**ការរៀបចំទុកជាមុន ៖**

- ☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។
- ☞ ថតចម្លងឯកសារ «អត្ថប្រយោជន៍សម្រាប់ស្ត្រីដែលធ្វើការ» មួយច្បាប់ (សូមមើលឯកសារអំណានទី៥ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន) និងប្រើវាជាឯកសារយោងនៅពេលបង្កើតតារាងនៅលើក្តារខៀន។
- ☞ នៅលើក្រដាសផ្ទាំងធំបង្កើត «បញ្ជីស្ត្រីដែលមានមុខតំណែងវិជ្ជាជីវៈខ្ពស់» (សូមមើលឯកសារអំណានទី៦ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។
- ☞ បិទតារាងនោះនៅក្នុងថ្នាក់ លើជញ្ជាំងដែលបានកំណត់។
- ☞ ប្រមូលសម្ភារៈដែលត្រូវការផ្សេងៗទៀតទាំងអស់។
- ☞ សរសេរចំណងជើងមេរៀនលើក្តារខៀន។

**🗝 គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- រំឭកសិស្ស ឱ្យចុះវត្តមាននៅពេលពួកគេចូលថ្នាក់រៀន។
- ពិនិត្យមើលថាតើសិស្ស មានយកសន្លឹកកិច្ចការមកជាមួយដែរឬទេ។
- សួរពួកគេថាតើពួកគេបានធ្វើកិច្ចការនៅផ្ទះរបស់ខ្លួនឬទេ។
- ឱ្យពួកគេទុកសន្លឹកកិច្ចការរបស់ខ្លួននៅលើតុរបស់លោកគ្រូ អ្នកគ្រូ និងយកប្រដាប់ប្រដាសរសេរមុនពេលចូលរៀន។

## ២. ដំណើរការបង្រៀន

### សេចក្តីណែនាំ

☞ ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល «អារម្មណ៍» របស់សិស្សនៅក្នុងថ្នាក់ដោយ ឱ្យពួកគេប្រើដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតថាមពលរបស់ពួកគេ។

☞ អាន និងចង្អុលចំណងជើងមេរៀននៅលើក្ដារខៀន។ ឱ្យសិស្សទាយថាតើមេរៀនថ្ងៃនេះ នឹងរៀនពីអ្វី។ សុំឱ្យសិស្សស្ម័គ្រចិត្ត ២-៣នាក់ចែករំលែកពីគំនិតរបស់ពួកគេទៅកាន់ក្រុម។

☞ សួរសិស្សនូវសំណួរដូចខាងក្រោម ៖

- ◈ តើនៅក្នុងចិត្តប្អូនគិតឃើញអ្វីខ្លះនៅពេលដែលប្អូនគិតពីពាក្យ «ការងារ»?

☞ លើកទឹកចិត្តសិស្សឱ្យឆ្លើយនឹងសំណួរនេះ។ ទទួលយកចម្លើយទាំងអស់។

☞ សួរសំណួរដូចខាងក្រោម ៖

- ◈ តើប្អូនគិតថាវាមានសារៈសំខាន់ដែរឬទេដែលស្ត្រីត្រូវធ្វើការ មានការងារ ឬអាជីព?

☞ ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់ឆ្លើយសំណួរ។ ចម្លើយអាចរួមមានដូចខាងក្រោម ៖

- បាទ/ចាស វាជួយស្ត្រីឱ្យមានភាពម្ចាស់ការផ្នែកហិរញ្ញវត្ថុ មានជម្រើសកាន់តែច្រើន និងមានសេរីភាពកាន់តែប្រសើរ។
- វាអាស្រ័យលើតម្រូវការហិរញ្ញវត្ថុនៅក្នុងគ្រួសារ ឬផ្ទះ និងប្រសិនបើវាជាតម្រូវការសំខាន់នោះវាជាការត្រឹមត្រូវដែលស្ត្រីត្រូវធ្វើការងារ។
- ស្ត្រីគួរធ្វើការងាររហូតដល់ពួកគេមានកូន ហើយបន្ទាប់មកពួកគេគួរផ្តោតលើការចិញ្ចឹមកូន និងថែទាំគ្រួសារ។

☞ បែងចែកសិស្ស ទៅជា៤ក្រុមស្មើគ្នា។ ចែកក្រដាស A4 ដល់ក្រុមនីមួយៗ។

☞ ឱ្យក្រុមនីមួយៗពិភាក្សាចំណុចខាងក្រោមនៅក្នុងក្រុមនីមួយៗរបស់គេ ៖

- កំណត់ពីស្ត្រីម្នាក់ ឬច្រើននាក់នៅក្នុងគ្រួសាររបស់ប្អូន ឬសហគមន៍ដែលមានការងារ មានប្រាក់ឈ្នួល។ ឧទាហរណ៍ នរណាម្នាក់ដែលធ្វើការនៅក្នុងរោងចក្រ ឬមានអាជីវកម្មឯករាជ្យផ្ទាល់ខ្លួន។
- ពិភាក្សាពីបញ្ហាប្រឈមចំនួន២ដែលប្អូនគិតថា ស្ត្រីទាំងនេះអាចជួបប្រទះនៅពេលបំពេញការងាររបស់ខ្លួន។
- រៀបរាប់វិធីចំនួន៣ទៅ៥ចំណុចចំពោះការមានការងារដែលមានប្រាក់ឈ្នួល ឬអាជីវកម្មមានឥទ្ធិពលជាវិជ្ជមានលើជីវិតរបស់ស្ត្រីទាំងនោះ។
- សរសេរពីអត្ថប្រយោជន៍របស់ស្ត្រីដែលមានការងារមានប្រាក់ឈ្នួល *(ឱ្យសិស្សសរសេរពីអត្ថប្រយោជន៍នោះដាក់ក្នុងក្រដាស A4 របស់គេ)*។
- ប្រាប់សិស្សថា ពួកគេមានពេល១០នាទីដើម្បីធ្វើកិច្ចការនេះ។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- នៅក្នុងក្រុមធំ មិនត្រូវពិភាក្សាពីបញ្ហាប្រឈមដែលស្ត្រីធ្វើការជួបប្រទះឡើយ។
- ប្រសិនបើសិស្ស មានសំណួរ ឬមតិយោបល់ពីការលំបាកដែលស្ត្រីជួបប្រទះនៅពេលធ្វើការ ឬបញ្ហាប្រឈមផ្សេងៗដែលមានទាក់ទងនឹងការងារ សូមទាញការយកចិត្តទុកដាក់របស់គេមកលើការរៀនសូត្ររបស់គេនៅក្នុងម៉ូឌុល២ ៖ ប្រសិទ្ធភាពផ្ទាល់ខ្លួន និងការសិក្សាស្វែងយល់ ដែលពួកគេបានធ្វើទាក់ទងនឹងប្រធានបទផ្សេងៗដូចជា ការប្រាស្រ័យទាក់ទង ការចរចា និងការដោះស្រាយបញ្ហាវិញ។ រំឭកសិស្សថា ពួកគេបានរៀនពីរបៀបនៃការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពនៅក្នុងម៉ូឌុលទី២ ដោយត្រូវចងចាំជានិច្ចពីបរិបទ ពេលវេលា និងទីកន្លែង។
- លើកឧទាហរណ៍មួយដោយនិយាយថា «ប្រសិនបើស្ត្រីម្នាក់ជួបប្រទះនូវការជំទាស់ចំពោះជម្រើសរបស់ខ្លួនក្នុងការទទួលយកការងារមានប្រាក់ឈ្នួល នាងត្រូវប្រើជំនាញដែលបានរៀនពីទំនាក់ទំនងពីការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពនិងបញ្ជាក់ឱ្យបានច្បាស់ពីហេតុផលនៃការសម្រេចចិត្តរបស់នាង។ នាងក៏អាចចរចាដោយលើកឡើងពីឧទាហរណ៍របស់ស្ត្រីដែលនាងស្គាល់ ហើយដែលបានជ្រើសរើសជម្រើសដូចគ្នានេះ»។

### ៣. ការពង្រឹងចំណេះដឹង

☞ ឱ្យសិស្សម្នាក់មកពីក្រុមនីមួយៗបង្ហាញពីគំនិតរបស់ក្រុមខ្លួនស្តីពីអត្ថប្រយោជន៍របស់ស្ត្រីដែលមានការងារមានប្រាក់ឈ្នួល។

> **គន្លឹះសម្រាប់គ្រូបង្រៀន**
>
> លោកគ្រូ អ្នកគ្រូត្រូវ ៖
>
> - នៅពេលក្រុមនីមួយៗបានចែករំលែកគំនិតរបស់ខ្លួនហើយ សូមគូសសញ្ញា(✓)នៅក្បែរចំណុចមូលនៅលើតារាងដែលមានស្រាប់នៅលើក្តារខៀន ឬបន្ថែមទៅលើចំណុចនោះ។
> - ប្រសិនបើក្រុមមិនបានលើកឡើងនូវចម្លើយខ្លះដែលមាននៅលើតារាងទេ សួរបញ្ជាក់ពួកគេបន្ថែម។
> - មើលក្ដារឡានឈរទី២នៅក្នុងក្រដាសថតចម្លង។ វាផ្តល់ព័ត៌មានលម្អិតសម្រាប់ជាចំណុចយោងរបស់លោកគ្រូ អ្នកគ្រូ។

☞ បន្ទាប់ពីក្រុមទាំងអស់បានបញ្ចប់ការធ្វើបទបង្ហាញរួចហើយ អរគុណសិស្សចំពោះការចូលរួមចំណែករបស់គេ។

☞ ប្រាប់សិស្សដូចខាងក្រោម ៖

- ដូចដែលបានពិភាក្សានៅម៉ូឌុលមុនៗ *(ខ្លួនឯង និងប្រសិទ្ធភាពផ្ទាល់ខ្លួន)* ផ្នត់គំនិតយេនឌ័រ និងឥរិយាបថបិតាធិបតេយ្យ ជារឿយៗ មានឥទ្ធិពលនិងផលជះមួយផ្នែកធំដល់ជីវិតរបស់ក្មេងស្រីដោយរាប់បញ្ចូលទាំងការដើរហើរ និងអត្តសញ្ញាណដែរ។
- ដូចគ្នានេះដែរ ការរំពឹងទុករបស់សង្គមពីតួនាទីយេនឌ័រក៏បានកំណត់ពីរបៀបដែលយើងយល់ឃើញចំពោះការងារ និងប្រភេទការងារ ឬអាជីពដែលយើងជ្រើសរើសដូចដែលបានពិភាក្សានៅក្នុងមេរៀនមុន។

– កន្លែងធ្វើការ *(រួមជាមួយទីកន្លែងសាធារណៈ)* គឺជាកន្លែងដែលមានកំណត់ពីយេនឌ័រ។ កន្លែងធ្វើការតំណាងឱ្យការរកប្រាក់ និងជាទីកន្លែងដែលជាប្រពៃណីមានបុរសភាគច្រើនពង្រីកការគ្រប់គ្រងលើធនធាននៅក្នុងរចនាសម្ព័ន្ធបិតាធិបតេយ្យ។ តាមរយៈការរកការងារធ្វើ ស្ត្រីត្រូវប្រឈមផ្ទាល់ទៅនឹងបទដ្ឋានបិតាធិបតេយ្យដែលកំណត់ពីតួនាទី និងឱកាសរបស់ខ្លួននៅក្នុងបរិបទនៃគ្រួសារ។ ការផ្លាស់ប្តូរ ឬការជំទាស់ទៅនឹងបទដ្ឋាន ឬឥរិយាបថ ទាំងនោះអាចមានការលំបាក ប៉ុន្តែវាមិនមែនមានន័យថាវាមិនអាចធ្វើទៅបាននោះទេ។

☞ ស្ត្រីដែលចូលរួមធ្វើការងារដែលមានប្រាក់ឈ្នួល...តើវាផ្តល់អ្វីខ្លះដល់ពួកគេ?

- វាបង្កើនឱកាសឱ្យស្ត្រីចូលរួមក្នុងការធ្វើការសម្រេចចិត្តនៅក្នុងគ្រួសារ។
- វាអាចលើកទឹកចិត្តឱ្យមានភាពម្ចាស់ការផ្នែកហិរញ្ញវត្ថុ ឧទាហរណ៍ ៖ អាចជួយឱ្យស្ត្រីមានលទ្ធភាពស្មើគ្នាក្នុងការគ្រប់គ្រងធនធានក្នុងគ្រួសារ និងលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរចំពោះឥរិយាបថរបស់សមាជិកគ្រួសារចំពោះស្ត្រីឱ្យក្លាយជាសមាជិកដែលមានសមភាពជាងមុន។

☞ ការស្រាវជ្រាវក៏បង្ហាញដែរថា ម្តាយដែលមានការងារធ្វើមានសុខភាពផ្លូវចិត្តល្អប្រសើរជាង មានលទ្ធភាពកសាងទំនាក់ទំនងកាន់តែល្អនៅក្នុងគ្រួសារ និងបង្កើនប្រាក់ចំណូលក្នុងគ្រួសាររបស់គេ។ នៅពេលស្ត្រីរកប្រាក់ និងគ្រប់គ្រងប្រាក់របស់ខ្លួន ពួកគេអាច និងប្រហែលជាជ្រើសរើសការចំណាយប្រាក់នោះទៅលើសុខភាពរបស់ខ្លួនដែលតាមធម្មតាគេផ្តល់អាទិភាពតិចតួចនៅក្នុងតម្រូវការប្រចាំគ្រួសារ នៅពេលដែលបុរសជាអ្នកគ្រប់គ្រងថវិកា។ ជាមួយគ្នានេះដែរ បុរសដែលមានម្តាយជាអ្នកធ្វើការទំនងជាមានទំនោរទៅរកការចូលរួមចំណែកក្នុងការធ្វើកិច្ចការផ្ទះ និងចំណាយពេលវេលាច្រើនលើការថែទាំសមាជិកគ្រួសារ។

☞ ស្ត្រីកម្ពុជាកំពុងតែជម្នះនឹងផ្នត់គំនិត និងឥរិយាបថយេនឌ័រនៅកន្លែងធ្វើការដោយកំពុងតែអនុវត្តវិជ្ជាជីវៈបានយ៉ាងល្អដែលតាមទំនៀមទម្លាប់គេមើលឃើញវិជ្ជាជីវៈនោះថាជាការងារដែលបុរសភាគច្រើនជាអ្នកធ្វើ។ ឧទាហរណ៍រួមមាន ៖

- បច្ចុប្បន្ននេះ ស្ត្រីនៅក្នុងប្រទេសកម្ពុជាកំពុងឈានជើងចូលក្រុមហ៊ុនល្បីៗជាច្រើន ដែលជាងពាក់កណ្តាលនៃក្រុមហ៊ុនទាំងនោះស្ថិតក្នុងវិស័យហិរញ្ញវត្ថុ។ ពួកគេជាអ្នកដឹកនាំស្ថាប័នកំពូលមួយចំនួននៅក្នុងប្រទេសកម្ពុជា។

☞ ឧទាហរណ៍មួយទៀតគឺជាវិស័យអាកាសចរណ៍ឥណ្ឌាដែលផ្តល់តួនាទីវិជ្ជាជីវៈដល់ស្ត្រីច្រើនជាងគេដំបូង។ បច្ចុប្បន្ន អ្នកបើកយន្តហោះនៅក្នុងប្រទេសឥណ្ឌាមាន ១១.៧% (៥,១០០ នាក់) គឺជាស្ត្រី ធៀបទៅនិងអ្នកបើករយន្តហោះជាស្ត្រីនៅទូទាំងពិភពលោកចំនួន ៣%[3]។ សួរសំណួរដូចខាងក្រោម ៖

- តើប្អូនមានស្គាល់ស្ត្រីមកពីគ្រួសារ ឬសហគមន៍ផ្ទាល់របស់ប្អូនដែលបានឡើងតំណែងនៅកន្លែងធ្វើការដែរឬទេ? ឧទាហរណ៍ ៖ ថាតើប្អូនស្គាល់នរណាម្នាក់ដែលមានមុខតំណែងជាអ្នកគ្រប់គ្រង ឬប្រធាននៅក្នុងក្រុមហ៊ុនរបស់គាត់ ឬនរណាម្នាក់ដែលចាប់ផ្តើមបើកអាជីវកម្មផ្ទាល់ខ្លួនរបស់គាត់ និងមានអារម្មណ៍សប្បាយចិត្តជាមួយនឹងការងាររបស់គាត់។

---

[3] http://economictimes.indiatimes.com/industry/transportation/airlines-/-aviation/how-indias-women-pilots-are-breaking-the-gender-barrier-to-soar-high/articleshow/47952673.cms?utm_source=contentofinterest&utm_medium=text&utm_campaign=cppst

☞ ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់ឡើងឆ្លើយ។
☞ ចង្អុលនិងពិភាក្សាដោយសង្ខេបទៅលើតារាងដែលរៀបរាប់ពីស្ត្រីក្នុងមុខតំណែងវិជ្ជាជីវៈខ្ពស់[4]។
☞ សរុបសេចក្តីដោយចែករំលែកចំណុចដូចខាងក្រោម ៖
- សេដ្ឋកិច្ចរបស់ប្រទេសមួយនឹងមានប្រសិទ្ធផលបំផុត នៅពេលដែលពលរដ្ឋភាគច្រើនរបស់ខ្លួនអាចចូលរួមក្នុងកម្លាំងពលកម្ម ដែលមានន័យថាមនុស្សគ្រប់គ្នាដោយមិនគិតពីយេនឌ័ររបស់គេ មានសិទ្ធិទទួលបានឱកាសស្មើគ្នា និងអាចធ្វើការជ្រើសរើសដោយហ្មត់ចត់។
- ស្ត្រីដែលចេញទៅធ្វើការអាចមានន័យថាមានលទ្ធភាពទទួលបានអំណាច និងធនធានសម្រាប់ពួកគេដែលអាចនាំពួកគេទៅរកមុខតំណែងស្មើភាពកាន់តែច្រើនសម្រាប់ស្ត្រីនៅក្នុងសង្គម។
☞ ប្រសិនបើនៅមានពេល សរុបមេរៀនដោយប្អូកសរុបពីអ្វីដែលបានរៀនពីមេរៀននេះ។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖
- ធានាថា សិស្សទាំងអស់បានប្រគល់សន្លឹកកិច្ចការរបស់ពួកគេមុនពេលបំបែកគ្នា។

---
[4] សូមមើលព័ត៌មានបន្ថែមនៅផ្នែកចុងក្រោយនៃជំពូកនេះ។

# សំណុំឯកសារសម្រាប់គ្រូបង្រៀន



## ឯកសារអំណានទី៥ ៖ តារាងគំរូ ៖ អត្ថប្រយោជន៍នៃការងារសម្រាប់ស្ត្រី

| អត្ថប្រយោជន៍នៃការងារសម្រាប់ស្ត្រី | ពន្យល់ពីអត្ថប្រយោជន៍ |
|---|---|
| ភាពម្ចាស់ការផ្នែកហិរញ្ញវត្ថុ | – ការរកប្រាក់ចំណូលអាចមានន័យថា មានការគ្រប់គ្រងធនធានកាន់តែប្រសើរនៅក្នុងគ្រួសារ។ ឧទាហរណ៍ ស្ត្រីដែលចូលរួមក្នុងការងារមានប្រាក់ឈ្នួលអាចមានសិទ្ធិច្រើនក្នុងការនិយាយពីរបៀបចាយវាយប្រាក់របស់នាងនៅក្នុងគ្រួសារ ទាំងទៅលើការអប់រំ ឬសុខភាពរបស់កូន។<br>– គេអាចមើលឃើញថានាងជាអ្នកទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ និងបានផ្លាស់ប្តូរតួនាទីបែបប្រពៃណីដែលតាមធម្មតាគេកំណត់ថាជាតួនាទីរបស់បុរសក្នុងបរិបទគ្រួសាររបស់ឥណ្ឌា។ ឧទាហរណ៍ តាមធម្មតាគេមើលឃើញថាបុរសគឺជាអ្នករកប្រាក់ចំណូលសំខាន់នៅក្នុងគ្រួសារហេតុដូច្នេះហើយទើបគេមើលឃើញថាគាត់ជាអ្នកទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុនៅក្នុងគ្រួសារ។ នៅពេលស្ត្រីធ្វើការងារមានប្រាក់ឈ្នួល ពួកគេអាចបំបែកតួនាទីដែលបានកំណត់សម្រាប់ពួកគេ ហើយហេតុដូច្នេះហើយទើបពួកគេទទួលបានទំនុកចិត្ត និងការគោរពខ្លួនឯងកាន់តែច្រើន។ |
| ការចរចា និងអំណាចធ្វើការសម្រេចចិត្តកាន់តែប្រសើរនៅក្នុងគ្រួសារ | – សិទ្ធិប្រើប្រាស់ធនធានភាគច្រើនលើកកម្ពស់ដល់ការជឿជាក់របស់មនុស្សម្នាក់ក្នុងការបង្ហាញពីគំនិតរបស់ខ្លួន។ ការធ្វើការនៅកន្លែងធ្វើការផ្នែកវិជ្ជាជីវៈក៏បណ្តុះគុណភាពនៃការងារជាក្រុម ការសម្រេចចិត្តសំខាន់ៗ និងភាពជាម្ចាស់ផងដែរ។ នៅក្នុងគ្រួសារ គុណសម្បត្តិទាំងនេះនឹងជួយស្ត្រីឱ្យចែករំលែកទស្សនៈរបស់ខ្លួន និងធ្វើការជ្រើសរើសកាន់តែហ្មត់ចត់ថែមទៀតចំពោះទំនាក់ទំនងផ្ទាល់ខ្លួនរបស់គេ។ |
| ការគោរព និងសេចក្តីថ្លៃថ្នូរកាន់តែប្រសើរ | – ភាពជឿជាក់របស់ស្ត្រីក៏ជួយពួកគេឱ្យទទួលបានការគោរពពីមិត្តភក្តិគ្រួសារ និងមនុស្សដែលគេមានទំនាក់ទំនងជាមួយនៅពេលធ្វើការ។ |
| ការកើនឡើងនៃសេរីភាពក្នុងការធ្វើដំណើរ | – ជារឿយៗ គេរឹតត្បិតស្ត្រីមិនឱ្យធ្វើដំណើរទៅកាន់ទីសាធារណៈផ្សេងៗទេ ដោយសារតែការទទួលខុសត្រូវនៅក្នុងគ្រួសារជាពិសេស ដូចជាការទៅផ្សារទិញបន្លែ ការទៅយកកូនពីសាលារៀនជាដើម។ ប៉ុន្តែ សម្រាប់ស្ត្រី |

| | |
|---|---|
| | ដែលធ្វើការងារមានប្រាក់ឈ្នួលអាចប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈ ឬឯកជនជាមធ្យោបាយដើម្បីធ្វើដំណើរទៅការិយាល័យ ឬកន្លែងធ្វើការ។ |
| **ការកើនឡើងនូវភាពជឿជាក់** | – នៅកន្លែងធ្វើការ ទំនួលខុសត្រូវ និងភារកិច្ចវិជ្ជាជីវៈដែលត្រូវប្រកាន់ខ្ជាប់ និងត្រូវបំពេញឱ្យបានជោគជ័យបញ្ជាក់ពីការជឿជាក់របស់ខ្លួន។ ភាពនៃការគោរពខ្លួនឯងដែលស្ត្រីអាចទទួលបានពីការងារនេះមានតួនាទីមួយក្នុងការអះអាងពីការកើនឡើងនៃភាពជឿជាក់និងការពឹងផ្អែកលើខ្លួនឯង។ |
| **ការទំនាក់ទំនងសង្គមនៅក្រៅផ្ទះ និងសហគមន៍** | – កន្លែងធ្វើការផ្តល់ឱកាសដើម្បីបង្កើតទំនាក់ទំនងក្រៅផ្លូវការជាមួយមិត្តរួមការងារ និងមិត្តភក្តិនៅក្នុងដំណើរដ៏វែងឆ្ងាយ។ ដោយសារវាគឺជាក្រុមមនុស្សចម្រុះ ស្ត្រីនឹងជួបមនុស្សជាច្រើនដែលបង្កើនទំនាក់ទំនងក្នុងរង្វង់សង្គមរបស់គេ។ |
| **គោលបំណង និងផ្នែកមួយផ្សេងទៀតនៃអត្តសញ្ញាណរបស់ស្ត្រី** | – ការជឿជាក់ និងការគោរពខ្លួនឯងដែលស្ត្រីទទួលបានពីការងារមានប្រាក់ឈ្នួលមានឥទ្ធិពលជាវិជ្ជមាននៅក្នុងពេលវេលាភាគច្រើន។ វាមានសារៈសំខាន់ដោយសារស្ត្រីកំណត់ខ្លួនឯងថាជាមនុស្សម្នាក់ដែលអ្នកដទៃជឿទុកចិត្តក្នុងការសម្រេចចិត្ត និងដែលអាចគាំទ្រមិត្តរួមការងាររបស់ខ្លួន ហើយក៏ជាអ្នកដែលអាចធ្វើការងារដែលមានក្នុងដៃបានជោគជ័យដែរ។ |

**សេចក្តីណែនាំ ៖**

- គូរតារាងមួយដែលមានបង្ហាញកូឡោនទី១ និងជួរដេកចំនួន៨។
- សរសេរចំណងជើងដូចដែលមាននៅក្នុងជួរដេកទី១ កូឡោនទី១។
- សរសេរឃ្លា / ប្រយោគដែលគេផ្តល់ឱ្យនៅក្នុងជួរដេកទាំង ៨ ក្នុងកូឡោនទី១។
- ថតចម្លងទំព័រនេះមួយច្បាប់ដើម្បីប្រើជាឯកសារយោងដើម្បីពន្យល់ពីអត្ថប្រយោជន៍នៅពេលអនុវត្តសកម្មភាពនេះ។

ឯកសារអំណានទី៦ ៖ តារាងគំរូ ៖ ស្ត្រីកម្ពុជានៅក្នុងមុខតំណែងវិជ្ជាជីវៈខ្ពស់

| ឈ្មោះ | ការចាត់តាំង(តួនាទី) | ស្ថាប័ន |
|---|---|---|
| លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី | ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច |
| ជំទាវ វេជ្ជ. អ៊ឹង កន្ថាផាវី | រដ្ឋមន្ត្រី | ក្រសួងកិច្ចការនារី |
| លោកជំទាវ គឹម សេដ្ឋានី | រដ្ឋលេខាធិការ | ក្រសួងអប់រំ យុវជន និងកីឡា |
| លោកជំទាវ ......... | អនុរដ្ឋលេខាធិការ | ក្រសួងអប់រំ យុវជន និងកីឡា |
| លោកស្រី ........ | ប្រធាននាយកដ្ឋាន | សុខភាពសិក្សា (ក្រសួង អ.យ.ក) |
| លោកស្រី ........ | ប្រធាននាយកដ្ឋាន | .... (ក្រសួង អ.យ.ក) |
| លោកជំទាវ មិថុនា ភួងថង | អភិបាលនៃអគ្គណៈអភិបាល | ខេត្តកោះកុង |
| លោកជំទាវ ប្បាន ស្រីមុំ | អភិបាលនៃអគ្គណៈអភិបាល | ខេត្តប៉ៃលិន |
| លោកស្រី ចក់ សុភាព | នាយិកាប្រតិបត្តិ | អង្គការមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| លោកស្រី ចាន់ រ៉ាមី | នាយិកាប្រតិបត្តិ | អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន |

សេចក្តីណែនាំ ៖

- ប្រើក្រដាសផ្ទាំងធំដើម្បីបង្កើតតារាងដូចបង្ហាញខាងលើ។
- តារាងត្រូវមាន៣កូឡោន និងជួរដេកចំនួន១៦។
- សរសេរចំណងជើងនៅក្នុងជួរដេកទី១ក្នុងកូឡោននីមួយៗដូចបង្ហាញខាងលើ។
- បំពេញឃ្លា ឬប្រយោគដែលសមស្របក្នុងជួរដេក និងកូឡោននីមួយៗ ដូចដែលគេបានផ្តល់ឱ្យនៅក្នុងតារាងខាងលើ។ ត្រូវសរសេរឃ្លា ឬប្រយោគឱ្យបានច្បាស់ល្អ។
- ទុកជួរដេកមួយចំនួនឱ្យទំនេរដើម្បីឱ្យសិស្ស ផ្តល់ឧទាហរណ៍ ពីស្ត្រីនៅក្នុងជីវិតផ្ទាល់របស់ពួកគេដែលពួកគេជឿថាទទួលជោគជ័យក្នុងវិជ្ជាជីវៈ។
- បិទតារាងនៅលើជញ្ជាំងក្នុងថ្នាក់រៀន។ ត្រូវធានា សិស្សទាំងអស់អាចមើលឃើញតារាងច្បាស់នៅពេលអនុវត្តសកម្មភាព។

# ជំពូកទី២ ៖ ការរៀបចំផែនទីស្តីពីបំណងប្រាថ្នា និងការកំណត់គោលដៅ




**ទិដ្ឋភាពទូទៅ**

ម៉ូឌុលទី៣ ៖ ជំពូកទី២ មានគោលដៅជួយសិស្សពង្រឹងការយល់ដឹងពីសារៈសំខាន់នៃការកំណត់ពីការចាប់អារម្មណ៍ និងបំណងប្រាថ្នាផ្ទាល់របស់ខ្លួន បន្ទាប់មកអនុវត្តជំហានជាក់លាក់ឆ្ពោះទៅរកការកំណត់គោលដៅតាមទិសដៅនោះ។

ជារឿយៗ ក្មេងស្រីត្រូវពុះពារឧបសគ្គជាប្រចាំដើម្បីមានលទ្ធភាពធ្វើឱ្យមានតុល្យភាពចំពោះការទទួលខុសត្រូវនៅក្នុងផ្ទះ និងការងារសាលារៀន។ ពេលចប់ម៉ោងរៀនក្មេងស្រីមួយចំនួនក៏អាចចូលរួមក្នុងសកម្មភាពនៃកម្មវិធីសិក្សាបំពេញបន្ថែមផ្សេងទៀត ឬធ្វើការងារក្រៅម៉ោងនៅក្រៅផ្ទះរបស់ពួកគេ។ ដូច្នេះ នៅក្នុងពេលកំពុងឆ្លើយតបទៅនឹងតម្រូវការចំពោះមុខនៃជីវិតប្រចាំថ្ងៃ ក្មេងស្រីមានពេលវេលាផ្ទាល់ខ្លួនតិចតួចបំផុតសម្រាប់ខ្លួនឯង។

ជំពូកនេះធ្វើឱ្យសិស្សមានលទ្ធភាពយល់ពីរបៀបកំណត់គោលដៅដែលមានលក្ខណៈជាក់លាក់ ពិតប្រាកដ និងអាចសម្រេចបាន និងរបៀបដែលពួកគេអាចគិត និងធ្វើការឆ្ពោះទៅរកការសម្រេចបានគោលដៅរបស់ខ្លួន។

**រយៈពេលមេរៀន ៖ ១ ម៉ោង ៣០ នាទី**

**ចំនួនលំនាំបង្រៀន ៖ ២**

| **វត្ថុបំណង ៖** |
|---|
| ១. ដើម្បីមានលទ្ធភាពគិត និងកំណត់ពីចំណាប់អារម្មណ៍ និងបំណងប្រាថ្នាផ្ទាល់របស់ខ្លួន។ |
| ២. ដើម្បីយល់ថាតើគោលដៅជាអ្វី និងរបៀបកំណត់គោលដៅទាំងនោះ។ |

# មេរៀនទី៣ ៖ ខ្ញុំប្រាថ្នាចង់បាន

➡ **វត្ថុបំណងមេរៀន ៖**

- ដើម្បីលើកទឹកចិត្តសិស្ស ឱ្យបែងចែកឱ្យដាច់ពីគ្នារវាងការចាប់អារម្មណ៍ និងបំណងប្រាថ្នា ព្រមទាំងជួយពួកគេឱ្យកំណត់ពីជំនាញ(បំណិន)ជាលក្ខណៈបុគ្គលម្នាក់ៗដើម្បីរៀបចំផែនទីបង្ហាញផ្លូវសម្រាប់គោលដៅផ្ទាល់ខ្លួន។
- កំណត់ធនធាន និងជម្រើសជាក់ស្តែងដែលអាចអនុវត្តបានក្នុងការរៀបចំគោលដៅ និងបំណងប្រាថ្នាសម្រាប់អាជីពរបស់ខ្លួន។

🕘 **រយៈពេលមេរៀន ៖** ៤៥ នាទី

✉ **សារសំខាន់ៗ ៖**

១. សិស្សយល់ពីសារៈសំខាន់នៃបំណងប្រាថ្នា និងធនធានដែលពួកគេត្រូវការដើម្បីសម្រេចក្តីសុបិនរបស់ខ្លួន។

២. សិស្សចាប់ផ្តើមរៀបចំផែនទីស្តីពីចំណាប់អារម្មណ៍ និងជំនាញ(បំណិន)របស់ពួកគេដើម្បីជួយពួកគេកំណត់ពីគោលដៅរបស់គេនៅក្នុងលំហាត់ខាងមុខ។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ ៖**

☞ សម្រាប់គ្រូបង្រៀន ៖ ក្រដាសផ្ទាំងធំចំនួន៣សន្លឹក ក្តារខៀន ហ្វឺត ឬដីស ហ្វឺតលុបមិនជ្រះ២ដើម និងស្កុត។

☞ សម្រាប់សិស្ស ៖ សន្លឹកកិច្ចការ កិច្ចការផ្ទះទំព័រទី៩៥។

**ការរៀបចំទុកជាមុន ៖**

☞ អានទិដ្ឋភាពទូទៅរបស់ម៉ូឌុលទី៣ ៖ ជំពូកទី២ «ការរៀបចំផែនទីស្តីពីបំណងប្រាថ្នា និងការកំណត់គោលដៅ»។

☞ អាន និងយល់ពីលំនាំបង្រៀនឱ្យបានច្បាស់។

☞ សរសេររឿងចំនួន៣លើក្រដាសផ្ទាំងធំដាច់ដោយឡែកពីគ្នា (សូមមើលឯកសារអំណានទី៧នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។

☞ ប្រមូលសម្ភារៈដែលចាំបាច់ទាំងអស់ផ្សេងៗទៀត។

☞ សរសេរចំណងជើងមេរៀននៅលើក្តារខៀន។

🗝 **គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- រំឭកសិស្ស ឱ្យចុះវត្តមាន នៅពេលពួកគេចូលក្នុងថ្នាក់រៀន។
- ឱ្យសិស្សម្នាក់ៗយកសន្លឹកកិច្ចការរបស់ពួកគេ និងប្រដាប់ប្រដាសរសេរមុនពេលរៀន។

## ២. វិធីសាស្ត្របង្រៀន

**សេចក្ដីណែនាំ**

- ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល «អារម្មណ៍» របស់គេនៅក្នុងថ្នាក់ដោយឱ្យសិស្សប្រើដៃដើម្បីបង្ហាញពីកម្រិតថាមពលរបស់គេ។
- ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់សង្ខេបពីអ្វីដែលពួកគេបានរៀននៅម៉ោងមុន។
- ណែនាំសិស្សពីជំពូកទី២ នៃម៉ូឌុលទី៣។
- អាន និងចង្អុលចំណងជើងមេរៀននៅលើក្ដារខៀន។ ឱ្យសិស្សទាយថាតើមេរៀនថ្ងៃនេះនឹងរៀនពីអ្វី។ ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់ចែករំលែកគំនិតរបស់ពួកគេជាមួយក្រុម។
- ប្រាប់ពួកគេថា មេរៀននៅថ្ងៃនេះនឹងណែនាំពួកគេពីមនុស្ស៣នាក់តាមរយៈសាច់រឿង៣ដាច់ដោយឡែកពីគ្នា។
- អានរឿងទី១ឱ្យឮៗ(សូមមើលឯកសារអំណានទី៧នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។ ឱ្យសិស្សបំពេញចន្លោះទទេ។
- អនុវត្តដំណើរការដូចគ្នាឡើងវិញសម្រាប់សាច់រឿងទី ២ និងទី ៣។

🗝 **គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ធ្វើឱ្យសកម្មភាពនេះមានទំនាក់ទំនងគ្នា។ ឱ្យសិស្សស្ម័គ្រចិត្តម្នាក់បំពេញចន្លោះទទេដោយពិភាក្សាជាមួយសិស្សផ្សេងទៀត។
- លើកទឹកចិត្តសិស្ស ឱ្យរកពាក្យផ្សេងៗដើម្បីបំពេញចន្លោះទទេសម្រាប់សាច់រឿងទាំង៣

## ៣.ការពង្រឹងចំណេះដឹង

**ចំណុចសម្រាប់ការពិភាក្សា**

- សួរសំណួរដូចខាងក្រោម ៖
  - តើប្អូនសម្រេចចិត្តបំពេញពាក្យដើម្បីបញ្ចប់សាច់រឿងទាំង៣យ៉ាងដូចម្ដេច?
  - សរសេរចម្លើយរបស់គេដាក់នៅលើក្ដារខៀន។

☞ ចែករំលែកចំណុចដូចខាងក្រោម ៖

- ជាញឹកញាប់បំផុត បំណងប្រាថ្នារបស់យើងកើតមានឡើងទៅតាមប្រភេទនៃជម្រើសផ្សេងៗដែលយើងមើលឃើញនៅជុំវិញខ្លួនយើង។
- យើងទទួលរងឥទ្ធិពលដោយសារការរំពឹងទុកដែលយើងត្រូវបំពេញនៅពេលធ្វើការសម្រេចចិត្តពីអ្វីដែលខ្លួនយើងប្រាថ្នាចង់បាន (ក្លាយជាអ្វីមួយ)។
- ការណ៍នេះនាំឱ្យមានការយល់មិនច្បាស់លាស់មួយពីជម្រើស និងបំណងប្រាថ្នារបស់ខ្លួន។

☞ សួរសំណួរដូចខាងក្រោម ៖

◈ តើប្អូនគិតថាផ្នែកខ្លះនៅក្នុងរឿងណាមួយនៃរឿងទាំង៣មានភាពមិនប្រាកដនិយមដែរឬទេ?

◈ តើប្អូនស្គាល់នរណាម្នាក់នៅក្នុងជីវិតរបស់ប្អូនដែលមានបំណងប្រាថ្នា «គ្មានភាពប្រាកដនិយម» ដែរឬទេ?

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកចំណុចដូចខាងក្រោម ៖

- មានពេលវេលាជាច្រើនដែលកម្លាំងជម្រុញខាងក្រៅទៅលើបំណងប្រាថ្នារបស់បុគ្គលម្នាក់ៗកើតចេញពីបុគ្គលដែលមានឥទ្ធិពលដែលរស់នៅជុំវិញយើង។ ឧទាហរណ៍ ៖ ក្មេងស្រីនិងក្មេងប្រុសវ័យជំទង់ជាច្រើននាក់សុបិនចង់ក្លាយជាតារាសម្ដែងពីព្រោះជីវិតរបស់តួអង្គដែលពួកគេចូលចិត្តបានបំផុសគំនិតរបស់ពួកគេ។ ស្រដៀងគ្នានេះដែរ អ្នកខ្លះប្រហែលជាប្រាថ្នាចង់ធ្វើជាគ្រូបង្រៀន ព្រោះពួកគេចំណាយពេលជាអតិបរិមាជាមួយគ្រូបង្រៀន។
- យើងត្រូវដឹង និងយល់ពីលទ្ធភាពនៃធនធានរបស់យើង ឬលទ្ធភាពនៃការបង្កើតនិងការទទួលបានធនធានទាំងនោះ ដើម្បីគាំទ្រនិងសម្រេចតាមគន្លងអាជីពរបស់យើង។
- វិជ្ជាជីវៈនីមួយៗតម្រូវឱ្យមនុស្សមានជំនាញ(បំណិន)សំខាន់ៗ និងមានទេពកោសល្យដើម្បីសម្រេចបានក្នុងវិស័យណាមួយ។ ដូច្នេះហើយ វាមានសារៈសំខាន់ណាស់ក្នុងការបែងចែកភាពខុសគ្នារវាងក្ដីសុបិន និងការពិត និងស្វែងរកវិធីដែលសមស្របបំផុតដើម្បីឆ្ពោះទៅមុខ។

☞ សួរសំណួរដូចខាងក្រោម ៖

◈ តើប្អូនយល់ពាក្យ «បំណងប្រាថ្នា» មានន័យយ៉ាងដូចម្ដេច?

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកចំណុចដូចខាងក្រោម ៖

- វាជានិន្នាការរបស់មនុស្សទូទៅក្នុងការប្រាថ្នាចង់បានអ្វីមួយ និងស្រមៃពីការចង់បាននោះជាញឹកញាប់ជាងរបស់ដែលពាក់ព័ន្ធណាមួយផ្សេងទៀត។ ពួកយើងមួយចំនួនក៏មានបុគ្គលគំរូដែលមានឥទ្ធិពលនៅក្នុងប្រភេទនៃចំណុចនានាដែលគេប្រាថ្នាចង់បានដែរ។
- ជារឿយៗ ស្ត្រីខិតខំតស៊ូក្នុងការបង្ហាញពីក្ដីសុបិនផ្ទាល់ខ្លួន និងវិជ្ជាជីវៈរបស់ពួកគេ។ យោងតាមការសិក្សាស្រាវជ្រាវមួយដែលធ្វើឡើងដោយធនាគារពិភពលោកក្នុងឆ្នាំ២០១២ បុរស

៥៥% បាននិយាយថាស្ត្រីគួររួមបញ្ចូលតួនាទីក្នុងផ្ទះរបស់ពួកគេជាមួយនឹងការរកប្រាក់ដែរ។[5] ការរំពឹងទុក និងការកំណត់តួនាទីទាំងនេះសម្រាប់ស្ត្រីបានកំណត់លើក្តីសុបិន និងជម្រើសរបស់គេ។

– ដូចដែលយើងបានយល់ពីមេរៀនកន្លងមក ជារឿយៗ យេនឌ័រ និងអំណាចវាយតម្លៃទាបលើការចូលរួមចំណែករបស់ស្ត្រីក្នុងផ្នែកសេដ្ឋកិច្ច។ វាមានសារៈសំខាន់ដែលត្រូវទទួលស្គាល់ថាក្នុងនាមជាស្ត្រី និងក្មេងស្រី យើងពិតជាមានតួនាទីកាន់តែធំទូលាយមួយក្នុងការសិក្សាស្វែងយល់ពីខ្លួនយើង ហើយនៅក្នុងដំណើរការនេះយើងត្រូវតែធ្វើជាអ្នកសម្រេចចិត្តពី ជម្រើសនៅក្នុងជីវិតផ្ទាល់របស់យើង។

☞ សួរសំណួរដូចខាងក្រោម ៖

◈ តើចំណុចអ្វីខ្លះដែលប្អូនត្រូវចងចាំក្នុងចិត្តនៅពេលប្អូនរៀបចំខ្លួនសម្រាប់ធ្វើការងារ?

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកចំណុចដូចខាងក្រោម ៖

– មានចំណុចចំនួន៣ ដែលប្អូនត្រូវចងចាំ ៖

**១. ចំណាប់អារម្មណ៍ ២. សមត្ថភាព ៣. ជម្រើសអាជីព**




– វាមានសារៈសំខាន់ណាស់ក្នុងការចាត់ចំណាត់ថ្នាក់បំណងប្រាថ្នាអាជីពរបស់ប្អូនទៅតាមការកំណត់ទាំងនេះដើម្បីធានាថាបំណងប្រាថ្នាទាំងនោះអាចអនុវត្តនិងសម្រេចបាន។ ជាផ្នែកមួយនៃកម្មវិធីសិក្សា សិស្សនឹងអនុវត្តលំហាត់មួយស្តីពីការកំណត់គោលដៅ និងការអនុវត្តការសម្រេចចិត្ត។

☞ ប្រសិនបើមានពេល សរុបមេរៀនដោយសរុបនូវអ្វីដែលបានរៀនពីមេរៀននេះ។




**កិច្ចការផ្ទះ**

☞ មុនពេលសិស្សបំបែកគ្នា ចូរចំណាយពេល៥នាទីដើម្បីពន្យល់ពីកិច្ចការផ្ទះដល់ពួកគេ។

☞ ឱ្យសិស្សបើកសន្លឹកកិច្ចការទំព័រទី៩៥-៩៦។

☞ អានសេចក្តីណែនាំ បន្ទាប់មកពន្យល់ពីអ្វីដែលសិស្សត្រូវធ្វើ។

☞ រំឭកសិស្សពីសារៈសំខាន់នៃការយកសន្លឹកកិច្ចការរបស់ខ្លួនមករៀននៅម៉ោងក្រោយ។

[5] http://siteresources.worldbank.org/INTWDR2012/Resources/7778105-1299699968583/7786210-1316090663409/Spread-3.pdf



# សំណុំឯកសារសម្រាប់គ្រូបង្រៀន

## ឯកសារអំណានទី៧ ៖ តារាងរឿងគំរូ

*តារាងទី១*

| រឿងទី១ |
|---|
| ___________ មានប្អូនស្រី២នាក់ និងបងប្រុសម្នាក់។ ___________ ស្រឡាញ់ការសិក្សា និងចូលរៀនរៀងរាល់ថ្ងៃ។ ___________ ចូលរៀនថ្នាក់របាំក្នុងតំបន់។ ថ្ងៃមួយ ___________ បានចូលរួមពិធីមង្គលការនៅក្នុងគ្រួសារមួយដែល ___________ ត្រូវបានគេសួរថា «តើប្អូនចង់ធ្វើអ្វីនៅថ្ងៃអនាគត? » ___________ បានឆ្លើយថា «ខ្ញុំមិនដឹងទេ» ។ ___________ បានសម្តែងរបាំនៅក្នុងពិធីមង្គលការនោះ។ គ្រប់គ្នារីករាយនិងពេញចិត្តក្នុងការមើលការសម្តែងនោះ។ *(ត្រឡប់តារាងនេះទៅម្ខាងទៀត។ សរសេររឿងនេះឡើងវិញ។ បំពេញក្នុងចន្លោះ ដោយប្រើឈ្មោះ រីណា)* |

*តារាងទី២*

| រឿងទី២ |
|---|
| ___________ គឺជាសិស្សដែលខំប្រឹងរៀន។ ___________ តែងតែទទួលបានពិន្ទុខ្ពស់ជាងគេរាល់ការប្រឡងនៅក្នុងថ្នាក់។ ប្អូនមិនដែលឃើញ ___________ នៅលេងលើដងផ្លូវជាមួយមិត្តភក្តិនោះទេ។ ___________ ចង់ក្លាយជាវិស្វករសំណង់ស៊ីវិល។ *(ត្រឡប់តារាងនេះទៅម្ខាងទៀត។ សរសេររឿងនេះឡើងវិញ។ បំពេញក្នុងចន្លោះទទេដោយប្រើឈ្មោះស៊ីណា)* |

*តារាងទី៣*

| រឿងទី៣ |
|---|
| ___________ ចូលចិត្តប្រដាល់។ ___________ ក៏ធ្លាប់បានឈ្នះការប្រកួតថ្នាក់រដ្ឋមួយចំនួន។ ___________ ចង់កសាងអាជីពប្រដាល់។ ___________ នឹងដាក់ពាក្យសុំអាហារូបករណ៍ដើម្បីសុំប្រាក់ឧបត្ថម្ភដល់ការសិក្សា។ *(ត្រឡប់តារាងនេះទៅម្ខាងទៀត។ សរសេររឿងនេះឡើងវិញ។ បំពេញក្នុងចន្លោះទទេដោយប្រើឈ្មោះរតនា)* |

**សេចក្តីណែនាំ ៖**

- បង្កើតតារាងរឿងចំនួន៣។
- សរសេររឿងមួយនៅលើតារាងនីមួយៗ។
- នៅផ្នែកម្ខាងនៃតារាងនីមួយៗ ចូរសរសេរឃ្លា ឬប្រយោគដែលមានទាំងចន្លោះទទេដូចមាននៅខាងលើ។
- នៅផ្នែកម្ខាងទៀតនៃតារាងនីមួយៗ ចូរសរសេររឿងឡើងវិញដោយបំពេញឈ្មោះរបស់មនុស្សនៅក្នុងចន្លោះ ដូចដែលបានណែនាំនៅក្នុងរឿងនីមួយៗ។
- បិទតារាងរឿងទាំង៣នៅក្នុងថ្នាក់។ ធានាថាផ្នែកដែលមានចន្លោះទទេគឺជាអ្វីដែលសិស្សអាចមើលឃើញ។
- សិស្សត្រូវបំពេញចន្លោះនៅលើតារាងសាច់រឿងនីមួយៗនៅពេលអនុវត្តសកម្មភាព។

# មេរៀនទី៤ ៖ គោលដៅ និងការកំណត់គោលដៅ[6]

➲ **វត្ថុបំណងមេរៀន ៖** ដើម្បីពន្យល់ពីអត្ថន័យនៃគោលដៅ និងផ្តល់ធាតុចូលពីរបៀបកំណត់គោលដៅនោះ។

🕘 **រយៈពេលមេរៀន ៖** ៤៥ នាទី

✉ **សារសំខាន់ៗ ៖**

១. វាមានសារៈសំខាន់ណាស់ក្នុងការកំណត់គោលដៅនានាសម្រាប់ការរីកចម្រើន និងការអភិវឌ្ឍផ្ទាល់ខ្លួន។

២. គេត្រូវកំណត់គោលដៅតាមលក្ខណៈ«ជ.វ.ស.ទ.ព»។

៣. នៅពេលកំណត់គោលដៅរួចហើយ វាមានសារៈសំខាន់ក្នុងការចាប់ផ្តើមធ្វើការងារសារឡើងវិញដើម្បីរៀបចំផែនការ រៀបចំកិច្ចការ និងកំណត់វត្ថុបំណងឆ្ពោះទៅរកការសម្រេចគោលដៅទាំងនោះ។ នៅពេលធ្វើរួចរាល់ហើយ វានឹងជួយយើងឱ្យយល់កាន់តែទូលំទូលាយ និងកំណត់អាទិភាពកិច្ចការដែលសំខាន់ និងបន្ទាន់បំផុត ព្រមទាំងតម្រង់ទិសការយកចិត្តទុកដាក់ពេលវេលា និងថាមពលរបស់យើងឆ្ពោះទៅរកការសម្រេចគោលដៅនៅក្នុងជីវិតរបស់យើង។

៤. ការកំណត់គោលដៅជួយយើងក្នុងការរៀបចំធនធាន កំណត់អាទិភាព ក៏ដូចជាប្រើពេលវេលាប្រកបដោយប្រសិទ្ធិភាពដើម្បីសម្រេចបានគោលដៅទាំងនោះ។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ ៖**

☞ សម្រាប់គ្រូបង្រៀន ៖ ក្រដាសតារាងមួយសន្លឹក ក្តារខៀន ហ្វឺត ឬដីស ហ្វឺតលុបមិនជ្រះមួយដើម ខ្មៅដៃពណ៌ ឬថ្នាំលាប និងជក់ ឬប៊ិកគូររូប ស្កុត និងកន្ត្រៃ។

☞ សម្រាប់សិស្ស ៖ សន្លឹកកិច្ចការ ៖ កិច្ចការក្នុងថ្នាក់ទំព័រទី៩៧ និងទី៩៩ និងសម្ភារៈសរសេរ។

**ការរៀបចំទុកជាមុន ៖**

☞ អាន និងយល់ពីលំនាំបង្រៀនឱ្យច្បាស់។

[6] ដកស្រង់ពីកម្មវិធីសិក្សា P.A.C.E នៃ ICRW-Gap Inc។

- ☞ អានឯកសារអំណានទី៨ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន។
- ☞ បង្កើតតារាងមួយដែលពន្យល់អត្ថន័យរបស់ពាក្យគោលដៅ «ជ.វ.ស.ទ.ព» (សូមមើលឯកសារអំណានទី៩ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។
- ☞ បិទតារាងគោលដៅ «ជ.វ.ស.ទ.ព» នៅក្នុងថ្នាក់។
- ☞ ប្រមូលសម្ភារៈដែលចាំបាច់ផ្សេងៗទៀត។
- ☞ សរសេរចំណងជើងមេរៀននៅលើក្ដារខៀន។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- រំឭកសិស្សឱ្យចុះវត្តមាននៅពេលពួកគេចូលក្នុងថ្នាក់រៀន។
- ពិនិត្យមើលថាតើសិស្សមានយកសន្លឹកកិច្ចការរបស់ខ្លួនមកសាលារៀនដែរឬទេ។
- សួរសិស្សថាតើពួកគេបានធ្វើកិច្ចការផ្ទះរបស់គេដែរឬទេ។
- ឱ្យសិស្ស ម្នាក់ៗយកសម្ភារៈសរសេរមុនពេលរៀន។

## ២. វិធីសាស្ត្របង្រៀន

### សេចក្ដីណែនាំ

- ☞ ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល «អារម្មណ៍» សិស្សនៅក្នុងថ្នាក់ដោយឱ្យសិស្សប្រើដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតថាមពលរបស់ពួកគេ។
- ☞ ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់សង្ខេបពីអ្វីដែលពួកគេបានរៀននៅម៉ោងមុន។
- ☞ អាន និងចង្អុលចំណងជើងមេរៀននៅលើក្ដារខៀន។ ឱ្យសិស្សទាយថាតើមេរៀនថ្ងៃនេះនឹងរៀនពីអ្វី។ ឱ្យសិស្សស្ម័គ្រចិត្ត ២-៣នាក់ចែករំលែកគំនិតរបស់ពួកគេជាមួយក្រុម។
- ☞ ប្រាប់សិស្សថា មេរៀននៅថ្ងៃនេះនឹងជួយពួកគេឱ្យយល់កាន់តែទូលំទូលាយនូវចំណុចដូចខាងក្រោម ៖
  - អ្វីជាគោលដៅ។
  - មូលហេតុដែលវាមានសារៈសំខាន់ក្នុងការកំណត់គោលដៅ។
- ☞ សួរសិស្សនូវសំណួរដូចខាងក្រោម ៖
  - តើគោលដៅគឺជាអ្វី?
  - តើពាក្យអ្វីខ្លះដែលមានទាក់ទងជាមួយនឹងគោលដៅ?

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- សរសេរពាក្យ «គោលដៅ» នៅលើក្តារខៀន។ គូរវង្វង់ជុំវិញពាក្យនោះ។ នៅពេលសិស្សឆ្លើយសំណួរខាងលើ សរសេរពាក្យគន្លឹះដែលទាក់ទងពីចម្លើយរបស់ពួកគេនៅជុំវិញរង្វង់ដើម្បីបង្កើតសំណាញ់ពាក្យ។
- ចម្លើយដែលអាចមានរួមមានដូចខាងក្រោម ៖ «វត្ថុបំណង» «ការចង់បាន» «គោលបំណង» «ផែនការ» «ទិសដៅ»។

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកចំណុចដូចខាងក្រោម ៖

– គេកំណត់**គោលដៅ**មួយថាជាអ្វីមួយដែលយើងមានបំណង ***សម្រេចឱ្យបាន*** នៅថ្ងៃអនាគត។ វាជាសមិទ្ធផលជាក់លាក់ដែលជួយយើងក្នុងការសម្រេចក្តីសុបិន ឬបំណងប្រាថ្នានៅក្នុងជីវិតរបស់យើង។

☞ សួរសំណួរដូចខាងក្រោម ៖

- តើយេនឌ័ររបស់មនុស្សម្នាក់ប៉ះពាល់ដល់គោលដៅ និងការកំណត់គោលដៅរបស់គេដែរឬទេ? តើដោយរបៀបណា?

☞ ទទួលយកចម្លើយ បន្ទាប់មកពន្យល់ដូចខាងក្រោម ៖

– ឆ្លុះបញ្ចាំងឡើងវិញនូវជំពូកនានានៅក្នុងម៉ូឌុលទី១ស្តីពី យេនឌ័រ អំណាច និងបិតាធិបតេយ្យដែលបង្ហាញយើងពីរបៀបនៃការរំពឹងទុកផ្នែកយេនឌ័រជុំវិញអ្វីដែលសមស្របសម្រាប់ស្ត្រី និងបុរសដែលកំណត់អាកប្បកិរិយា ឥរិយាបថ ជម្រើស សមត្ថភាពធ្វើការសម្រេចចិត្ត និងការទទួលបានមូលធនសង្គម និងសេដ្ឋកិច្ចរបស់យើង។

– នៅក្នុងលក្ខណៈស្រដៀងគ្នានេះដែរ កម្លាំងយេនឌ័រ អំណាច និងសង្គមបិតាធិបតេយ្យអាច និងជារឿយៗពិតជាមានឥទ្ធិពលលើការសម្រេចចិត្តរបស់ក្មេងស្រីវ័យជំទង់ទៅលើផែនការអនាគតរបស់ពួកគេ រួមទាំងគោលដៅដែលពួកគេបានកំណត់សម្រាប់ខ្លួនឯងផងដែរ។

– ក្មេងស្រី និងស្ត្រី អាចយល់ឃើញថា គោលដៅក្នុងជីវិតរបស់ពួកគេជារឿយៗត្រូវបានកំណត់ជាមុន ឬត្រូវកំណត់ឱ្យពួកគេដោយពួកគេមិនបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការធ្វើការសម្រេចចិត្ត។

**🗝 គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- នៅក្នុងបរិបទនេះ ត្រូវរំឭកសិស្សថា គោលដៅរបស់គេត្រូវមានលក្ខណៈផ្ទាល់ខ្លួនឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ជាជាងការផ្អែកលើការរំពឹងទុករបស់ឪពុកម្ដាយ ឬសង្គមទាំងមូល។

## កិច្ចការក្នុងថ្នាក់

**កិច្ចការក្នុងថ្នាក់ ៖**

- ឱ្យសិស្សបើកសន្លឹកកិច្ចការរបស់ខ្លួននៅទំព័រទី៩៧។
- អានសេចក្ដីណែនាំ បន្ទាប់មកពន្យល់ពីអ្វីដែលពួកគេត្រូវធ្វើ។
  - ឱ្យសិស្សឆ្លុះបញ្ចាំងពីជីវិតរបស់ពួកគេ និងគិតពីគោលដៅសំខាន់ៗមួយចំនួនដែលពួកគេចង់សម្រេចបាន។ ឱ្យសិស្សសរសេរគោលដៅទាំងនោះនៅលើក្រដាសកិច្ចការរបស់គេ *(ឱ្យសិស្សពិចារណាលើការមើលក្រដាសកិច្ចការទំព័រទី៩៧ឡើងវិញ (ក្ដីសុបិនរបស់ខ្ញុំ ចំណាប់អារម្មណ៍របស់ខ្ញុំ / ជម្រើសអាជីពរបស់ខ្ញុំ)*។
  - ប្រាប់សិស្សថា ពួកគេមានពេល៥នាទីដើម្បីបំពេញកិច្ចការនេះ។
- ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់ចែករំលែកជាមួយក្រុមធំ។
- យកឧទាហរណ៍ពីចម្លើយរបស់សិស្ស បន្ទាប់មកពន្យល់ចំណុចដូចខាងក្រោម ៖
  - ពេលខ្លះ គោលដៅរបស់យើងមានលក្ខណៈផ្ទាល់ខ្លួនជាទីបំផុត ហើយពេលខ្លះយើងមានគោលដៅដែលតម្រង់ទៅរកភាពល្អជារួមនៅក្នុងសហគមន៍។ ជារឿយៗ គោលដៅពឹងផ្អែកទៅលើធនធានការអប់រំរបស់យើង ។ល។
  - មនុស្សម្នាក់អាចកែសម្រួលឡើងវិញ ឬផ្លាស់ប្ដូរគោលដៅទៅតាមពេលវេលាបាន។
  - គោលដៅអាចមានរយៈពេលខ្លី ឬរយៈពេលវែង។
  - ការសិក្សាស្វែងយល់ក៏ជាកត្តាមួយក្នុងការសម្រេចចិត្តលើគោលដៅរបស់មនុស្សម្នាក់ដែរ។
  - គេមិនអាចហៅអ្វីមួយដែលអាចទទួលបានដោយស្រួលថាជាគោលដៅបានទេ។ ទោះជាយ៉ាងនេះក្ដី យើងត្រូវគិតគូរពិចារណាពីលទ្ធភាព និងបំណងប្រាថ្នាពេលអនាគតរបស់យើង *(អ្វីដែលយើងចង់សម្រេចឱ្យបាន)* នៅពេលកំណត់គោលដៅផ្សេងៗ។
- សួរសំណួរដូចខាងក្រោម ៖
  - ហេតុអ្វីបានជាប្អូនគិតថា វាមានសារៈសំខាន់ដែលត្រូវកំណត់គោលដៅ?

☞ ចម្លើយដែលអាចមាន រួមមានដូចខាងក្រោម ៖

– សម្រាប់ការរីកចម្រើន និងការអភិវឌ្ឍរបស់បុគ្គលម្នាក់ៗ។
– សម្រាប់ភាពជោគជ័យ និងសមិទ្ធផលនៅក្នុងជីវិត។
– ដើម្បីផ្តល់ទិសដៅ និងគោលបំណងសម្រាប់ជីវិតរបស់បុគ្គលម្នាក់ៗ។
– ដើម្បីឯករាជ្យភាព និងការពឹងផ្អែកលើខ្លួនឯង។
– ដើម្បីធ្វើឱ្យជីវិតរបស់យើងមានន័យ។
– ដើម្បីសម្រេចក្តីសុបិន ។ល។

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកចំណុចដូចខាងក្រោម ៖

– ដើម្បីទទួលបានជោគជ័យយើងត្រូវកំណត់គោលដៅសម្រាប់ខ្លួនយើង។
– គោលដៅផ្តល់ឱ្យយើងនូវទិសដៅច្បាស់លាស់មួយដើម្បីធ្វើការឆ្ពោះទៅរកគោលដៅនោះ។
– ប្រសិនបើគ្មានការកំណត់គោលដៅ យើងនឹងខ្វះការយកចិត្តទុកដាក់ និងទិសដៅ។
– ការកំណត់គោលដៅធ្វើឱ្យយើងមានលទ្ធភាពគ្រប់គ្រងលើគន្លង និងទិសដៅដែលសំខាន់ក្នុងជីវិតរបស់យើង។ វាក៏ផ្តល់ឱ្យយើងនូវចំណុចដៅដែលកំណត់ថាតើយើងពិតជាទទួលបានជោគជ័យដែរឬទេ។ ឧទាហរណ៍ ប្រសិនបើគោលដៅរបស់ប្អូនគឺត្រូវសន្សំប្រាក់ដើម្បីបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា ហើយប្អូនបានសន្សំប្រាក់គ្រប់ចំនួននៅក្នុងគណនីធនាគាររបស់ប្អូន តែប្អូនមិនបានចុះឈ្មោះចូលរៀននៅថ្នាក់ឧត្តមសិក្សា ឬរៀនមិនបានពិន្ទុល្អ ដូច្នេះប្រាក់ដែលសន្សំបាននោះនឹងមានលក្ខណៈផ្ទុយពីរបៀបដែលប្អូនកំណត់ភាពជោគជ័យរបស់ខ្លួន។

☞ សួរសំណួរដូចខាងក្រោម ៖

◈ តើអ្វីជាការកំណត់គោលដៅពិតប្រាកដ?
◈ តើមនុស្សម្នាក់កំណត់គោលដៅដោយរបៀបណា?

☞ ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់ឆ្លើយសំណួរ បន្ទាប់មកចែករំលែកចំណុចដូចខាងក្រោម ៖

– ការកំណត់គោលដៅគឺជាការគិតពីអនាគតដែលពាក់ព័ន្ធនឹងអ្វីដែលយើងចង់ធ្វើនិងសម្រេចឱ្យបានតាមវិធីជាក់លាក់មួយ។ ការកំណត់គោលដៅគឺលើសពីការសម្រេចចិត្តលើអ្វីដែលយើងចង់ធ្វើ។ វាពាក់ព័ន្ធជាមួយនឹងការគិតគូរពីអ្វីដែលយើងចាំបាច់ត្រូវធ្វើដើម្បីទៅដល់កន្លែងដែលយើងចង់ទៅ និងរយៈពេលដែលយើងត្រូវចំណាយដើម្បីទៅដល់ទីនោះ។ វាពាក់ព័ន្ធនឹងការគិត ការរៀបចំផែនការ និងការកំណត់ពេលវេលា សម្រាប់របៀបដែលយើងចង់ធ្វើអ្វីដែលយើងចង់ធ្វើ។ គេអាចនិយាយម្យ៉ាងទៀតថា ៖
  – ជំហានដំបូងនៃការកំណត់គោលដៅគឺការស្គាល់ពីទីកន្លែងដែលយើងចង់ទៅ។

– ជំហានទី២ គឺការមានផែនការសម្រាប់ទៅឱ្យដល់ទីនោះ។

☞ សួរសំណួរដូចខាងក្រោម ៖

- តើមនុស្សម្នាក់ដឹងថាគោលដៅមួយល្អដោយរបៀបណា?
- តើយើងអាចរៀបចំផែនការប្រកបដោយប្រសិទ្ធភាពដើម្បីសម្រេចគោលដៅនោះបានដោយរបៀបណា?

☞ ទទួលយកចម្លើយ២-៣ បន្ទាប់មកចែករំលែកចំណុចដូចខាងក្រោម ៖

– ដើម្បីកំណត់គោលដៅដែលមានអានុភាព យើងត្រូវរៀបចំគោលដៅតាមវិធីដែលហៅថាគោលដៅ «ជ.វ.ស.ទ.ព»។

– តើយើងដឹងថាគោលដៅមួយមានលក្ខណៈ «ជ.វ.ស.ទ.ព» ដោយរបៀបណា ហើយតើយើងអាចរៀបចំផែនការប្រកបដោយប្រសិទ្ធភាពដើម្បីសម្រេចបានគោលដៅនោះដោយរបៀបណា?

☞ ពន្យល់ពីគោលការណ៍ដែលត្រូវអនុវត្តតាមជានិច្ចទាំង៥ក្នុងការកំណត់គោលដៅដែលរួមមាន ៖

**គោលការណ៍ទី១ ៖ កំណត់គោលដៅមួយដែលលើកទឹកចិត្តដល់ប្អូន**

– គោលការណ៍នេះមានន័យថា គោលដៅដែលប្អូនកំណត់សម្រាប់ខ្លួនឯងត្រូវការលើកទឹកចិត្តផ្ទាល់ខ្លួន និងសំខាន់សម្រាប់ប្អូន។ វាអាចបន្ថែមគុណតម្លៃដល់ជីវិតរបស់ប្អូន នៅពេលប្អូនសម្រេចបានគោលដៅនោះ បានន័យថាវាត្រូវជួយប្អូនឱ្យបង្កើនសមត្ថភាពរបស់ប្អូន និងធ្វើឱ្យឱកាសនាពេលអនាគតរបស់ប្អូនកាន់តែល្អប្រសើរឡើង។

– ប្រសិនបើគោលដៅដែលប្អូនកំណត់មានភាពចាប់អារម្មណ៍តិចតួចសម្រាប់ប្អូន ឬមិនមានសារៈសំខាន់ចំពោះប្អូននៅក្នុងស្ថានភាពទូទៅនៃជីវិតរបស់ប្អូន ពេលនោះវាអាចមានលទ្ធភាពដែលថា ប្អូនអាចនឹងមិនធ្វើឱ្យវាកើតឡើង១០០%ទេ។ ការលើកទឹកចិត្តគឺជាសមាសធាតុសំខាន់នៃការសម្រេចគោលដៅដែលយើងកំណត់សម្រាប់ខ្លួនយើងបានដោយជោគជ័យ។

# «ស្មាត S.M.A.R.T. ឬ ជ.វ.ស.ទ.ព»

**គោលការណ៍ទី២ ៖ កំណត់គោលដៅដែលមានលក្ខណៈ «ជ.វ.ស.ទ.ព»**

☞ ពន្យល់ដូចខាងក្រោម ៖

– ដើម្បីកំណត់គោលដៅដែលមានអានុភាព យើងត្រូវកំណត់ថាតើជាគោលដៅមានលក្ខណៈ «ជ.វ.ស.ទ.ព»ដែរឬទេ។

– តើយើងដឹងថាគោលដៅមួយមានលក្ខណៈ«ជ.វ.ស.ទ.ព»ដោយរបៀបណា ហើយតើមនុស្សម្នាក់អាចរៀបចំផែនការប្រកបដោយប្រសិទ្ធភាពដើម្បីសម្រេចបានគោលដៅនោះដោយរបៀបណា?

☞ ពន្យល់ពីគោលការណ៍នៃការកំណត់គោលដៅ «ជ.វ.ស.ទ.ព» ដោយមានឧទាហរណ៍មួយដើម្បីជួយសិស្សឱ្យយល់កាន់តែច្បាស់។

☞ គោលដៅត្រូវតែមានលក្ខណៈ....

– ជាក់លាក់ (ជ-Specific) ៖ យើងត្រូវកំណត់គោលដៅដែលមានលក្ខណៈជាក់លាក់។

  ○ ចំណុចនេះមានន័យថា គោលដៅរបស់ប្អូនត្រូវតែមានលក្ខណៈច្បាស់លាស់ និងពិតប្រាកដ។ គោលដៅដែលមានលក្ខណៈទូលំទូលាយមិនមានប្រយោជន៍ឡើយ ដោយសារវាមិនបានផ្តល់ទិសដៅគ្រប់គ្រាន់។ ចូរចងចាំថា ប្អូនត្រូវការគោលដៅដើម្បីបង្ហាញផ្លូវរបស់ប្អូន។ ចូរបង្កើតគោលដៅដែលមានលក្ខណៈងាយស្រួលតាមដែលប្អូនអាចធ្វើបាន ដើម្បីទៅឱ្យដល់កន្លែងដែលប្អូនចង់ទៅតាមរយៈការកំណត់ឱ្យបានច្បាស់ពីកន្លែងដែលប្អូនចង់បញ្ចប់។ *ឧទាហរណ៍ ៖ ខ្ញុំនឹងត្រៀមខ្លួនឱ្យបានល្អ ហើយនឹងប្រឡងយកអាហារូបករណ៍នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញនៅរយៈពេល២ឆ្នាំខាងមុខ។*

– អាចវាស់វែងបាន (វ-Measurable) ៖ យើងត្រូវកំណត់គោលដៅដែលអាចវាស់វែងបាន។

  ○ ចំណុចនេះរួមមានផ្នែកដែលចាំបាច់នានាសម្រាប់គោលដៅរបស់ប្អូន ដូចជា កាលបរិច្ឆេទជាក់លាក់ ហិរញ្ញវត្ថុ ។ល។ វាអាចឱ្យប្អូនវាស់ពីកម្រិតនៃភាពជោគជ័យរបស់ប្អូនបាន។ *ឧទាហរណ៍ ៖ វាគឺជាគោលដៅមួយដែលគេអាចវាស់វែងបានចំពោះការរៀបចំមូលនិធិហិរញ្ញប្បទានដើម្បីចុះឈ្មោះឱ្យទាន់ពេលវេលា ពេលវេលាដែលមានសម្រាប់ចូលរួមក្នុងការត្រៀមខ្លួនប្រឡង ក៏ដូចជាការចូលរួមប្រឡង ដែរ។*

– អាចសម្រេចបាន (ស-Achievable) ៖ យើងត្រូវកំណត់គោលដៅដែលអាចសម្រេចបាន។

  ○ ត្រូវប្រាកដថា គោលដៅធ្វើឱ្យប្អូនចាប់អារម្មណ៍។ ប្រសិនបើប្អូនកំណត់គោលដៅមួយដែលប្អូនដឹងថា ប្អូនមានការចាប់អារម្មណ៍តិចតួច ឬមិនចាប់អារម្មណ៍សោះ វានឹងមិនជំរុញទឹកចិត្តប្អូនទេ ហើយថែមទាំងកាត់បន្ថយការជឿជាក់លើខ្លួនឯងរបស់ប្អូនទៀតផង។ ត្រូវកំណត់ខ្លួនឯងដោយជៀសវាងការកំណត់គោលដៅដែលងាយស្រួល។ ការសម្រេចបានគោលដៅមួយដែលមានភាពងាយខ្លាំងពេកអាចធ្វើឱ្យប្អូនខកចិត្តនៅទីបញ្ចប់ ហើយអាចធ្វើឱ្យប្អូនមានអារម្មណ៍ភ័យខ្លាចក្នុងការកំណត់គោលដៅផ្សេងៗនាពេលអនាគតដែលមានហានិភ័យចំពោះភាពបរាជ័យ។ ដើម្បីរក្សាបាននូវតុល្យភាព ចូរ

កំណត់គោលដៅដែលមានលក្ខណៈប្រាកដនិយមដែលតម្រូវឱ្យប្អូនពុះពារ ជួយប្អូនឱ្យកែលម្អខ្លួនឯង និងផ្ដល់ឱ្យប្អូននូវភាពពេញចិត្តកាន់តែខ្លាំងឡើងនៅពេលប្អូនសម្រេចវាបាន។ *ឧទាហរណ៍ ៖ គោលដៅនេះអាចសម្រេចទៅបានដោយផ្អែកលើការតស៊ូ ការប្ដេជ្ញាចិត្ត និងការខិតខំប្រឹងប្រែងរបស់នរណាម្នាក់ដើម្បីត្រៀមប្រឡង។*

- ភាពទាក់ទងគ្នា (ទ-Relavant) ៖ យើងត្រូវកំណត់គោលដៅដែលមានភាពជាប់ទាក់ទងគ្នា។
  - គោលដៅរបស់ប្អូនត្រូវតែជាប់ទាក់ទងទៅនឹងទិសដៅដែលប្អូនចង់ឱ្យដំណើរជីវិតនាពេលអនាគតរបស់ប្អូនប្រព្រឹត្តទៅ។ គោលដៅគួរមានភាពជាប់ទាក់ទង និងសង្គតិភាពព្រមទាំងមិនរាយប៉ាយ។ *ឧទាហរណ៍ ៖ គោលដៅនេះមានជាប់ទាក់ទងនឹងខ្ញុំដោយយោងលើគុណវុឌ្ឍិបច្ចុប្បន្នរបស់ខ្ញុំ (បរិញ្ញាបត្រផ្នែកសង្គមវិទ្យា) ហើយជំនាញ(បំណិន)ដែលខ្ញុំមានបច្ចុប្បន្ននេះធ្វើឱ្យខ្ញុំមានលទ្ធភាពរៀបចំខ្លួនក្នុងការកំណត់ធនធានផ្សេងៗដែលធ្វើឱ្យខ្ញុំអាចសិក្សាសម្រាប់ការប្រឡង។*
- ពេលវេលាកំណត់ (ព-Time Bound) ៖ យើងត្រូវកំណត់គោលដៅដែលមានពេលវេលាកំណត់។
  - គោលដៅរបស់ប្អូនត្រូវតែមានកំណត់ពេលវេលា ឬកាលបរិច្ឆេទចុងក្រោយមួយ។ ចំណុចនេះមានន័យថា ប្អូនត្រូវកំណត់ពេលវេលាដើម្បីសម្រេចបានគោលដៅ ដែលប្អូនអាចធ្វើការឆ្ពោះទៅរកការសាទរចំពោះភាពជោគជ័យរបស់ប្អូន។ កាលកំណត់បង្កើតឱ្យមានភាពបន្ទាន់ដែលពេលខ្លះធ្វើឱ្យប្អូនសម្រេចគោលដៅមុនពេលកំណត់។ *ឧទាហរណ៍ ៖ គេកំណត់គោលដៅនៅក្នុងពេលវេលាជាក់លាក់មួយ។ ក្នុងករណីនេះ វាមានរយៈពេល២ឆ្នាំ។*

កិច្ចការក្នុងថ្នាក់

**កិច្ចការក្នុងថ្នាក់ ៖**

☞ ឱ្យសិស្សបើកសន្លឹកកិច្ចការរបស់ខ្លួននៅទំព័រទី៩៧។ ផ្ដល់ការណែនាំដូចខាងក្រោម ៖

- កំណត់គោលដៅសំខាន់បំផុតសម្រាប់ខ្លួនប្អូនដោយឆ្លុះបញ្ចាំងទៅលើចំណុចនីមួយៗ និងឆ្លើយសំណួរដូចខាងក្រោម ៖
  - តើគោលដៅនេះលើកទឹកចិត្តប្អូនជាលក្ខណៈផ្ទាល់ខ្លួនដែរឬទេ? តើវាមានសារៈសំខាន់ចំពោះប្អូនដែរឬទេ?
  - តើគោលដៅនេះជួយបង្កើនសមត្ថភាពផ្ទាល់របស់ប្អូន និងធ្វើឱ្យប្អូនមានឱកាសកាន់តែប្រសើរឡើងនៅពេលអនាគតដែរឬទេ?

– នៅពេលដែលប្អូនបានកំណត់ពីគោលដៅសំខាន់បំផុតរបស់ប្អូនហើយ ចូរគូសសញ្ញា(✓) នៅក្បែរវា។

🗝 **គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

🕯 មុនពេលសិស្សគូសសញ្ញា(✓)នៅក្បែរគោលដៅសំខាន់ និងបន្ទាន់បំផុតនៅលើសន្លឹកកិច្ចការរបស់គេ សូមណែនាំឱ្យគេគិតទៅរកបំណងប្រាថ្នាពេលអនាគតរបស់ខ្លួន ៖ អ្វីដែលពួកគេចង់សម្រេចបានតាមវិធីជាក់លាក់ណាមួយ និងគោលដៅមួយដែលនឹងផ្តល់អត្ថប្រយោជន៍ដល់ជីវិតរបស់គេនាពេលអនាគត។ ឱ្យសិស្សឆ្លុះបញ្ចាំងលើសន្លឹកកិច្ចការពីមុនមករបស់គេ (ទំព័រទី៩៧)។

☞ នៅពេលសិស្សម្នាក់ៗបានកំណត់ពីគោលដៅរបស់ខ្លួនហើយ ចូរប្រាប់សិស្សថា ឥឡូវនេះពួកគេនឹងអនុវត្តគោលការណ៍ទី៣ ដែលតម្រូវឱ្យគេកំណត់គោលដៅរបស់ខ្លួនជាលាយលក្ខណ៍អក្សរនៅក្នុងទម្រង់ជាសេចក្តីថ្លែងគោលដៅ។

☞ ពន្យល់ដូចខាងក្រោម ៖

**គោលការណ៍ទី៣ ៖ កំណត់គោលដៅរបស់ប្អូនជាលាយលក្ខណ៍អក្សរ**

– សកម្មភាពនៃការសរសេរគោលដៅមួយធ្វើឱ្យគោលដៅនោះមានភាពពិតប្រាកដ និងជាក់លាក់។ វាធ្វើឱ្យប្អូនប្តេជ្ញាចិត្តក្នុងការធ្វើឱ្យគោលដៅនោះកើតឡើង។ នៅពេលដែលប្អូនសរសេរគោលដៅរបស់ប្អូន ចូរប្អូនប្រើពាក្យថា «**ខ្ញុំនឹង**» ជំនួសឱ្យពាក្យ «ខ្ញុំប្រហែលជាអាច» ឬ «ខ្ញុំអាច»។
   - ឧទាហរណ៍មួយស្តីពីសេចក្តីថ្លែងគោលដៅដែលមានលក្ខណៈប្តេជ្ញាចិត្តខ្ពស់គឺ ៖ «ចាប់ពីថ្ងៃនេះតទៅខ្ញុំនឹងខំរៀនដើម្បីត្រៀមប្រឡងយកអាហារូបករណ៍នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ និងចូលប្រឡងនៅឆ្នាំ២០១៨»។
   - ឧទាហរណ៍អំពីសេចក្តីថ្លែងគោលដៅដែលមានលក្ខណៈខ្សោយគឺ ៖ «ខ្ញុំអាចប្រឡងយកអាហារូបករណ៍នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងពេល ២ ឆ្នាំខាងមុខ»។

– សេចក្តីថ្លែងគោលដៅទី១គឺជាសេចក្តីថ្លែងដែលមានអានុភាព និងវិជ្ជមាន។ ប្អូនអាចមើលឃើញដោយខ្លួនឯងពីការប្តេជ្ញាចិត្តរបស់ប្អូនផ្ទាល់ និងធ្វើការលើគោលដៅនោះចាប់ពីថ្ងៃនេះតទៅ។ សេចក្តីថ្លែងគោលដៅទី២មានភាពខ្វះខាតការផ្តោតការយកចិត្តទុកដាក់ និង ពុំមាន

ភាពជាក់លាក់។ វាផ្តល់ឱ្យប្អូននូវលំហរ និងឱកាសដើម្បីដោះសារ ប្រសិនបើប្អូនផ្លាស់ប្តូរការចាប់អារម្មណ៍លើគោលដៅនោះ។

– ដើម្បីរំឭកខ្លួនអ្នកជារៀងរាល់ថ្ងៃ ចូរសរសេរគោលដៅរបស់ប្អូននៅលើក្រដាសមួយ ឬច្រើនសន្លឹក និងបិទវានៅទីកន្លែងផ្សេងៗគ្នានៅក្នុងផ្ទះរបស់ប្អូន ដូចជានៅលើជញ្ជាំង នៅក្បែរគ្រែ នៅលើកញ្ចក់ នៅលើទូរចានជាដើម។ វានឹងជួយរំឭកប្អូនជាប់ជាប្រចាំជារៀងរាល់ថ្ងៃនូវអ្វីដែលប្អូនតាំងចិត្តធ្វើ។

## ៣. ការពង្រីកចំណេះដឹង

🗣 **ចំណុចសម្រាប់ការពិភាក្សា**

កិច្ចការក្នុងថ្នាក់

**កិច្ចការក្នុងថ្នាក់ ៖**

☞ ឱ្យសិស្សបើកសន្លឹកកិច្ចការរបស់ខ្លួននៅទំព័រទី៩៨។

☞ ពន្យល់ថា សិស្សត្រូវអនុវត្តគោលការណ៍គោលដៅ«ជ.វ.ស.ទ.ព»សម្រាប់គោលដៅរបស់ខ្លួន។ ឱ្យសិស្សធ្វើការជាជំហានៗ បន្ទាប់មកបំពេញព័ត៌មានដែលទាក់ទង។

☞ ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់ចែករំលែកសេចក្តីថ្លែងគោលដៅរបស់ខ្លួន និងមូលហេតុដែលគេគិតថា គោលដៅរបស់ខ្លួនជាគោលដៅ «ជ.វ.ស.ទ.ព»។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ចងចាំថា សិស្សជាច្រើនប្រហែលជាមិនធ្លាប់បានគិតពីគោលដៅ និងមិនមានគោលដៅជាវិជ្ជាជីវៈ ឬអប់រំនៅឡើយទេនៅពេលនេះ។ គោលបំណងរបស់កម្មវិធីសិក្សា Gap Inc. P.A.C.E. គឺដើម្បីផ្តល់ការលើកទឹកចិត្តដល់សិស្សទាំងនោះ ៖ ដើម្បីកំណត់ពីបំណងប្រាថ្នា និងសុបិនរបស់ខ្លួននាពេលអនាគត។
- ដំណើរការនៃការគិតពីគោលដៅគឺជាការផ្តល់សិទ្ធិអំណាចដល់សិស្ស ហើយវានឹងបង្កើតឱកាសមួយឱ្យពួកគេមើលឃើញពីលទ្ធផលរូបី និងអរូបីតាមរយៈដំណើរការនេះ។

☞ ពន្យល់ដូចខាងក្រោម ៖

**គោលការណ៍ទី៤ ៖ ប្រើប្រាស់ផែនការសកម្មភាពជាមូលដ្ឋាន**

- ការរៀបចំផែនការជាជំហានៗដើម្បីសម្រេចគោលដៅរបស់ប្អូនមានសារៈសំខាន់ណាស់។ វាជួយឱ្យប្អូនផ្តោតការយកចិត្តទុកដាក់ និងធ្វើការឆ្ពោះទៅរកការទទួលបានជោគជ័យចំពោះការសម្រេចបានគោលដៅរបស់ប្អូនជានិច្ច។
- នៅពេលរៀបចំផែនការ ចូរសរសេរជំហាននីមួយៗដែលនឹងជួយប្អូនឱ្យសម្រេចបានគោលដៅរបស់ប្អូន។ គូសសញ្ញា(✓)នៅក្បែរជំហាននីមួយៗនៅពេលប្អូនបានអនុវត្តជំហាននោះហើយ។ ចំណុចនេះនឹងបង្ហាញយ៉ាងច្បាស់ពីវឌ្ឍនភាពរបស់ប្អូនឆ្ពោះទៅរកការសម្រេចបានលទ្ធផលចុងក្រោយ។
- ដំណើរការនៃការរៀបចំផែនការទៅមុខ និងការរៀបចំផែនការសកម្មភាពទៅជាជំហានតូចៗអាចជួយប្អូនបាន ប្រសិនបើគោលដៅរបស់ប្អូនមានរយៈពេលវែង មានទំហំធំ និងតម្រូវឱ្យប្អូនចំណាយពេលវេលា ថាមពល និងធនធានច្រើន។
- អ្វីដែលប្អូនចាំបាច់ត្រូវធ្វើ ៖
  - ជំហានទី១ ៖ គិតពីចំណុចទាំងអស់ដែលប្អូនចាំបាច់ត្រូវបំពេញដើម្បីសម្រេចគោលដៅរបស់ប្អូន។ ចាប់ផ្តើមជាមួយនឹងសកម្មភាពដំបូងដែលប្អូនចាំបាច់ត្រូវអនុវត្ត។ នៅពេលប្អូនបញ្ចប់សកម្មភាពនោះហើយ ចូរគិតពីអ្វីដែលប្អូនត្រូវធ្វើបន្ទាប់ និងសកម្មភាពបន្តបន្ទាប់ទៀត។ ចូរពិនិត្យមើលជំហានទាំងអស់ បន្ទាប់មកពិនិត្យមើលថាតើប្អូនត្រូវកំណត់អាទិភាពជំហានណាមួយដែលតម្រូវឱ្យប្អូនបំពេញតាមកាលកំណត់ជាក់លាក់ ឬដោយសារប្អូនពឹងផ្អែកលើនរណាម្នាក់ផ្សេងទៀត ហើយពេលវេលា និងការដែលអាចជួបគេបានមានកម្រិតបំផុតដែរឬទេ។
  - ជំហានទី២ ៖ នៅពេលដែលប្អូនមានបញ្ជីសកម្មភាព ឬកិច្ចការដែលបានកំណត់ហើយ ប្អូនចាំបាច់ត្រូវធ្វើវាតាមលំដាប់លំដោយដើម្បីឈានទៅដល់គោលដៅរបស់ប្អូនចាប់ពីពេលចាប់ផ្តើមរហូតដល់ពេលបញ្ចប់ដោយពិនិត្យមើលកិច្ចការនីមួយៗយ៉ាងលម្អិត។ ចូរពិនិត្យមើលថាតើប្អូនអាចអនុវត្តជំហានណាមួយរួចហើយ តែនៅតែមិនទាន់សម្រេចបាននូវវត្ថុបំណងដែលបានគ្រោងទុកដែរឬទេ។ តើប្អូនត្រូវការសុំជំនួយដែរឬទេ? តើមានកាលបរិច្ឆេទកំណត់ណាមួយសម្រាប់ជំហាន ឬសកម្មភាពជាក់លាក់ដែលចាំបាច់ត្រូវអនុវត្តដែរឬទេ? តើប្អូនត្រូវការ និងចាំបាច់ត្រូវរៀបចំធនធានបន្ថែម ដូចជា ហិរញ្ញវត្ថុ មនុស្សផ្សេងទៀត ។ល។ ដើម្បីជួយដែរឬទេ?

កិច្ចការក្នុងថ្នាក់

**កិច្ចការក្នុងថ្នាក់**

☞ ឱ្យសិស្សបើកសន្លឹកកិច្ចការរបស់ខ្លួននៅទំព័រទី៩៩។

☞ ពន្យល់ពីអ្វីដែលសិស្សចាំបាច់ត្រូវធ្វើ។ លើកទឹកចិត្តសិស្សឱ្យរៀបចំផែនការសកម្មភាពជាជំហានៗសម្រាប់គោលដៅដែលពួកគេបានកំណត់។ ឱ្យសិស្សកំណត់ឧបសគ្គដែលអាចកើតមានដែលរារាំងពួកគេមិនឱ្យសម្រេចបានគោលដៅរបស់ខ្លួន និងស្វែងរកដំណោះស្រាយដើម្បីជម្នះឧបសគ្គទាំងនោះ។

> **គន្លឹះសម្រាប់គ្រូបង្រៀន**
>
> លោកគ្រូ អ្នកគ្រូត្រូវ ៖
>
> - ប្រសិនបើមិនមានពេលវេលាដើម្បីអនុវត្តសន្លឹកកិច្ចការក្នុងថ្នាក់នៅទំព័រទី១០០បាន ចូរពិចារណាយកវាធ្វើជាកិច្ចការផ្ទះវិញ។ ពន្យល់លម្អិតពីអ្វីដែលសិស្សត្រូវធ្វើ និងផ្តល់ពេលវេលាឱ្យសិស្ស សួរបញ្ជាក់ពីសំណួរណាមួយដែលពួកគេអាចមាន។

☞ សរុបសេចក្តីដោយពន្យល់ដូចខាងក្រោម ៖

**គោលការណ៍ទី៨ ៖ តស៊ូ - ប្រកាន់ខ្ជាប់នូវផែនការរបស់ប្អូន**

- ចូរចងចាំថា ការកំណត់គោលដៅគឺជាសកម្មភាពបន្តជាប្រចាំមិនមែនត្រឹមតែជាមធ្យោបាយសម្រាប់ការបញ្ចប់ការងារមួយទេ។
- រៀបចំឱ្យមានការរំឭកដើម្បីឱ្យប្អូនអនុវត្តតាមផែនការរបស់ខ្លួនជានិច្ច។
- កំណត់រយៈពេលជាក់លាក់ជាប្រចាំដើម្បីពិនិត្យមើលគោលដៅរបស់ប្អូនឡើងវិញ។
- គោលដៅចុងក្រោយរបស់ប្អូនអាចនៅតែមានភាពស្រដៀងគ្នាក្នុងរយៈពេលវែង ប៉ុន្តែផែនការសកម្មភាពដែលប្អូនបានកំណត់សម្រាប់ខ្លួនប្អូនផ្ទាល់ក្នុងកំឡុងពេលដំណើរការអាចផ្លាស់ប្តូរជាដុំកំភួន។ ចូរធានាថាភាពជាប់ទាក់ទង គុណតម្លៃ និងភាពចាំបាច់នៅតែមានកម្រិតខ្ពស់។

☞ ប្រសិនបើមានពេល សូមបញ្ចប់មេរៀនដោយសរុបនូវអ្វីដែលបានរៀនពីមេរៀននេះ។

> **គន្លឹះសម្រាប់គ្រូបង្រៀន**
>
> លោកគ្រូ អ្នកគ្រូត្រូវ ៖
>
> - ប្រមូលសន្លឹកកិច្ចការទាំងអស់មុនពេលសិស្សបំបែកគ្នា ក្នុងករណីដែលពួកគេបានបញ្ចប់សន្លឹកកិច្ចការទំព័រទី១០០ ដែលជាកិច្ចការក្នុងថ្នាក់។

# សំណុំឯកសារសម្រាប់គ្រូបង្រៀន

## ឯកសារអំណានទី៨ ៖ ឯកសារអំណានសម្រាប់គ្រូបង្រៀន



បរិបទចំណេះដឹង ៖ របៀបបង្កើតគោលដៅ «ជ.វ.ស.ទ.រ - S.M.A.R.T.»

ជាក់លាក់-អាចវាស់វែងបាន-អាចសម្រេចបាន-ជាប់ទាក់ទងគ្នា -រយៈពេលកំណត់

ជាក់លាក់ ៖ គោលដៅជាក់លាក់មួយមានឱកាសក្នុងការសម្រេចបានច្រើនជាងគោលដៅទូទៅឆ្ងាយណាស់។ ដើម្បីកំណត់គោលដៅជាក់លាក់ ប្អូនត្រូវឆ្លើយសំណួរចំនួន៦ដូចខាងក្រោម ៖

| | |
|---|---|
| ១. នរណា ៖ តើនរណាជាប់ទាក់ទង? | ៤. ពេលវេលា ៖ កំណត់ពេលវេលា។ |
| ២. អ្វី ៖ តើអ្វីដែលខ្ញុំចង់សម្រេចបាន? | ៥. ណាមួយ ៖ កំណត់តម្រូវការ និងឧបសគ្គដែលអាចកើតមាន។ |
| ៣. ទីកន្លែង ៖ កំណត់ទីតាំងចាំបាច់។ | ៦. មូលហេតុ ៖ កំណត់មូលហេតុ ឬអត្ថប្រយោជន៍ជាក់លាក់នៃការសម្រេចគោលដៅ។ |

*ឧទាហរណ៍ ៖ គោលដៅទូទៅគឺ ៖ «ខ្ញុំចង់បានរាងកាយមាំមួន»។ គោលដៅជាក់លាក់គឺ ៖ «ខ្ញុំនឹងទៅក្លឹបសុខភាពចាប់ពីថ្ងៃស្អែក និងហាត់ប្រាណ៣ថ្ងៃក្នុងមួយសប្តាហ៍ក្នុងរយៈពេល៦ខែបន្ទាប់»។*

អាចវាស់វែងបាន ៖ កំណត់លក្ខណៈវិនិច្ឆ័យជាក់លាក់សម្រាប់វាស់វែងវឌ្ឍនភាពចំពោះការសម្រេចគោលដៅដែលប្អូនបានកំណត់។ នៅពេលប្អូនវាស់វែងវឌ្ឍនភាពរបស់ប្អូន ប្អូនតាមដានដំណើរការនៃគោលដៅ សម្រេចគោលដៅតាមកាលបរិច្ឆេទកំណត់ និងទទួលបាននូវភាពសប្បាយរីករាយលើសមិទ្ធផលដែលជំរុញប្អូនឱ្យខិតខំបន្តដើម្បីសម្រេចគោលដៅរបស់ប្អូន។ ដើម្បីកំណត់ថាតើគោលដៅរបស់ប្អូនអាចវាស់វែងបានដែរឬទេ ចូរសួរសំណួរដូចជា ៖ ប៉ុន្មាន(តម្លៃ ឬពេលវេលា)? ចំនួនប៉ុន្មាន? តើខ្ញុំដឹងដោយរបៀបណា នៅពេលដែលខ្ញុំសម្រេចបានគោលដៅរបស់ខ្ញុំ?

អាចសម្រេចបាន ៖ នៅពេលប្អូនកំណត់គោលដៅដែលមានសារៈសំខាន់បំផុតសម្រាប់ប្អូន ប្អូនចាប់ផ្តើមគិតគូរពីវិធីដែលប្អូនអាចធ្វើវាឱ្យក្លាយជាការពិត។ ប្អូនបង្កើតឥរិយាបថ សមត្ថភាព ជំនាញ និងសមត្ថភាពហិរញ្ញវត្ថុដើម្បីសម្រេចបានគោលដៅនោះ។ ប្អូនចាប់ផ្តើមមើលឃើញឱកាសដែលកន្លងផុតទៅដែលនាំប្អូនខិតកាន់តែជិតទៅរកការសម្រេចបានគោលដៅរបស់ប្អូន។

ប្អូនអាចសម្រេចបានស្ទើរតែទាំងស្រុងនូវគោលដៅណាមួយដែលប្អូនបានកំណត់នៅពេលដែលប្អូនរៀបចំផែនការជាជំហានៗរបស់ប្អូនប្រកបដោយភាពឆ្លាតវៃ និងកំណត់ពេលវេលាដែលអនុញ្ញាត្តិឱ្យប្អូនអនុវត្តជំហានទាំងនោះ។ គោលដៅដែលហាក់ដូចជានៅឆ្ងាយនិងមិនអាចសម្រេចបានកាន់តែខិតមកជិត និងអាចសម្រេចបាន មិនមែនដោយសារគោលដៅរបស់ប្អូនរួមតូចនោះទេ ប៉ុន្តែដោយសារប្អូនមានការរីកចម្រើន និងពង្រីកសកម្មភាពដើម្បីសម្រេចបានគោលដៅទាំងនោះ។ នៅពេលប្អូនធ្វើតារាងគោលដៅរបស់ប្អូន ប្អូនកសាងនូវនិមិត្តរូបផ្ទាល់ខ្លួនរបស់ប្អូន។ ប្អូនមើលឃើញខ្លួនឯងថាមានតម្លៃដោយសារគោលដៅទាំងនេះហើយបង្កើតលក្ខណៈពិសេស និងបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនដែលអាចឱ្យប្អូនទៅដល់គោលដៅទាំងនោះ។

ភាពទាក់ទងគ្នា ៖ ដើម្បីឱ្យមានភាពទាក់ទងគ្នា គោលដៅត្រូវតែតំណាងឱ្យវត្ថុបំណងមួយដែលប្អូនមានទាំង**ឆន្ទៈ** និង**សមត្ថភាព**ធ្វើការងារឆ្ពោះទៅរកវត្ថុបំណងនោះ។ គោលដៅអាចមានលក្ខណៈធំនិងប្រាកដនិយម។ ប្អូនគឺជាមនុស្សតែម្នាក់គត់ដែលអាចសម្រេចចិត្តថាតើគោលដៅរបស់ប្អូនគួរធំប៉ុណ្ណា។ ចូរធានាថារាល់គោលដៅនីមួយៗតំណាងឱ្យវឌ្ឍនភាពសំខាន់ៗ។

គោលដៅធំមួយជាញឹកញាប់មានភាពងាយស្រួលក្នុងការសម្រេចបានជាងគោលដៅតូច ដោយសារគោលដៅតូចតម្រូវឱ្យមានកម្លាំងចិត្តតិចដែរ។ ការងារលំបាកបំផុតមួយចំនួនដែលប្អូនអាចសម្រេចបានហាក់ដូចជាអាចមានភាពងាយស្រួល ដោយសារការងារទាំងនោះជាការងារដែលយើងស្រឡាញ់។

ពេលវេលាកំណត់ ៖ គោលដៅត្រូវមានកាលកំណត់ជាក់លាក់មួយ។ ប្រសិនបើគោលដៅពុំមានកាលកំណត់ជាក់លាក់ទេ នោះវាពុំមានភាពបន្ទាន់ឡើយ។ ប្រសិនបើប្អូនចង់ស្រកទម្ងន់ ៥ គីឡូក្រាម តើប្អូនចង់ស្រកទម្ងន់នោះនៅពេលណា? ពាក្យថា «ថ្ងៃណាមួយ» វាមិនដំណើរការទេ។ ប្រសិនបើប្អូនកំណត់ពេលវេលាជាក់លាក់មួយ ដូចជា «ត្រឹមថ្ងៃទី២១ ខែមិថុនា» ពេលនោះប្អូនបានកំណត់ក្នុងចិត្តដើម្បីចាប់ផ្តើមអនុវត្តលើគោលដៅនោះ។

## ឯកសារអំណានទី៩ ៖ តារាងគំរូ ៖ គោលដៅ «ជ.វ.ស.ទ.ព - S.M.A.R.T.»




S **ជាក់លាក់** ៖ សេចក្តីថ្លែងគោលដៅរបស់ប្អូនត្រូវច្បាស់លាស់ និងគួរឆ្លើយសំណួរទាំង ៦ រួមមាន ៖ អ្វីខ្លះ នរណា ណាមួយ ពេលណា ទីកន្លែងណា មូលហេតុ?

M **អាចវាស់វែងបាន** ៖ កំណត់លក្ខណៈវិនិច្ឆ័យជាក់លាក់សម្រាប់វាស់វែងវឌ្ឍនភាពឆ្ពោះទៅរកគោលដៅដែលប្អូនបានកំណត់។ ដើម្បីកំណត់ថាតើគោលដៅរបស់ប្អូនអាចវាស់វែងបានដែរឬទេ សួរសំណួរដូចជា ៖ (រយៈពេល / ថ្ងៃ) ប៉ុន្មាន? ចំនួនប៉ុន្មាន? តើខ្ញុំនឹងដឹងដោយរបៀបណា នៅពេលដែលខ្ញុំសម្រេចបានគោលដៅនោះ?

A អាចសម្រេចបាន ៖ គោលដៅត្រូវមានភាពលំបាកខ្លះ ប៉ុន្តែអាចសម្រេចបាន។

R **ភាពជាប់ទាក់ទងគ្នា** ៖ គោលដៅត្រូវមានភាពលំបាកខ្លះ ប៉ុន្តែត្រូវតែទាក់ទងនឹងប្អូន។ ប្អូនត្រូវតែមានការលើកទឹកចិត្ត និងមានឆន្ទៈក្នុងការធ្វើការឆ្ពោះទៅរកការសម្រេចបានគោលដៅនោះ។

T **រយៈពេលកំណត់** ៖ គោលដៅត្រូវមានការកំណត់ពេលវេលាថាតើពេលណាដែលប្អូនចង់សម្រេចបាននូវលទ្ធផលរបស់ប្អូន។

**សេចក្តីណែនាំ ៖**

- បង្កើតតារាងពីគោលដៅ«ជ.វ.ស.ជ.ព - S.M.A.R.T. »ដូចបង្ហាញខាងលើ។
- ធានាថា អត្ថបទសរសេរជាអក្សរជិត ហើយអាចមើលឃើញច្បាស់។
- បិទតារាងនៅក្នុងថ្នាក់។

ចំណាំសម្រាប់លោកគ្រូ អ្នកគ្រូ ៖ ផ្លាស់ប្តូរពណ៌នៅក្នុងតារាងខាងលើទៅជា «ជ.វ.ស.ទ.ព - S.M.A.R.T.» ដើម្បីឱ្យត្រូវទៅតាមមេរៀន។

# ជំពូកទី៣ ៖ ជំនាញ(បំណិន)ដែលប្អូនចង់បាន




## ទិដ្ឋភាពទូទៅ

ក្មេងស្រីវ័យជំទង់ឆ្លងកាត់ការប្រែប្រួលផ្នែករាងកាយ និងអារម្មណ៍ជាច្រើន នៅពេលដែលពួកគេឈានពីវ័យជំទង់ទៅជាមនុស្សពេញវ័យ។ ជាមួយនឹងការប្រែប្រួលទាំងនេះ ពួកគេក៏រៀនពុះពារនឹងសម្ពាធនានាពីសាលារៀន ការងារផ្ទះ និងការទទួលខុសត្រូវក្នុងគ្រួសារ។ ជារឿយៗពួកគេមើលឃើញថាខ្លួនឯងស្ថិតក្នុងស្ថានភាពដែលពួកគេត្រូវធ្វើការសម្រេចចិត្តសំខាន់ៗដែលនឹងប៉ះពាល់ដល់ជីវិត និងអនាគតរបស់ពួកគេ។

ចំពោះសិស្សដែលមានអារម្មណ៍ជឿជាក់លើសមត្ថភាពខ្លួនឯងក្នុងការគ្រប់គ្រងជីវិតប្រចាំថ្ងៃរបស់គេ ពួកគេធ្វើការសម្រេចចិត្ត និងធ្វើការលើបំណងប្រាថ្នារបស់ខ្លួន។ ពួកគេចាំបាច់ត្រូវបង្កើតជំនាញដូចជាភាពជាអ្នកដឹកនាំ ការធ្វើសេចក្តីសម្រេចចិត្ត ព្រមទាំងការគ្រប់គ្រងពេលវេលា និងភាពតានតឹង។

មេរៀននេះនឹងផ្តល់ឱកាសឱ្យសិស្សរៀនសូត្រពីជំនាញទាំងនេះតាមវិធីមួយដែលធ្វើឱ្យពួកគេមានអារម្មណ៍កាន់តែប្រាកដលើខ្លួនឯង និងបំណងប្រាថ្នាពេលអនាគតរបស់ពួកគេ ព្រមទាំងមានលទ្ធភាពធ្វើការងារជាប់ជាប្រចាំឆ្ពោះទៅរកការសម្រេចបានគោលដៅនាពេលអនាគតរបស់ខ្លួន។

**រយៈពេលជំពូក ៖ ៣ ម៉ោង**

**ចំនួនលំនាំបង្រៀនសរុប ៖ ៤**

## វត្ថុបំណង

១. ដើម្បីមានលទ្ធភាពយល់ពីការធ្វើសេចក្តីសម្រេចចិត្ត និងថ្លឹងថ្លែងពីផលវិបាកនៃការសម្រេចចិត្តរបស់ពួកគេ។

| |
|---|
| ២. ដើម្បីយល់ពីតម្លៃនៃពេលវេលា និងមានលទ្ធភាពគ្រប់គ្រងពេលវេលារបស់ខ្លួនបានកាន់តែល្អប្រសើរ។ |
| ៣. ដើម្បីអាចកំណត់ពីមូលហេតុនៃភាពតានតឹងក្នុងជីវិតរបស់គេ និងរៀនពីរបៀបគ្រប់គ្រងវា។ |
| ៤. ដើម្បីមើលឃើញពីលក្ខណៈពិសេសនៃភាពជាអ្នកដឹកនាំដែលជាគុណសម្បត្តិដែលគេមានដែលគេអាចអភិវឌ្ឍបន្ថែមទៀត។ |

## មេរៀនទី៥ ៖ តើ កញ្ញា គួរធ្វើអ្វីខ្លះ?[7]

➲ **វត្ថុបំណងមេរៀន ៖** ដើម្បីយល់ពីការធ្វើសេចក្ដីសម្រេចចិត្ត ជំហានទាក់ទងនឹងការធ្វើសេចក្ដីសម្រេចចិត្ត និងសារៈសំខាន់នៃការថ្លឹងថ្លែងពីផលវិបាកនៃការសម្រេចចិត្ត។

**រយៈពេលមេរៀន ៖** ៤៥ នាទី

**សារសំខាន់ៗ ៖**

១. ការធ្វើសេចក្ដីសម្រេចចិត្តមានន័យថា ជាការធ្វើការជ្រើសរើសរវាងជម្រើសជាច្រើន។

២. មនុស្សម្នាក់គួរធ្វើសេចក្ដីសម្រេចចិត្តបន្ទាប់ពីការពិចារណាដោយប្រុងប្រយ័ត្នពីលទ្ធផល និងផលវិបាកដែលអាចកើតមាន។

៣. ការសម្រេចចិត្តត្រូវធ្វើឡើងដោយផ្អែកលើគុណតម្លៃរបស់មនុស្សម្នាក់ ក៏ដូចជាគោលដៅផ្ទាល់ខ្លួន និងវិជ្ជាជីវៈ ក្នុងពេលបច្ចុប្បន្ន និងទៅអនាគត។

### ១. ការរៀបចំ

**សម្ភារៈដែលត្រូវការ ៖**

- សម្រាប់គ្រូបង្រៀន ៖ ក្រដាសផ្ទាំងធំមួយសន្លឹក ក្ដារខៀនហ្វឺត ឬដីស ហ្វឺតលុបមិនជ្រះពណ៌ខ្មៅមួយដើម ស្កុត និងកន្ត្រៃ។
- សម្រាប់សិស្ស ៖ ក្រដាស A4ចំនួន ៤ សន្លឹក សម្ភារៈសរសេរ។

**ការរៀបចំទុកជាមុន ៖**

- អានទិដ្ឋភាពទូទៅរបស់ម៉ូឌុលទី៣ ៖ ជំពូកទី៣«ជំនាញដែលប្អូនចង់បាន» និងឯកសារអំណានទី១០ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន។
- អាន និងយល់ឱ្យច្បាស់ពីលំនាំបង្រៀន។
- រៀបចំ(សរសេរ)សាច់រឿងចំនួន៤ (សូមមើលឯកសារអំណានទី១១ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។
- ប្រមូលសម្ភារៈដែលត្រូវការផ្សេងៗ។
- សរសេរចំណងជើងមេរៀននៅលើក្ដារខៀន។

[7] ដកស្រង់ពីកម្មវិធីសិក្សាសុខភាព និងបំណិនជីវិត AGEP

🗝 **គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- រំឭកសិស្ស ឱ្យចុះវត្តមាន នៅពេលពួកគេចូលថ្នាក់រៀន។
- ប្រសិនបើលោកគ្រូ អ្នកគ្រូឱ្យសិស្សធ្វើកិច្ចការផ្ទះ *(សន្លឹកកិច្ចការទំព័រទី១០០)* នៅពេលបង្រៀនមេរៀនមុន សូមប្រាប់គេឱ្យដាក់សន្លឹកកិច្ចការរបស់ខ្លួននៅលើតុរបស់លោកគ្រូ អ្នកគ្រូមុនពេលចូលរៀន។

## ២. វិធីសាស្ត្របង្រៀន

### សេចក្តីណែនាំ

- ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល «អារម្មណ៍» សិស្សនៅក្នុងថ្នាក់ដោយឱ្យសិស្សប្រើដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតថាមពលរបស់ពួកគេ។
- ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់សង្ខេបអ្វីដែលពួកគេបានរៀននៅម៉ោងមុន។
- ណែនាំសិស្សពីជំពូកទី៣នៃម៉ូឌុលទី៣ (សូមមើលឯកសារអំណានទី១០នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។
- អាន និងចង្អុលចំណងជើងមេរៀននៅលើក្តារខៀន។ ឱ្យសិស្សទាយថាតើមេរៀនថ្ងៃនេះនឹងរៀនពីអ្វី។ សុំឱ្យសិស្សស្ម័គ្រចិត្ត ២-៣នាក់ចែករំលែកពីគំនិតរបស់ពួកគេជាមួយក្រុម។
- ប្រាប់សិស្សថា មេរៀននៅថ្ងៃនេះនឹងជួយពួកគេឱ្យយល់ពីចំណុចដូចខាងក្រោម ៖
  - អត្ថន័យនៃការធ្វើសេចក្តីសម្រេចចិត្ត។
  - ដំណើរការដែលពាក់ព័ន្ធជាមួយនឹងការធ្វើសេចក្តីសម្រេចចិត្ត។
- បែងចែកសិស្សជា៤ក្រុមស្មើៗគ្នា។
- ចែកក្រដាស A4 មួយសន្លឹកដល់ក្រុមនីមួយៗ ប្រដាប់ប្រដាសរសេរ និងសាច់រឿងមួយច្បាប់។
- ឱ្យក្រុមនីមួយៗធ្វើដូចខាងក្រោម ៖
  - អានសាច់រឿងដោយប្រុងប្រយ័ត្ន។
  - ចូលរួមក្នុងការពិភាក្សាលម្អិតពីការសម្រេចចិត្តដែលកញ្ញា ត្រូវធ្វើនៅក្នុងសាច់រឿងដែលផ្តល់ឱ្យ។
  - បំផុសគំនិត និងពិភាក្សាពីជម្រើសខុសៗគ្នា ព្រមទាំងផលវិបាក ឬលទ្ធផលដែលអាចកើតមានរបស់ជម្រើសនីមួយៗ។
  - ឯកភាពគ្នាទៅលើអ្វីដែល កញ្ញា គួរធ្វើនៅក្នុងស្ថានភាពដែលផ្តល់ឱ្យ។

- ប្រាប់សិស្សថា ពួកគេមានពេល ១៥ នាទីដើម្បីបំពេញកិច្ចការនេះ បន្ទាប់មកពួកគេត្រូវធ្វើបទបង្ហាញពីចម្លើយរបស់ខ្លួនទៅដល់ក្រុមផ្សេងទៀត។

**🗝 គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- មេរៀននេះប្រើឈ្មោះ«កញ្ញា»សម្រាប់តួអង្គក្មេងស្រីដែលបានលើកឡើងនៅក្នុងសកម្មភាព។ លោកគ្រូ អ្នកគ្រូអាចប្រើឈ្មោះផ្សេងពីនេះអាស្រ័យលើបរិបទ ឬប្រសិនបើសិស្សមានឈ្មោះដូចគ្នា។
- លើកទឹកចិត្តសិស្ស ឱ្យចែករំលែកទស្សនៈរបស់ខ្លួន និងចូលរួមក្នុងការពិភាក្សាជាក្រុម។
- នៅពេលសិស្ស ចូលរួមក្នុងការពិភាក្សាជាក្រុម ចូរសរសេរសំណួរ៣ (ខាងក្រោម) នៅចំហៀងម្ខាងនៃក្តារខៀនសម្រាប់ក្រុមនីមួយៗដើម្បីមើលនៅពេលធ្វើបទបង្ហាញរបស់ខ្លួន។
- មុនពេលចាប់ផ្តើមធ្វើបទបង្ហាញ សូមកំណត់វិន័យមូលដ្ឋានមួយចំនួនដើម្បីឱ្យសិស្សគ្រប់គ្នាអនុវត្តតាម។ វិន័យទាំងនោះរួមមាន ៖
  - សិស្សម្នាក់ៗត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើអ្នកធ្វើបទបង្ហាញ។
  - សិស្សម្នាក់ៗត្រូវស្តាប់ដោយប្រុងប្រយ័ត្នចំពោះអ្វីដែលអ្នកធ្វើបទបង្ហាញម្នាក់ៗនិយាយ។
  - ហាមនិយាយឆ្លងឆ្លើយគ្នានៅពេលធ្វើបទបង្ហាញជាក្រុម។

## ៣. ការពង្រឹងចំណេះដឹង

**🗣 ចំណុចសម្រាប់ការពិភាក្សា**

☞ ឱ្យសិស្សចូលក្នុងក្រុមធំវិញដើម្បីពិភាក្សា។ ឱ្យសិស្សអង្គុយតាមក្រុមដែលបានកំណត់។

☞ បន្ទាប់មក ឱ្យក្រុមនីមួយៗឡើងធ្វើបទបង្ហាញពីចម្លើយរបស់ខ្លួនម្តងមួយក្រុមៗដល់ក្រុមផ្សេងទៀត ដោយផ្អែកលើសំណួរដែលសរសេរនៅលើក្តារខៀន។

**សំណួរចំនួន៣ ៖**

| | | |
|---|---|---|
| ១. តើមានបញ្ហាអ្វីនៅក្នុងសាច់រឿង? | ២. តើការសម្រេចចិត្តដំបូងដែលកញ្ញាត្រូវធ្វើគឺជាអ្វីបើតាមសាច់រឿង? | ៣. ហេតុអ្វីបានជានាងត្រូវធ្វើការសម្រេចចិត្តនេះ? តើការសម្រេចចិត្តរបស់នាងផ្អែកលើអ្វី? |

☞ សរសេរពាក្យសំខាន់ៗដែលបានពីចម្លើយរបស់ក្រុមនីមួយៗនៅក្រោមផ្នែកចំនួន២ផ្សេងគ្នា ៖

- របៀបដែលក្រុមបានវិភាគពីអ្វីដែលជាទ្វេគ្រោះ។
- មូលដ្ឋានដែលក្រុមប្រើប្រាស់ដើម្បីធ្វើការសម្រេចចិត្ត។

☞ ក្រោយពីធ្វើបទបង្ហាញរួច សូមលើកទឹកចិត្តសិស្សឱ្យវិភាគបន្ថែមលើការសម្រេចចិត្តដែលពួកគេបានធ្វើ។

☞ សួរសំណួរដូចខាងក្រោម ៖

- ◈ តើប្អូនបានគិត និងវិភាគពីផលវិបាកនៃការសម្រេចចិត្តដែលក្រុមរបស់ប្អូនបានលើកឡើងដែរឬទេ?
- ◈ តើវាសមស្របសម្រាប់កញ្ញាដែរឬទេចំពោះស្ថានភាពដែលកញ្ញាមាន? និយាយម្យ៉ាងទៀត តើប្អូនបានគិតឬទេថាតើការសម្រេចចិត្តរបស់ក្រុមប្អូននឹងបង្កគ្រោះថ្នាក់ ឬផលអវិជ្ជមានក្នុងជីវិតរបស់ កញ្ញា ដែរឬទេ?

☞ ទទួលយកចម្លើយ បន្ទាប់មកប្រាប់សិស្សពីរបៀបធ្វើការសម្រេចចិត្តដែលល្អមួយ ៖

- ការសម្រេចចិត្តមួយគឺជាជម្រើសមួយដែលធ្វើឡើងរវាងជម្រើស២ ឬច្រើនដែលអាចមាន។
- យើងទាំងអស់គ្នាធ្វើការសម្រេចចិត្តជារៀងរាល់ថ្ងៃ ហើយនឹងត្រូវធ្វើការសម្រេចចិត្តជាច្រើនទៀតក្នុងជីវិតរស់នៅរបស់យើង។ ការសម្រេចចិត្តរបស់យើងមួយចំនួននឹងមានឥទ្ធិពលលើជីវិតរស់នៅរបស់យើង ដូច្នេះចូរយើងពិនិត្យមើលឱ្យបានដិតដល់លើផ្នែកសំខាន់ៗនៃការធ្វើសេចក្តីសម្រេចចិត្ត ៖
  - ពិនិត្យមើលជាមុន ប្រមើលមើលពីអ្វីដែលអាចនឹងកើតឡើង ប្រសិនបើប្អូនធ្វើអ្វីមួយ។ ចំណុចនេះគេហៅថាការព្យាករណ៍លទ្ធផល ឬការយល់ពីផលវិបាកផ្សេងៗ។ ការដែលប្អូនព្យាករណ៍បានកាន់តែល្អ ប្អូននឹងធ្វើការសម្រេចចិត្តបានកាន់តែល្អចំពោះលទ្ធផល ឬផលវិបាកដែលប្អូនចង់បាន។
  - ការធ្វើសេចក្តីសម្រេចចិត្តត្រូវតែធ្វើឡើងដោយគិតគូរជានិច្ចពីពេលវេលា ទីកន្លែង និងស្ថានភាព។
  - ការសម្រេចចិត្តអាចមានទាំងរយៈពេលខ្លី និងរយៈពេលវែង។ ពេលខ្លះយើងប្រហែលជាចាំបាច់ត្រូវធ្វើការសម្រេចចិត្តមួយដែលមិនសូវមានការពេញចិត្តដោយដឹងថាវានឹងជួយយើងឱ្យធ្វើការសម្រេចចិត្តមួយដែលយើងពេញចិត្តទៅថ្ងៃក្រោយ។

☞ សួរសំណួរដូចខាងក្រោម ៖

- ◈ តើមានជំហានសំខាន់ៗអ្វីខ្លះសម្រាប់ធ្វើសេចក្តីសម្រេចចិត្តមួយដែលល្អ?

☞ ទទួលយកចម្លើយ បន្ទាប់មកចែករំលែកដូចចំណុចខាងក្រោម ៖

- គិតឱ្យបានច្បាស់លាស់ និងដោយស្ងៀមស្ងាត់ ពីបញ្ហា ស្ថានភាព ឬចំណុចបញ្ហាដែលត្រូវការធ្វើការសម្រេចចិត្ត។
- ស្វែងរកព័ត៌មានបន្ថែម ប្រសិនបើប្អូនមានចម្ងល់ពីស្ថានភាពនោះ។
- គិតពីផលវិបាក ឬលទ្ធផលដែលអាចកើតមានសម្រាប់ការអនុវត្តន៍សកម្មភាពនីមួយៗ។
- គិតពីមូលហេតុនៃការជំទាស់ដែលប្អូនអាចមានទាក់ទងនឹងការសម្រេចចិត្តដែលប្អូនត្រូវធ្វើដោយផ្អែកលើគោលការណ៍ និងជំនឿផ្ទាល់ខ្លួន។
- ជ្រើសរើសការសម្រេចចិត្តដែលហាក់ដូចជាសមស្របបំផុតដោយយោងលើចំណេះដឹង គុណតម្លៃ ព្រមទាំងគោលដៅបច្ចុប្បន្ន និងអនាគត។
- គិតដោយប្រុងប្រយ័ត្នពីជម្រើសទាំងអស់ និងមានអារម្មណ៍ស្រួលក្នុងចិត្តជាមួយនឹងជម្រើសចុងក្រោយដែលប្អូនសម្រេច។

☞ គិតពីវិធីដែលសមស្របបំផុតក្នុងការប្រាប់ពីការសម្រេចចិត្តនោះទៅបុគ្គលដែលពាក់ព័ន្ធ។ ចូរចងចាំជានិច្ចពីឱកាស ពេលវេលា និងកាលៈទេសៈសមស្របនានាដើម្បីធ្វើឱ្យប្រាកដថាមនុស្សម្នាក់មានលទ្ធភាពដោះស្រាយស្ថានភាពនានាប្រកបដោយប្រសិទ្ធភាព។

☞ ប្រសិនបើមានពេល សូមបញ្ចប់មេរៀនដោយសរុបនូវអ្វីដែលបានរៀនពីមេរៀននេះ។

**🗝 គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូ ៖

- មុនពេលសិស្សបំបែកគ្នា ត្រូវធានាថាលោកគ្រូ អ្នកគ្រូបានទទួលសន្លឹកកិច្ចការទាំងអស់ពីសិស្ស *(ប្រសិនបើអាចធ្វើទៅបាន)*។

# សំណុំឯកសារសម្រាប់គ្រូបង្រៀន

## ឯកសារអំណានទី១០ ៖ ឯកសារអំណានសម្រាប់គ្រូបង្រៀន

**បរិបទចំណេះដឹង ៖ គន្លឹះសម្រាប់គ្រូបង្រៀន**

១. លោកគ្រូ អ្នកគ្រូត្រូវមានចិត្តទូលាយ និងមិនលម្អៀងដោយត្រូវគោរពចំពោះចម្លើយរបស់សិស្ស ព្រោះថាមិនមានចម្លើយជាក់លាក់ដែលអាចត្រូវនឹងសាច់រឿងទេ។

២. សាច់រឿងនីមួយៗត្រូវធ្វើឡើងដោយផ្អែកទៅតាមករណីនីមួយៗ និងទៅតាមការយល់ឃើញដែលក្មេងស្រីនឹងមានចម្លើយខុសៗគ្នាដោយផ្តោតលើទស្សនៈផ្សេងៗគ្នា និងបរិបទ ឬបទពិសោធន៍ខុសគ្នា។

៣. លោកគ្រូ អ្នកគ្រូ ក៏ត្រូវមានការប្រុងប្រយ័ត្នដែរដើម្បីជៀសវាងពីការវិនិច្ឆ័យផ្ទាល់ខ្លួននៅពេលមានការពិភាក្សាជាមួយក្រុម។

៤. លោកគ្រូ អ្នកគ្រូ ត្រូវចងចាំជានិច្ចថា នេះគឺជាលំហាត់ដ៏សំខាន់មួយសម្រាប់សិស្ស ដោយសារពួកគេអនុវត្តជំនាញដោះស្រាយបញ្ហារបស់គេដែលលោកគ្រូ អ្នកគ្រូបានបង្រៀនពួកគេនៅក្នុងជំពូកមុនៗ។

សន្ទានុក្រមពាក្យបច្ចេកទេស

- **ផលវិបាក** ៖ រឿងល្អ ឬអាក្រក់ដែលអាចបណ្តាលមកពីការសម្រេចចិត្ត ឬសកម្មភាពមួយ។
- **ការសម្រេចចិត្ត** ៖ ការជ្រើសរើសមួយរវាងជម្រើសពីរ ឬច្រើន។
- **ការធ្វើសេចក្តីសម្រេចចិត្ត** ៖ ដំណើរការនៃការឈានដល់ការសម្រេចចិត្តមួយ។
- **ដំណើរការ** ៖បណ្តុំសកម្មភាព ឬជំហានជាបន្តបន្ទាប់ដែលគេធ្វើឡើងដើម្បីសម្រេចបានអ្វីមួយ។
- **គុណតម្លៃ** ៖ គុណតម្លៃគឺជាគោលការណ៍ទាំងឡាយណាដែលគេជឿថាមានសារៈសំខាន់ចំពោះរបៀបដែលគេរស់នៅមិនថាវាជាជីវិតផ្ទាល់ខ្លួន ការសិក្សា ឬវិជ្ជាជីវៈរបស់គេឡើយ។

## ឯកសារអំណានទី១០ ៖ ឯកសារអំណានសម្រាប់គ្រូបង្រៀន (ត)

**បរិបទចំណេះដឹង ៖ កំណាត់ចំណាំបន្ថែមសម្រាប់គ្រូបង្រៀន**

មេរៀននេះមានបំណងបង្រៀនសិស្សពីរបៀបដែលគេត្រូវដោះស្រាយស្ថានភាពមួយដែលគេត្រូវធ្វើការសម្រេចចិត្ត។ ផ្នែកផ្សេងទៀតក្រៅពីចំណុចដែលបានបញ្ជាក់ខាងលើ លោកគ្រូ អ្នកគ្រូត្រូវបញ្ជាក់ពីប្រភេទខុសៗគ្នានៃជំនាញ(បំណិន)ដែលយើងត្រូវការដើម្បីធ្វើការសម្រេចចិត្តមួយដូចដែលបានរៀននៅមេរៀនមុន។

លោកគ្រូ អ្នកគ្រូអាចប្រើកំណត់ចំណាំខាងក្រោមដើម្បីផ្តល់ឧទាហរណ៍ពីការប្រើជំនាញដែលបានរៀនចំពោះការធ្វើសេចក្តីសម្រេចចិត្ត។ កំណត់ចំណាំនេះគូសបញ្ជាក់ពីជំនាញជាក់លាក់ និងភ្ជាប់ទៅនឹងសាច់រឿងជាក់លាក់ដែលគេផ្តល់ឱ្យសិស្ស។

លោកគ្រូ **អ្នកគ្រូត្រូវចងចាំជានិច្ចនូវចំណុចខាងក្រោម នៅពេលពិភាក្សាពីសាច់រឿង ៖**

- **ទំនួលខុសត្រូវ និងការកំណត់អាទិភាពរួមគ្នា ៖**

  ជាញឹកញាប់ គេរំពឹងទុកថាក្មេងស្រីត្រូវចូលរួមរៀបចំម្ហូបអាហារដើម្បីទទួលភ្ញៀវដែលមកលេងផ្ទះរបស់គេ ឬត្រូវចូលរួមធ្វើកិច្ចការប្រចាំថ្ងៃក្នុងគ្រួសារ ដោយត្រូវកាត់បន្ថយការគិតគូរពីអាទិភាពផ្ទាល់ខ្លួនរបស់គេ។ វាមានសារៈសំខាន់សម្រាប់ កញ្ញា ក្នុងការប្រាប់ម្តាយនាង ឬបងរបស់នាងពីមូលហេតុដែលវាមានសារៈសំខាន់ចំពោះនាងក្នុងការធ្វើអ្វីមួយដែលនាងចូលចិត្តស្របពេលដែលនាងក៏ត្រូវយកចិត្តទុកដាក់ចំពោះទំនួលខុសត្រូវរបស់នាងនៅក្នុងផ្ទះដែរ។ ក្នុងពេលជាមួយគ្នានេះ នាងអាចចាប់ផ្តើមសាកល្បងនិយាយជាមួយបងប្រុសរបស់នាងដើម្បីឱ្យគាត់ជួយនាង ដូច្នេះនាងមានពេលវេលាដើម្បីធ្វើអ្វីដែលនាងចង់ធ្វើ ហើយគាត់ក៏ដូចគ្នាដែរ។ នៅក្នុងសាច់រឿងនេះ នៅពេលដែល កញ្ញា ត្រូវត្រៀមខ្លួនសម្រាប់ការប្រឡង វាគួរតែជា អាទិភាពរបស់នាង។ នាងចាំបាច់ត្រូវនិយាយពីរឿងនេះជាមួយជីដូន និងម្តាយរបស់នាង ហើយប្រាប់ពួកគាត់ពីមូលហេតុដែលវាមានសារៈសំខាន់ចំពោះនាងក្នុងការរៀនសូត្រនៅដំណាក់កាលនេះ។ ទំនួលខុសត្រូវក្នុងគ្រួសារគឺជាកិច្ចការរួម ហើយជាបណ្តើរៗ កញ្ញានឹងមានលទ្ធភាពបង្កើតបានទម្លាប់មួយនៅក្នុងគ្រួសារដោយមិនគំរាមកំហែងដល់អារម្មណ៍របស់នរណាម្នាក់ឡើយ។

- **វាជាការសំខាន់ដែលត្រូវនិយាយថា ទេ «គិត! ប្រតិកម្ម! និងធ្វើសកម្មភាព!»**

  គួរឱ្យសោកស្តាយ ដែលការបៀតបៀនផ្លូវភេទនៅកន្លែងសាធារណៈគឺជាទម្រង់ធម្មតាបំផុតនៃអំពើហិង្សា។ គេ«បង្រៀន»ក្មេងស្រីភាគច្រើនមិនឱ្យរវល់ពីការបៀតបៀនផ្លូវភេទនៅតាមផ្លូវ។ ពេលខ្លះពួកគេក៏មិនរវល់នឹងវាដែរដោយសារតែការភ័យខ្លាចពីការសងសឹក កង្វះការគាំទ្រពីសាធារណៈជន និងការកាត់បន្ថយសេរីភាពដើរហើរពីសំណាក់គ្រួសារ និងមិត្តភក្តិ។ ទោះជា

យ៉ាងនេះក្តី នៅក្នុងសាច់រឿងទី២ និងសាច់រឿងស្រដៀងៗគ្នានេះវាមានសារៈសំខាន់ដែល កញ្ញា ដឹងថា វាមិនមែនជាកំហុសរបស់នាងទេ។ ពេលខ្លះ នៅក្នុងស្ថានភាពបែបនោះ ការនិយាយថា«ទេ»ខ្លាំងៗពិតជាមានប្រយោជន៍ណាស់។ ប្រសិនបើស្ថិតនៅតាមទីសាធារណៈដែលមានមនុស្សច្រើន គេអាចទាញការចាប់អារម្មណ៍ និងចែករំលែកវាជាមួយអ្នកដែលនៅក្បែរៗនោះ។ វាមានសារៈសំខាន់ដែលត្រូវចូលរួមជាមួយមនុស្សនៅជុំវិញប្អូន។ តាមអ្វីដែលគ្រួសារមានការបារម្ភ ការភ័យខ្លាចធំបំផុតមួយក្នុងចំណោមការភ័យខ្លាចនានាចំពោះការរិះគន់ចេញមកពីពួកគេ។ និយាយយ៉ាងដូច្នេះ វាមានសារៈសំខាន់ក្នុងការចងចាំពីសារៈសំខាន់នៃការចែករំលែកពីឧបទ្ទវហេតុ និងអារម្មណ៍ដែលប្អូនមានពីឧបទ្ទវហេតុនេះជាមួយមិត្តភក្តិ និងគ្រួសារ។ មានពេលជាច្រើនដែលក្មេងស្រីមិនបានបង្ហាញពីអារម្មណ៍របស់ខ្លួន ក្រោយពីមានឧបទ្ទវហេតុមួយដូចនេះ។ ការនិយាយ និងការចែករំលែកជាមួយមនុស្សដែលជិតស្និតនឹងប្អូនធ្វើឱ្យប្អូនបានធូរស្បើយផ្លូវចិត្ត និងជួយប្អូនបង្កើតប្រព័ន្ធគាំទ្រមួយសម្រាប់ខ្លួនឯង។

- **ពិចារណាពីពេលវេលា ទីកន្លែង និងស្ថានភាព ៖** ទម្រង់ណាមួយនៃអំពើហិង្សាក្នុងគ្រួសារក៏ប៉ះពាល់ដល់កូនៗដែរ។ នៅក្នុងស្ថានភាពនេះ កញ្ញា អាចរង់ចាំឱ្យស្ថានភាពរវាងឪពុកម្តាយរបស់នាងវិលទៅរកភាពប្រក្រតីសិនមុនពេលនាងនិយាយជាមួយពួកគាត់។ នាងអាចខិតខំយកចិត្តទុកដាក់រៀបចំតែសម្រាប់ឪពុកម្តាយនាងនៅពេលពួកគាត់ត្រជាក់ចិត្តបន្តិច ឬទុកពេលឱ្យពួកគាត់និយាយរកគ្នាវិញសិន។ នៅពេលអ្វីៗត្រលប់ទៅរកភាពប្រក្រតីវិញហើយ កញ្ញាអាចប្រាប់ពីគំនិតរបស់នាងពីការរៀនសូត្រដល់ឪពុក ឬម្តាយ ឬពួកគាត់ទាំងពីរនាក់។ នាងអាចពន្យល់ពីមូលហេតុដែលវាមានសារៈសំខាន់សម្រាប់នាងក្នុងការចូលហាត់របាំ។ នាងក៏អាចធានាចំពោះពួកគាត់ដោយប្រាប់ថា មិត្តភក្តិនាងជាច្រើននាក់បានចុះឈ្មោះចូលរៀនដែរ ដូច្នេះហើយវាអាចមានសុវត្ថិភាពសម្រាប់នាងក្នុងការដើរត្រឡប់មកផ្ទះវិញជាមួយពួកគេនៅពេលព្រលប់។ ការធ្វើបែបនេះក៏នឹងផ្តល់សុពលភាពដល់សំណើសុំរបស់នាងដែរ។ ឪពុកម្តាយនាងអាចពិចារណាប្រសិនបើទីតាំងនោះមើលទៅសមស្រប ហើយប្រសិនបើមនុស្សជាច្រើនដែលពួកគេស្គាល់បានចូលហាត់របាំដែលកញ្ញាអាចមកផ្ទះវិញដោយសុវត្ថិភាព។

**គន្លឹះសម្រាប់គ្រូបង្រៀន ៖** លោកគ្រូ អ្នកគ្រូត្រូវបើកចិត្តឱ្យទូលាយ និងមិនលម្អៀងដោយត្រូវគោរពចំពោះចម្លើយរបស់សិស្សព្រោះមិនមានចម្លើយជាក់លាក់ដែលអាចត្រូវនឹងស្ថានភាពដែលមានទាំងអស់ទេ។

## ឯកសារអំណានទី ១១ ៖ ប័ណ្ណឈុត

### សាច់រឿងទី ១ ៖ ក្រុម ១

**ប្រធានបទ ៖ ទំនួលខុសត្រូវក្នុងផ្ទះ និងការសិក្សា**

កញ្ញាជាក្មេងស្រីរៀនថ្នាក់ទី១១។ សប្តាហ៍នេះគឺជាសប្តាហ៍ដែលនាងត្រូវប្រឡង ហើយនាងត្រូវប្រឡងគណិតវិទ្យានៅថ្ងៃស្អែក ដែលជាមុខវិជ្ជាដែលនាងចាំបាច់ត្រូវខំរៀន។ នៅពេលដែលនាងទៅដល់ផ្ទះភ្លាម នាងរៀបចំទៅកាន់បន្ទប់របស់នាងដើម្បីរៀន។ បន្តិចក្រោយមកមានសាច់ញាតិខ្លះ បានមកលេងគ្រួសារនាង។ ជីដូន និងម្តាយ របស់ កញ្ញា បានឱ្យនាងទៅជួយរៀបចំអាហារ និងសម្អាតផ្ទះ។ បងប្អូនប្រុស កញ្ញាកំពុងលេងជាមួយមិត្តភក្តិរបស់គាត់នៅឯទីលានមុខផ្ទះ។

**តើ កញ្ញា គួរធ្វើដូចម្តេច?**

### សាច់រឿងទី ២ ៖ ក្រុម ២

**ប្រធានបទ ៖ ការដោះស្រាយការបៀតបៀន**

កញ្ញាជាក្មេងស្រីរៀននៅថ្នាក់ទី១១។ ថ្ងៃមួយនៅពេលនាងចេញពីសាលាត្រលប់មកផ្ទះវិញ ក្មេងប្រុសមួយក្រុមដែលឈរនៅតាមផ្លូវចាប់ផ្តើមស្រែកហៅនាងដោយប្រើពាក្យអាសគ្រាម។ នៅពេលនាងដើរកាត់ពួកគេ ពួកគេចាប់ផ្តើមដើរតាមនាង។ កញ្ញាដើរកាន់តែលឿនដើម្បីឱ្យឆាប់ទៅដល់ផ្ទះ។ ក្រោយពីជួបការបៀតបៀននេះ នាងបានទៅដល់ផ្ទះដោយមើលទៅមានភាពភិតភ័យ និងច្របូកច្របល់។ ឪពុករបស់នាងនៅផ្ទះនៅពេលនោះ ហើយបានសួរនាងថាតើមានរឿងអ្វីកើតឡើង។

ប្រសិនបើកញ្ញាប្រាប់ឪពុកនាងថា នាងត្រូវបានគេបៀតបៀន នោះឪពុកនាងអាចនឹងឈប់ឱ្យនាងទៅសាលារៀន ហើយនាងមិនចង់មានរឿងបែបនេះទេ។ ប៉ុន្តែនាងចង់ប្រាប់ឪពុករបស់នាងពីរឿងនេះដើម្បីឱ្យគាត់អាចជួយនាងបាន។

**តើ កញ្ញា គួរធ្វើដូចម្តេច?**

### សាច់រឿងទី ៣ ៖ ក្រុម ៣

**ប្រធានបទ ៖ ការដើរហើរ**

កញ្ញាជាក្មេងស្រីរៀននៅថ្នាក់ទី១១។ សាលារបស់នាងបានប្រកាសពីថ្នាក់របាំ និងសម្តែងដែលចាប់ផ្តើមនៅក្នុងសាលារៀនចាប់ពីម៉ោង៦ល្ងាចដល់ម៉ោង៨យប់ជារៀងរាល់ថ្ងៃកញ្ញាចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការចុះឈ្មោះចូលរៀនថ្នាក់របាំនោះ។ ប៉ុន្តែ ជាច្បាប់ នាងមិនត្រូវបានអនុញ្ញាតឱ្យចេញក្រៅផ្ទះក្រោយម៉ោង៧យប់ទេ។ ថ្ងៃនោះកញ្ញាបានចេញពីសាលាមកផ្ទះរួមជាមួយនឹងពាក្យសុំចុះឈ្មោះ។ ហើយស្អែកគឺជាថ្ងៃចុងក្រោយសម្រាប់ការដាក់ពាក្យនេះ។

នៅពេល កញ្ញា ចូលទៅដល់ផ្ទះនាងឃើញថាឪពុកម្តាយនាងកំពុងតែឈ្លោះគ្នាយ៉ាងខ្លាំងហើយបរិយាកាសនាពេលនោះក៏មានសភាពតានតឹងដែរ។ កញ្ញាមិនប្រាកដថា តើនាងគួរនិយាយពីការហាត់របាំនៅក្នុងស្ថានភាពនេះដែរឬទេ។ ប៉ុន្តែនាងពិតជាចង់ចុះឈ្មោះណាស់ ហើយកាលបរិច្ឆេទចុងក្រោយសម្រាប់ការដាក់ពាក្យគឺនៅថ្ងៃស្អែក។

**តើ កញ្ញា គួរធ្វើដូចម្តេច?**

### សាច់រឿងទី ៤ ៖ ក្រុម ៤

**ប្រធានបទ ៖ ការអប់រំនៅកម្រិតឧត្តមសិក្សា**

កញ្ញាជាក្មេងស្រីរៀននៅថ្នាក់ទី១១។ នាងជាសិស្សពូកែ ហើយនាងប្រាថ្នាចង់ក្លាយជាអ្នកវិទ្យាសាស្ត្រ។

នាងចង់រៀនបន្តថ្នាក់ឧត្តមសិក្សា និងរៀនយកបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រក្នុងនាមជាសិស្សធម្មតាម្នាក់។

ទោះជាយ៉ាងនេះក្តី ឪពុកម្តាយរបស់នាងធ្លាប់ប្រាប់នាងថា ក្មេងស្រីនៅក្នុងគ្រួសាររបស់គេត្រូវរៀបការនៅចន្លោះពីអាយុ១៥ ទៅ ១៧ ឆ្នាំ។ ឪពុកម្តាយរបស់នាងបានចាប់ផ្តើម រកមើលគូស្រករដែលសមស្របនឹងនាងរួចហើយ។ ក្រៅពីនេះសមាជិកចាស់ៗនៅក្នុងគ្រួសារមិនអនុញ្ញាតឱ្យកូនស្រីទៅឆ្ងាយដូចជាទៅទីក្រុងដើម្បីចូលរៀនមហាវិទ្យាល័យទេ។ ប៉ុន្តែកញ្ញាប្រាកដក្នុងចិត្តណាស់ថា នាងចង់រៀនបន្ថែម ហើយមិនចង់រៀបការមុនអាយុ២៥ឆ្នាំទេ។

**តើ កញ្ញា គួរធ្វើដូចម្តេច?**

**សេចក្តីណែនាំ ៖**

- បត់ក្រដាសផ្ទាំងធំទៅជា៤ផ្នែកស្មើគ្នា។
- លាក្រដាសឡើងវិញ។
- កាត់ក្រដាសតាមស្នាមបត់ជា៤ផ្ទាំងដើម្បីសរសេរសាច់រឿងចំនួន៤។
- សរសេរសាច់រឿងមួយនៅលើក្រដាសមួយដូចដែលបង្ហាញខាងលើ។
- យកក្រដាសសាច់រឿងនេះមកជាមួយលោកគ្រូ អ្នកគ្រូដើម្បីធ្វើលំហាត់នេះ។

# មេរៀនទី៦ ៖ ការគ្រប់គ្រងពេលវេលា

➲ **វត្ថុបំណងមេរៀន ៖** ដើម្បីយល់ពីតម្លៃពេលវេលា និងរៀនពីរបៀបគ្រប់គ្រងវាឱ្យកាន់តែមានប្រសិទ្ធភាព។

🕒 **រយៈពេលមេរៀន ៖** ៤៥ នាទី

**✉ សារសំខាន់ៗ ៖**

១. មនុស្សគ្រប់រូបមានពេលវេលាចំនួន២៤ម៉ោងក្នុងមួយថ្ងៃ ហើយប្អូនចង់ប្រើប្រាស់ពេលវេលារបស់ប្អូនដោយរបៀបណាគឺអាស្រ័យទៅលើប្អូន។

២. ដើម្បីអាចគ្រប់គ្រងពេលវេលារបស់ប្អូនឱ្យមានប្រសិទ្ធភាព ប្អូនត្រូវមានលទ្ធភាពបែងចែកឱ្យដាច់រវាងកិច្ចការបន្ទាន់ និងកិច្ចការសំខាន់ ព្រមទាំងកំណត់អាទិភាពវាទៅតាមនោះ។

៣. ការគ្រប់គ្រងពេលវេលាប្រកបដោយប្រសិទ្ធភាពមានន័យថា ការរៀបចំផែនការជាមុនសម្រាប់ថ្ងៃ ឬសប្តាហ៍របស់ប្អូនដើម្បីដាក់បញ្ចូលទាំងកិច្ចការបន្ទាន់ និងសំខាន់។

## ១. ការរៀបចំ

**📖 សម្ភារៈដែលត្រូវការ ៖**

☞ សម្រាប់គ្រូបង្រៀន ៖ ក្ដារខៀន និងហ្វឺត ឬដីស។

☞ សម្រាប់សិស្ស ៖ សន្លឹកកិច្ចការ ៖ កិច្ចការក្នុងថ្នាក់ទំព័រទី១០១ និងទី១០២ សម្ភារៈសរសេរ។

**ការរៀបចំទុកជាមុន ៖**

☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។

☞ ប្រមូលសម្ភារៈដែលត្រូវការផ្សេងៗទៀតទាំងអស់។

☞ សរសេរចំណងជើងមេរៀនលើក្ដារខៀន។

**🗝 គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- រំឭកសិស្សឱ្យចុះវត្តមានរបស់ខ្លួនពេលពួកគេចូលរៀន។
- ឱ្យសិស្សម្នាក់ៗយកសន្លឹកកិច្ចការរបស់ខ្លួន និងសម្ភារៈសរសេរមុនពេលចូលរៀន។

## ២. ដំណើរការបង្រៀន

### សេចក្តីណែនាំ

- ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល«អារម្មណ៍»សិស្សនៅក្នុងថ្នាក់ដោយឱ្យសិស្សប្រើដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតថាមពលរបស់ពួកគេ។
- ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់សង្ខេបអ្វីដែលពួកគេបានរៀននៅម៉ោងមុន។
- អាន និងចង្អុលចំណងជើងមេរៀននៅលើក្តារខៀន។ ឱ្យសិស្សទាយថាតើមេរៀនថ្ងៃនេះនឹងរៀនពីអ្វី។ ឱ្យសិស្សស្ម័គ្រចិត្ត ២-៣នាក់ចែករំលែកពីគំនិតរបស់ពួកគេជាមួយក្រុម។
- ប្រាប់សិស្សថា មេរៀននៅថ្ងៃនេះនឹងផ្តោតលើចំណុចដូចខាងក្រោម ៖
  - ពេលវេលាជាធនធានមានតម្លៃអ្វីម្ល៉េះទេ!
  - របៀបដែលគេគ្រប់គ្រងពេលវេលារបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព។

កិច្ចការក្នុងថ្នាក់

**កិច្ចការក្នុងថ្នាក់ ៖**

- ឱ្យសិស្សបើកសន្លឹកកិច្ចការរបស់ខ្លួននៅទំព័រទី១០១។
- ផ្តល់ការណែនាំដូចខាងក្រោម ៖
  - ធ្វើការងារលើនាឡិកាទី១ ៖ បែងចែកនាឡិកានោះជា៤ផ្នែកដែលមានរយៈពេល៣ៗម៉ោងដោយផ្អែកលើពេលវេលានៃការចាប់ផ្តើមជាទូទៅរបស់ប្អូនក្នុងមួយថ្ងៃៗ។ ឧទាហរណ៍ ប្រសិនបើថ្ងៃរបស់ប្អូនចាប់ផ្តើមនៅម៉ោង៦:០០ព្រឹក នោះចំណែកម៉ោងដំបូងរបស់ប្អូនគឺពីម៉ោង៦:០០ព្រឹកដល់ម៉ោង៩:០០ព្រឹក ចំណែកម៉ោងទី២របស់ប្អូនគឺពីម៉ោង៩:០០ព្រឹកដល់ម៉ោង១២:០០ថ្ងៃត្រង់ ចំណែកម៉ោងទី៣របស់ប្អូនគឺពីម៉ោង១២:០០ថ្ងៃត្រង់ដល់ម៉ោង ៣:០០រសៀល និងចំណែកម៉ោងទី៤របស់ប្អូនគឺពីម៉ោង៣:០០រសៀលដល់ម៉ោង៦:០០ល្ងាច។
  - បន្ទាប់មក សរសេរពីសកម្មភាពទាំងអស់ដែលប្អូនធ្វើនៅក្នុងចំណែកម៉ោងនីមួយៗទោះតិចក្តីច្រើនក្តី។ ឧទាហរណ៍ នៅក្នុងចំណែកម៉ោងទីមួយគឺពីម៉ោង៦៖០០ដល់ម៉ោង៩:០០ព្រឹក អាចមានសកម្មភាពដូចជា រៀបចំខ្លួនទៅសាលា រៀបចំអាហារពេលព្រឹក ដើរទៅសាលាជាដើម។ ស្រដៀងគ្នានេះដែរ នៅក្នុងចំណែកម៉ោងទី៣គឺពីម៉ោង១២:០០ថ្ងៃត្រង់ដល់ម៉ោង៣:០០រសៀល សកម្មភាពអាចរួមមានការញ៉ាំអាហារថ្ងៃត្រង់ ដើរត្រឡប់ពីសាលារៀនវិញ ការបញ្ចប់កិច្ចការសាលា ការដើរលេង ការរៀនគួរជាដើម។
  - ប្រាប់សិស្សថា គេមានពេល៥នាទីដើម្បីបំពេញកិច្ចការនេះ។

កិច្ចការក្នុងថ្នាក់

**កិច្ចការក្នុងថ្នាក់ ៖**

☞ នៅពេលសិស្សបានបញ្ចប់កិច្ចការរបស់ខ្លួននៅទំព័រ១០១ ហើយឱ្យសិស្សផ្តោតលើសន្លឹកកិច្ចការនៅទំព័រ១០២។

☞ ផ្តល់ការណែនាំដូចខាងក្រោម ៖

– ចែកនាឡិកាទី២របស់ប្អូនទៅជា៤ចំណែកដូចដែលប្អូនបានធ្វើមុននេះនៅទំព័រទី១០២។

– នៅក្នុងនាឡិកាទី២ ចូរសរសេរកិច្ចការនៅក្នុងចំណែកម៉ោងនីមួយៗដែលប្អូនចង់ធ្វើ ប៉ុន្តែមិនមានពេលធ្វើវាទេ។ ឧទាហរណ៍ សកម្មភាពទាំងនេះអាចមានដូចជា ការទៅផ្ទះមិត្តភក្តិ ទៅផ្សារ មើលទូរទស្សន៍ គេងថ្ងៃត្រង់មួយភ្លែត ការអានសៀវភៅ ការទៅរៀនរបាំជាដើម។

– ប្រាប់គេថា គេមានពេល៥នាទីដើម្បីបំពេញកិច្ចការនេះ។

## ៣. ការពង្រឹងចំណេះដឹង

### 🗣 ចំណុចសម្រាប់ការពិភាក្សា

☞ សួរសំណួរដូចខាងក្រោម ៖

– តើកិច្ចការមួយចំនួនក្នុងចំណោមកិច្ចការនានានៅក្នុងនាឡិកាទី២ដែលប្អូនបានកំណត់ថាជាកិច្ចការបន្ទាន់ និងសំខាន់ ហើយចង់ធ្វើវា ប៉ុន្តែមិនមានពេលនៅក្នុងជីវិតប្រចាំថ្ងៃរបស់ប្អូនមានអ្វីខ្លះ?

☞ ទទួលយកចម្លើយ បន្ទាប់មកសួរដូចខាងក្រោម ៖

◈ តើប្អូនអាចធ្វើអ្វីបានខ្លះដើម្បីផ្លាស់ប្តូររឿងនេះ?

◈ តើគេអាចធ្វើអ្វីបានខ្លះដើម្បីធ្វើឱ្យមានពេលវេលាសម្រាប់កិច្ចការដែលប្អូនគិតថាបន្ទាន់ និងមានសារៈសំខាន់ ហើយចង់ធ្វើវា?

☞ ទទួលយកចម្លើយ បន្ទាប់មកពន្យល់ដូចខាងក្រោម ៖

– ប្អូនមិនអាចបង្កើតពេលវេលាបន្ថែមទៀតបានទេ ដោយសារមានការកំណត់ចំនួនម៉ោងមួយក្នុងមួយថ្ងៃៗដែលមានសម្រាប់ប្អូន។

– ទោះជាយ៉ាងនេះក្តីប្អូនអាចគ្រប់គ្រងពេលវេលារបស់ប្អូនឱ្យកាន់តែល្អបានដើម្បីបញ្ចូលសកម្មភាពនានាដែលប្អូនគិតថាសំខាន់ ឬបន្ទាន់ ហើយដែលប្អូនពិតជាចង់ធ្វើវានោះ។

– ដើម្បីមានលទ្ធភាពគ្រប់គ្រងពេលវេលារបស់ប្អូនមានប្រសិទ្ធភាព ប្អូនត្រូវមានលទ្ធភាពបែងចែកឱ្យដាច់ពីគ្នារវាងកិច្ចការដែលសំខាន់ និងកិច្ចការដែលបន្ទាន់។

– មនុស្សគ្រប់រូបមានកិច្ចការដែលពួកគេពិតជាចង់ធ្វើនៅតាមថ្ងៃនីមួយៗ។ ប៉ុន្តែ ពេលវេលាក្នុងមួយថ្ងៃៗក៏តម្រូវឱ្យយើងបំពេញកិច្ចការ ឬសកម្មភាពមួយចំនួនជាប្រចាំថ្ងៃផងដែរ។ ដូច្នេះ ដើម្បីធ្វើឱ្យមានតុល្យភាពចំពោះលទ្ធភាពគ្រប់គ្រងពេលវេលារបស់យើងឱ្យមានប្រសិទ្ធភាព យើងត្រូវយល់ពីការបែងចែកដូចខាងក្រោម ៖

  - **កិច្ចការសំខាន់** ជាទូទៅទាក់ទងទៅនឹងគោលដៅជីវិតរបស់មនុស្សម្នាក់ដែលតាមធម្មតាមានរយៈពេលវែង និងមានលក្ខណៈយុទ្ធសាស្រ្ត។ ឧទាហរណ៍ ប្រសិនបើគោលដៅរយៈពេលវែងរបស់ក្មេងស្រីម្នាក់គឺត្រូវចូលរួមប្រឡងប្រកួតប្រជែងក្រោយពីបញ្ចប់ការអប់រំនៅវិទ្យាល័យរបស់ខ្លួន ហើយនាងត្រូវការពង្រឹងជំនាញភាសាអង់គ្លេស និងជំនាញទូទៅរបស់នាង នាងត្រូវបណ្តុះទម្លាប់ក្នុងការអានសារព័ត៌មានឱ្យបានមួយម៉ោងជារៀងរាល់ថ្ងៃ។ ការប្រឡង និងការកសាងជំនាញក្នុងការឆ្លើយឆ្លងដែលគេត្រូវការសម្រាប់ការប្រឡងនេះគឺជាកិច្ចការដ៏សំខាន់។ ហេតុដូច្នេះហើយ ពួកគេត្រូវកំណត់អាទិភាពចំពោះការលៃបម្រុងទុកពេលវេលារបស់ខ្លួនក្នុងមួយថ្ងៃៗដើម្បីឱ្យគេអាចឈានទៅដល់គោលដៅរយៈពេលវែងដែលមានការរៀបចំប្រកបដោយជោគជ័យសម្រាប់ការប្រឡងដែលមានភាពប្រកួតប្រជែង។
  - **កិច្ចការបន្ទាន់** ជាធម្មតាក៏មានសារៈសំខាន់ដែរ ប៉ុន្តែភាពបន្ទាន់គឺទាក់ទងជាមួយនឹងកត្តាពេលវេលា ពោលគឺ ការប្តេជ្ញាចិត្តរយៈពេលខ្លី ភ្លាមៗ ភាគច្រើនផ្អែកលើពេលវេលាកំណត់។ ដោយពិចារណាបន្ថែមទៅលើឧទាហរណ៍ខាងលើ យើងអាចនិយាយបានថាក្មេងស្រីដដែលដែលចង់ចូលរួមប្រឡងប្រកួតប្រជែងបានអានសារព័ត៌មានជារៀងរាល់ថ្ងៃ។ ប៉ុន្តែថ្ងៃមួយ គេប្រាប់នាងថា ថ្នាក់របស់នាងត្រូវប្រឡងពាក់កណ្តាលឆមាសនៅថ្ងៃបន្ទាប់។ ដោយសារការអានសារព័ត៌មានគឺមានសារៈសំខាន់សម្រាប់គោលដៅរយៈពេលវែងដើម្បីឱ្យការប្រឡងប្រកួតប្រជែងបានទទួលដោយជោគជ័យ នាងត្រូវបោះបង់ការអានសារព័ត៌មាននៅថ្ងៃនោះសិន ដើម្បីឱ្យនាងអាចរៀនសម្រាប់ការប្រឡងពាក់កណ្តាលឆមាសនៅថ្ងៃបន្ទាប់បាន។ ការប្រឡងពាក់កណ្តាលឆមាសបានលទ្ធផលល្អគឺមានភាពចាំបាច់សម្រាប់ក្មេងស្រីនោះដើម្បីបញ្ចប់ថ្នាក់វិទ្យាល័យរបស់នាង។ ដូច្នេះ ការរៀនសម្រាប់ការប្រឡងពាក់កណ្តាលឆមាសមិនត្រឹមតែមានសារៈសំខាន់ប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងបន្ទាន់ផងដែរ។ ការធ្វើបែបនេះដោយសារតែកត្តាពេលវេលា។ ដូច្នេះ វាមានសារៈសំខាន់ និងបន្ទាន់ដោយសារតែវាជាគោលដៅមួយដែលមានរយៈពេលខ្លី ឬបន្ទាន់។

- ទោះបីវាមានសារៈសំខាន់ដែលត្រូវយល់ថាតើកិច្ចការ ឬសកម្មភាពណាដែលប្អូនចង់កំណត់អាទិភាពក្នុងជីវិតប្រចាំថ្ងៃរបស់ប្អូនក៏ដោយ ផ្នែកដ៏សំខាន់មួយនៃការយល់នេះក៏ត្រូវរៀនសូត្រពីការនិយាយថា «ទេ» ដែរចំពោះកិច្ចការ ឬសកម្មភាពដែលអ្នកផ្សេងទៀតរំពឹងទុកពីប្អូន។
- ការគ្រប់គ្រងពេលវេលាប្រកបដោយប្រសិទ្ធភាពនៅក្នុងជីវិតប្រចាំថ្ងៃរបស់ប្អូនគឺជាគន្លឹះក្នុងការសម្រេចបានគោលដៅ និងបំណងប្រាថ្នារបស់ប្អូនសម្រាប់អនាគតរបស់ប្អូន។ មានតែពេលដែលប្អូនគ្រប់គ្រងពេលវេលារបស់ប្អូនដើម្បីបញ្ចូលកិច្ចការដែលប្អូនចង់ធ្វើជាសកម្មភាពប្រចាំថ្ងៃ និងកិច្ចការដែលប្អូនចាំបាច់ត្រូវធ្វើដើម្បីមានលទ្ធភាពធ្វើការឆ្ពោះទៅរកគោលដៅអនាគតរបស់ប្អូនប៉ុណ្ណោះទើបជាពេលវេលាដែលប្អូនកំពុងធ្វើការដោយប្រុងប្រយ័ត្នឆ្ពោះទៅរកអ្វីដែលប្អូនចង់សម្រេចបាន។
- **ការរៀបចំផែនការឆ្ពោះទៅមុខ** ៖ មនុស្សម្នាក់ៗមានពេល១៦៨ម៉ោងក្នុងមួយសប្តាហ៍។ ប៉ុន្តែប្រសិនបើប្អូនមិនបានរៀបចំផែនការពីរបៀបចំណាយពេលវេលានេះទេ ប្អូនមិនអាចប្រាកដថាប្អូននឹងបំពេញការងារទាំងអស់ដែលប្អូនចង់ធ្វើបានដោយជោគជ័យទេ។ ដូច្នេះ ការរៀបចំផែនការប្រចាំថ្ងៃ ឬប្រចាំសប្តាហ៍របស់ប្អូនមានសារៈសំខាន់ណាស់។ ការរៀបចំផែនការពេលវេលារបស់ប្អូនក៏ធ្វើឱ្យប្អូនមានលទ្ធភាពមានអារម្មណ៍ជឿជាក់កាន់តែច្រើន និងចំពោះការគ្រប់គ្រងពេលវេលារបស់ប្អូនដែរ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលប្អូនរៀបចំផែនការប្រចាំថ្ងៃ ឬប្រចាំសប្តាហ៍របស់ប្អូន វាផ្តល់នូវពេលវេលាសមស្របមួយចំនួនដែលប្អូនអាចដោះស្រាយការងារមិនបានគ្រោងទុកដែលកើតមាន ឬយកពេលវេលានោះសម្រាប់ការសម្រាកលំហែ និងធ្វើឱ្យខ្លួនមានថាមពល។

☞ ប្រសិនបើមានពេល សរុបមេរៀនដោយបូកសរុបអ្វីដែលបានរៀនពីមេរៀននេះ។

**🗝 គន្លឹះសម្រាប់គ្រូបង្រៀន ៖**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ប្រមូលសន្លឹកកិច្ចការទាំងអស់មុនពេលសិស្សបំបែកគ្នា។

# មេរៀនទី៧ ៖ ការគ្រប់គ្រងអារម្មណ៍តានតឹង

➲ **វត្ថុបំណងមេរៀន ៖** ដើម្បីយល់ពីរបៀបដែលអារម្មណ៍តានតឹងមានឥទ្ធិពលដល់ជីវិតរបស់មនុស្ស និងរៀនរបៀបដោះស្រាយវាឱ្យមានប្រសិទ្ធភាពនៅផ្ទះ និងនៅកន្លែងធ្វើការ។

🕒 **រយៈពេលមេរៀន ៖** ៤៥នាទី

✉ **សារសំខាន់ៗ ៖**

១. អារម្មណ៍តានតឹងអាចមានឥទ្ធិពលអវិជ្ជមានលើជីវិតរបស់យើង សុខភាពផ្លូវអារម្មណ៍ និងរាងកាយយើង ព្រមទាំងផលិតភាពរបស់យើង។

២. ជានិច្ចកាល យើងនឹងឆ្លងកាត់ស្ថានភាពនានាដែលអាចធ្វើឱ្យយើងមានអារម្មណ៍តានតឹង។ មុនពេលយើងអាចដោះស្រាយអារម្មណ៍តានតឹងបាន យើងត្រូវរៀនទទួលស្គាល់អ្វីដែលជាមូលហេតុរបស់វា។ យើងត្រូវរៀនបង្កើតយន្តការដោះស្រាយអារម្មណ៍តានតឹងផ្ទាល់របស់យើងដែលអាចជួយយើងឱ្យគ្រប់គ្រង និងសម្រាលអារម្មណ៍តានតឹងបាន។ យើងត្រូវអនុវត្តវិធីសាស្ត្រជាក់ស្តែងដើម្បីដោះស្រាយស្ថានភាពដែលបង្កឱ្យមានអារម្មណ៍តានតឹង។

៣. អារម្មណ៍តានតឹង គឺជាស្ថានភាពផ្លូវចិត្តមួយ ហើយគេអាចដោះស្រាយវាបាន។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ ៖**

- ☞ សម្រាប់គ្រូបង្រៀន ៖ ក្រដាសផ្ទាំងធំមួយសន្លឹកកាត់ជា៤ ម៉ាស៊ីនថតចម្លង ក្រដាសA4ចំនួន២សន្លឹក ក្រណាត់បិទភ្នែកមួយ ក្តារខៀន ឬហ្វឺត ឬដីស ហ្វឺតលុបមិនជ្រះ ស្កុត និងកន្ត្រៃ។
- ☞ សម្រាប់សិស្ស ៖ សន្លឹកកិច្ចការ ៖ កិច្ចការផ្ទះទំព័រទី១០៣ និងទី១០៥ ក្រដាស A4ចំនួន២សន្លឹក និងសម្ភារៈសរសេរ *(មួយឈុតក្នុងមួយក្រុម)*។

**ការរៀបចំទុកជាមុន ៖**

- ☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។
- ☞ អានឯកសារអំណានទី១២ នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន។
- ☞ រៀបចំប័ណ្ណចំនួន៤សន្លឹកដែលបង្ហាញពីស្ថានភាពខុសៗគ្នាចំនួន៤ (សូមមើលឯកសារអំណានទី១៣នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។
- ☞ ថតចម្លងឯកសារ«គន្លឹះសម្រាប់គ្រូបង្រៀនមួយច្បាប់» (សូមមើលឯកសារអំណានទី១២នៅក្នុងសំណុំឯកសារសម្រាប់គ្រូបង្រៀន)។

- តម្រៀបតុនៅក្នុងថ្នាក់រៀនសម្រាប់សកម្មភាព «ដើរបិទភ្នែក» *(ប្រសិនបើប្រើតុ)*។
- ប្រមូលសម្ភារៈដែលចាំបាច់ផ្សេងៗទៀតទាំងអស់។
- សរសេរចំណងជើងមេរៀននៅលើក្ដារខៀន។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- រំឭកសិស្ស ឱ្យចុះវត្តមានរបស់ខ្លួននៅពេលពួកគេចូលរៀន។
- ឱ្យសិស្សម្នាក់ៗយកសន្លឹកកិច្ចការរបស់ខ្លួន និងសម្ភារៈសរសេរមុនពេលចូលរៀន។

## ២. វិធីសាស្ត្របង្រៀន

**សេចក្ដីណែនាំ**

- ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល«ស្ថានភាពអារម្មណ៍»សិស្សនៅក្នុងថ្នាក់ដោយឱ្យពួកគេប្រើដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតថាមពលរបស់ពួកគេ។
- ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់សង្ខេបពីអ្វីដែលពួកគេបានរៀននៅម៉ោងមុន។
- អាន និងចង្អុលចំណងជើងមេរៀននៅលើក្ដារខៀន។ ឱ្យសិស្សទាយថាតើមេរៀនថ្ងៃនេះនឹងរៀនពីអ្វី។ ឱ្យសិស្សស្ម័គ្រចិត្ត ២-៣នាក់ចែករំលែកពីគំនិតរបស់ពួកគេជាមួយក្រុម។
- ប្រាប់សិស្សថា ថ្ងៃនេះពួកគេនឹងចូលរួមក្នុងសកម្មភាពមួយដែលជួយពួកគេឱ្យរៀនពីអារម្មណ៍តានតឹង និងរបៀបដែលវាប៉ះពាល់លើជីវិតប្រចាំថ្ងៃរបស់យើង ព្រមទាំងរបៀបដែលយើងអាចចាត់វិធានការដើម្បីគ្រប់គ្រងវា។
- បែងចែកសិស្សជា៤ក្រុម។
- ចែកប័ណ្ណមួយសន្លឹកឱ្យក្រុមនីមួយៗដែលឆ្លុះបញ្ចាំងពីស្ថានភាពមួយ ក្រដាសA4២សន្លឹក និងសម្ភារៈសរសេរមួយឈុត។
- ឱ្យក្រុមនីមួយៗអនុវត្តដូចខាងក្រោម ៖
  - ពិនិត្យមើលស្ថានភាពដែលមាននៅក្នុងប័ណ្ណរបស់ប្អូន។
  - ចំណាយពេល៥នាទីដើម្បីបំផុតគំនិតពីចំណុចផ្សេងៗដែលអាចបង្កឱ្យមានអារម្មណ៍តានតឹងនៅក្នុងជីវិតរបស់ប្អូននៅក្នុងស្ថានភាពដែលគេផ្ដល់ឱ្យ។
  - សរសេរចំណុចទាំងនេះដាក់ចូលទៅក្នុងប័ណ្ណរបស់ប្អូន។
  - ពិភាក្សា និងគូសរង្វង់លើកត្តាដែលបង្កឱ្យមានអារម្មណ៍តានតឹងបំផុតចំនួន២ នៅក្នុងប័ណ្ណរបស់ប្អូន។

– ប្រើក្រដាសA4ចំនួន២សន្លឹក និងសរសេរ «ស្ថានភាព» របស់ក្រុមរបស់ប្អូនជាចំណងជើងធំនៅលើក្រដាសទាំងពីរសន្លឹក។ សរសេរកត្តាមួយក្នុងចំណោមកត្តាទាំងពីរដែលបានគូសរង្វង់ដែលធ្វើឱ្យមានអារម្មណ៍តានតឹងពីក្នុងប័ណ្ណស្ថានភាពរបស់ប្អូននៅក្នុងក្រដាសA4នីមួយៗ។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- កំណត់ពេលវេលាសម្រាប់សកម្មភាព។ ប្រាប់សិស្សឱ្យបញ្ឈប់សកម្មភាពក្រោយរយៈពេល ៥នាទី។

- ឱ្យសិស្សម្នាក់មកពីក្រុមនីមួយៗចែករំលែកពីកត្តាសំខាន់បំផុតចំនួន២ដែលធ្វើឱ្យមានអារម្មណ៍តានតឹងដែលគេបានរកឃើញ។
- ចម្លើយមួយចំនួនរបស់ពួកគេអាចមានដូចខាងក្រោម ៖
  - សម្ពាធពីមិត្តភក្តិ *(ជីវិតផ្ទាល់ខ្លួន)។*
  - ទំនាក់ទំនងស្នេហា *(ជីវិតផ្ទាល់ខ្លួន)*។
  - ភាពតានតឹង ឬសម្ពាធការសិក្សាដែលត្រូវធ្វើឱ្យបានល្អនៅសាលារៀន*(ផ្ទះ ឬសាលារៀន)*។
  - ការរំពឹងទុកខ្ពស់ពីឪពុកម្តាយ៖ ការងារនៅក្នុងគ្រួសារ ការប្រព្រឹត្តិអាកប្បកិរិយា ។ល។ *(ផ្ទះ)។*
  - សម្ពាធជុំវិញអាពាហ៍ពិពាហ៍ មិត្តភាពសមស្រប ។ល។ *(ផ្ទះ)*។
  - ការគ្រប់គ្រងពេលវេលា ៖ ពេលវេលាកំណត់ និងកិច្ចការ *(ការងារថ្ងៃអនាគត)*។

**សកម្មភាពបន្ថែម ៖ ដើរបិទភ្នែក**

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ឱ្យសិស្សចូលរួមក្នុងសកម្មភាពបន្ថែម *(ការដើរបិទភ្នែក)* ប្រសិនបើលោកគ្រូ អ្នកគ្រូគិតថាវានឹងជួយសិស្សឱ្យមានការយល់ដឹងកាន់តែទូលំទូលាយថែមទៀត និងប្រសិនបើលោកគ្រូ អ្នកគ្រូមានពេលវេលាគ្រប់គ្រាន់។
- ប្រសិនបើសិស្សបានបង្ហាញពីការយល់ដឹងទូលំទូលាយតាមរយៈការកំណត់កត្តាដែលធ្វើឱ្យមានអារម្មណ៍តានតឹងក្នុងស្ថានភាពនានា *(ជីវិតផ្ទាល់ខ្លួន ផ្ទះ សាលារៀន ជីវិតនៅថ្ងៃអនាគត ។ល។)* សូមបន្តទៅកាន់ជំហានទី៣ ៖ ការពង្រឹកចំណេះដឹង ដោយផ្ទាល់។

☞ ឱ្យសិស្សស្ម័គ្រចិត្តម្នាក់មកពីក្រុមនីមួយៗបិទក្រដាសA4ពីរសន្លឹករបស់ខ្លួន *(ដោយមានសរសេរកត្តាដែលធ្វើឱ្យមានអារម្មណ៍តានតឹងនៅលើក្រដាសនោះ)* នៅលើតុចំនួន២ណាមួយនៅក្នុងថ្នាក់រៀន។

☞ រៀបចំសម្រាប់សកម្មភាពខាងមុខដោយអនុវត្តនូវចំណុចដូចខាងក្រោម ៖

- បែងចែកសិស្សជា២ក្រុមធំ។ ដាក់លេខក្រុមទី១ និងក្រុមទី២។ ឱ្យសិស្សឈរពីរជួរទល់មុខគ្នានៅក្នុងថ្នាក់។
- ប្រាប់សិស្សថា ៖ «ចូរស្រមៃថា ថ្នាក់រៀននេះគឺជាផ្លូវមួយដែលប្អូនត្រូវដើរក្នុងជីវិតប្រចាំថ្ងៃរបស់ប្អូន ហើយតុដែលមានក្រដាសគឺជា«គ្រលុក»ដែលតំណាងឱ្យអារម្មណ៍តានតឹងដែលយើងជួបនៅតាមផ្លូវនេះ។
- ឱ្យសិស្សស្ម័គ្រចិត្ត២នាក់ចេញមកក្រៅជួរ បន្ទាប់មកចងក្រណាត់បិទភ្នែកសិស្សម្នាក់។
- ផ្តល់ការណែនាំដូចខាងក្រោម ៖
  - **សម្រាប់សិស្សស្ម័គ្រចិត្តដែលចងក្រណាត់បិទភ្នែក** ៖ ប្អូនចាំបាច់ត្រូវដើរចេញពីចុងម្ខាងនៃថ្នាក់រៀនទៅកាន់ចុងម្ខាងទៀតដោយមិនត្រូវឱ្យបុកជាមួយតុទេ ជាពិសេស មិនត្រូវប៉ះតុនានាដែលមានបិទក្រដាសដែលសរសេរពីកត្តាធ្វើឱ្យមានអារម្មណ៍តានតឹងទេ។
  - **សម្រាប់សិស្សស្ម័គ្រចិត្តទី២៖** ប្អូនចាំបាច់ត្រូវតែបង្ហាញផ្លូវអ្នកដែលមានចងក្រណាត់បិទភ្នែកដោយប្រាប់ទិសដៅដល់គេដើម្បីដើរជុំវិញតុនៅក្នុងថ្នាក់រៀន។
  - **ក្រុមទី១** ៖ ប្អូនត្រូវស្រែកប្រាប់ពីយោបល់ជាវិជ្ជមានដែលមានលក្ខណៈគាំទ្រដល់សិស្សស្ម័គ្រចិត្តដែលមានចងក្រណាត់បិទភ្នែក ឧទាហរណ៍«អ្នកអាចធ្វើវាបាន!» ឬ «ជិតដល់ហើយ!»។
  - **ក្រុមទី២** ៖ ប្អូនត្រូវស្រែកប្រាប់យោបល់អវិជ្ជមានទៅឱ្យសិស្សស្ម័គ្រចិត្តដែលមានចងក្រណាត់បិទភ្នែក ឧទាហរណ៍ «អ្នកមិនអាចធ្វើវាបានទេ!» ឬ «អ្នកនឹងមិនអាចទៅដល់គោលដៅរបស់អ្នកទេ»។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ធានាថាតុនៅក្នុងថ្នាក់រៀនបានតម្រៀបជាជួរហើយស្រេច មុនពេលសកម្មភាពនេះចាប់ផ្តើម។

🕯 នៅពេលសកម្មភាពកំពុងដំណើរការសូមធានាថា ក្រុមទី២ដែលស្រែកប្រាប់ពីយោបល់អវិជ្ជមានត្រូវមានការគោរព និងជៀសវាងមតិណាមួយជាលក្ខណៈបុគ្គល។ កំណត់ច្បាប់នេះនៅពេលផ្តល់សេចក្តីណែនាំដល់ក្រុមទី២។

☞ នៅពេលចប់សកម្មភាព ឱ្យសិស្សចូលក្នុងក្រុមធំវិញ។

☞ សួរសិស្សស្ម័គ្រចិត្តដែលចងក្រណាត់បិទភ្នែកនូវសំណួរដូចខាងក្រោម ៖

– តើប្អូនមានអារម្មណ៍យ៉ាងដូចម្តេចនៅពេលគេចងបិទភ្នែកប្អូនពេលអនុវត្តសកម្មភាពនេះ?
– តើប្អូនកត់សម្គាល់អ្វីខ្លះពីកម្រិតនៃអារម្មណ៍តានតឹងរបស់ប្អូននៅពេលប្អូនត្រូវដើរគេចគ្រលុក ខណៈដែលមិត្តរួមថ្នាក់របស់ប្អូនស្រែកប្រាប់ប្អូនទាំងចំណុចវិជ្ជមាន និងអវិជ្ជមានព្រមៗគ្នា?

☞ សួរសិស្សស្ម័គ្រចិត្តទី២ ៖

– តើប្អូនមានអារម្មណ៍យ៉ាងដូចម្តេចពេលកំពុងផ្តល់ការណែនាំ ប្រាប់ទិសដៅ និងផ្តល់ការគាំទ្រ?

☞ សួរក្រុមទាំងពីរ ៖

– ប្រសិនបើប្អូនត្រូវជ្រើសរើសការគាំទ្រផ្នែកណាមួយ
  តើប្អូនត្រូវជ្រើសរើសយកការផ្តល់មតិបែប វិជ្ជមាន ឬអវិជ្ជមាន?

☞ បើកការពិភាក្សានៅក្នុងថ្នាក់ទាំងមូល ៖

– តើប្អូនមានអារម្មណ៍ដូចម្តេចចំពោះតួនាទីដែលប្អូនបានសម្តែង?
– តើប្អូនគិតថា សកម្មភាពនេះអាចទាក់ទងទៅនឹងជីវិតផ្ទាល់របស់ប្អូនយ៉ាងដូចម្តេច?

☞ រង់ចាំចម្លើយរបស់ពួកគេ បន្ទាប់ពីលោកគ្រូ អ្នកគ្រូសួរសំណួរនីមួយៗ។

## ៣.ការពង្រឹងចំណេះដឹង

### 🗣 ចំណុចសម្រាប់ការពិភាក្សា

☞ សួរសំណួរដូចខាងក្រោម ៖

– តើអ្វីដែលប្អូនគិតថាធ្វើឱ្យយើងមានអារម្មណ៍តានតឹងនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង?

☞ ចម្លើយដែលអាចមានដូចខាងក្រោម ៖

– ការព្រួយបារម្ភពីអនាគត។
– ការរៀបចំត្រៀមប្រឡង។
– សម្ពាធក្នុងការដែលត្រូវធ្វើឱ្យបានល្អក្នុងការសិក្សា។ល។

🗝 **គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- សូមមើលក្រដាសថតចម្លងរបស់លោកគ្រូ អ្នកគ្រូ«គន្លឹះសម្រាប់គ្រូបង្រៀន»ដើម្បីមើលបញ្ជីទាំងមូលនៃកត្តាដែលអាចធ្វើឱ្យមានអារម្មណ៍តានតឹង (សូមមើលឯកសារអំណានទី១៣សំណុំឯកសារសម្រាប់គ្រូបង្រៀន)។

☞ ចែករំលែកចំណុចដូចខាងក្រោម ៖

- បន្ថែមពីលើចំណុចទាំងអស់ដែលប្អូនបានលើកឡើង វានឹងមានប្រភេទកត្តាផ្សេងទៀតដែលធ្វើឱ្យមានអារម្មណ៍តានតឹងនៅក្នុងជិវិតរបស់ប្អូននៅពេលប្អូនចាប់ផ្ដើមធ្វើការងារ ដូចជាការរំពឹងទុកនៅកន្លែងការងារ បរិយាកាសការងារថ្មី ការធ្វើដំណើរជារៀងរាល់ថ្ងៃ ការធ្វើឱ្យមានតុល្យភាពរវាងការងារ និងជីវិតនៅផ្ទះ ។ល។ វាជាការសំខាន់ដែលប្អូនត្រូវយល់ពីចំណុចដូចខាងក្រោម ៖
  - តើអារម្មណ៍តានតឹងគឺជាអ្វី?
  - តើមានអ្វីកើតឡើង នៅពេលដែលយើងមានអារម្មណ៍តានតឹងលើរឿងផ្សេងៗ?
  - តើយើងអាចកាត់បន្ថយអារម្មណ៍តានតឹងដោយរបៀបណា?

☞ សួរសំណួរដូចខាងក្រោម ៖

- តើប្អូនគិតថា អ្វីជាអារម្មណ៍តានតឹង?

☞ ទទួលយកចម្លើយមួយចំនួន បន្ទាប់មកពន្យល់ចំណុចដូចខាងក្រោម ៖

- អារម្មណ៍តានតឹងគឺជាការឆ្លើយតបចេញពីផ្លូវចិត្ត និងរាងកាយទៅលើការទាមទារ ឬគំនាបណាមួយ។
- វាជាការឆ្លើយតបតាមធម្មជាតិ ហើយជាទូទៅទាក់ទងនឹងបទពិសោធន៍ ការព្រួយបារម្ភ និងបញ្ហាប្រឈមប្រចាំថ្ងៃរបស់យើងនៅផ្ទះ ឬសាលារៀន នៅក្នុងសហគមន៍ និងនៅក្នុងក្រុមមិត្តភក្ដិរបស់យើង។
- អារម្មណ៍តានតឹងអាចមានផលប៉ះពាល់ទាំងល្អ និងអាក្រក់លើជីវិតរបស់យើង។

☞ សួរសំណួរដូចខាងក្រោម ៖

- តើមានអ្វីកើតឡើងចំពោះរាងកាយរបស់ប្អូន នៅពេលដែលប្អូនមានអារម្មណ៍តានតឹង? តើប្អូនមានអារម្មណ៍យ៉ាងដូចម្ដេច?

☞ ទទួលយកចម្លើយមួយចំនួន បន្ទាប់មកពន្យល់ចំណុចដូចខាងក្រោម ៖

- ស្របពេលដែលយើងម្នាក់ៗធ្វើការឆ្លើយតប និងដោះស្រាយអារម្មណ៍តានតឹងតាមវិធីខុសៗគ្នា ឥទ្ធិពលនៃអារម្មណ៍តានតឹងជាប្រចាំ និង / ឬមិនបានដោះស្រាយអាចបណ្ដាលឱ្យមានអារម្មណ៍អន្ទះអន្ទែង កើតទុក្ខ ឆាប់ខឹង ដកខ្លួនចេញពីស្ថានភាព ឬមនុស្ស ការផ្ដោតការយកចិត្តទុកដាក់មិនបានល្អ ឆេវឆាវ ជំងឺរាងកាយ អស់កម្លាំង រំខានការគេង និងមានជំនាញ (បំណិន)ដោះស្រាយបញ្ហាអន់ខ្សោយដូចជាការប្រើថ្នាំជក់ គ្រឿងញៀន ឬគ្រឿងស្រវឹង ព្រមទាំងមានបញ្ហាផ្នែកសុខភាពផ្លូវចិត្តទៀតផង។ កត្តាទាំងអស់នេះអាចបន្ថយបង្អាក់សមត្ថភាពរបស់យើងក្នុងការធ្វើអ្វីមួយអស់ពីលទ្ធភាពរបស់យើង និងដឹកនាំជីវិតមួយដែលមានសុខភាពល្អផ្នែកអារម្មណ៍ និងរាងកាយ។

**គន្លឹះសម្រាប់គ្រូបង្រៀន ៖**

ប្រសិនបើលោកគ្រូ អ្នកគ្រូត្រូវពន្យល់បន្ថែម សូមប្រើឧទាហរណ៍ដែលបានផ្ដល់ឱ្យខាងក្រោមដើម្បីពន្យល់ពីឥទ្ធិពលរបស់អារម្មណ៍តានតឹង។

- ការឈឺចាប់ផ្នែករាងកាយ ៖ ឈឺក្បាល ឈឺពោះ ឈឺសាច់ដុំ ល្វិតល្វៃ ។ល។
- ការដកខ្លួនចេញ ៖ គ្មានការប្រាស្រ័យទាក់ទង ដកខ្លួនចេញពីមនុស្ស និងសកម្មភាពនានា ។ល។
- ការប្រែប្រួលអារម្មណ៍ ៖ អារម្មណ៍ខឹង អន្ទះអន្ទែង ឬបារម្ភ ឆាប់ខឹង បញ្ចេញកំហឹងដាក់អ្នកផ្សេង យំ ។ល។
- ភាពច្របូកច្របល់ ៖ ការគេង និងការញ៉ាំ ៖ ច្រើនពេក ឬមិនគ្រប់គ្រាន់។
- ការផ្ដោតអារម្មណ៍ ៖ ខ្វះការផ្ដោតអារម្មណ៍ ឬការយកចិត្តទុកដាក់បានក្នុងរយៈពេលខ្លី ។ល។

☞ សួរសំណួរដូចខាងក្រោម ៖

- តើយើងកាត់បន្ថយអារម្មណ៍តានតឹងឱ្យនៅក្នុងកម្រិតអប្បបរមានៅក្នុងជីវិតរបស់យើងបានដោយរបៀបណា ដែលមិនធ្វើឱ្យយើងខាតបង់ពេលវេលា ថាមពល សុខភាព ។ល។ និងធ្វើឱ្យមានផលិតភាពពិតប្រាកដ?

☞ ទទួលយកចម្លើយមួយចំនួន បន្ទាប់មកពន្យល់ចំណុចដូចខាងក្រោម ៖

- ដើម្បីចាប់ផ្ដើម យើងត្រូវយល់ពីអារម្មណ៍តានតឹងមុនពេលយើងអាចដោះស្រាយអារម្មណ៍តានតឹងនោះបាន ហើយយើងក៏ត្រូវរៀនទទួលស្គាល់ពីអ្វីដែលបង្កឱ្យមានអារម្មណ៍តានតឹងដែរ។

- ការកំណត់ ទទួលស្គាល់ និងបង្ហាញថាប្អូនមានអារម្មណ៍តានតឹងជួយប្អូនឱ្យផ្តោតលើការស្វែងយល់ពីមូលហេតុនៃភាពតានតឹងនោះ។
- ការរៀនពីជំនាញកាត់បន្ថយអារម្មណ៍តានតឹងជាក់ស្តែងគឺជាជំហានសំខាន់បំផុតក្នុងការដោះស្រាយអារម្មណ៍តានតឹង។

☞ សួរសំណួរដូចខាងក្រោម ៖

- តើកិច្ចការមួយចំនួនក្នុងចំណោមកិច្ចការនានាដែលប្អូនអាចធ្វើបានដើម្បីគ្រប់គ្រងអារម្មណ៍តានតឹងមានអ្វីខ្លះ?

☞ ទទួលយកចម្លើយមួយចំនួន បន្ទាប់មកពន្យល់ចំណុចដូចខាងក្រោម ៖

- គេអាចគ្រប់គ្រងអារម្មណ៍តានតឹងបានតាមរយៈមធ្យោបាយដូចខាងក្រោម ៖
  - តាមរយៈការគ្រប់គ្រងការឆ្លើយតបផ្នែករាងកាយ និងអារម្មណ៍របស់ប្អូនចំពោះអារម្មណ៍តានតឹងដោយខ្លួនឯង និងតាមរយៈការធ្វើចិត្តឱ្យស្ងប់ដើម្បីគិតពីអ្វីដែលបង្កឱ្យមានអារម្មណ៍តានតឹង។
  - តាមរយៈការគិតពីមធ្យោបាយជាក់ស្តែងដើម្បីត្រូវដោះស្រាយស្ថានភាពដែលបង្កឱ្យមានអារម្មណ៍តានតឹង។

☞ សួរសំណួរដូចខាងក្រោម ៖

- ◈ នៅពេលណាយើងកំពុងមានអារម្មណ៍តានតឹង តើយើងអាចកាត់បន្ថយវាបានដោយរបៀបណា?
- ◈ តើយើងអាចធ្វើអ្វីបានខ្លះដើម្បីឱ្យការឆ្លើយតបផ្នែករាងកាយ និងអារម្មណ៍របស់យើងមានភាពវិជ្ជមានជានិច្ច?

☞ ទទួលយកចម្លើយមួយចំនួន បន្ទាប់មកចែករំលែកចំណុចដូចខាងក្រោម ៖

- មានបច្ចេកទេសជាច្រើនដែលគេបានស្គាល់ក្នុងការគ្រប់គ្រង និងកាត់បន្ថយអារម្មណ៍តានតឹងដោយខ្លួនឯង ឧទាហរណ៍ ការចូលរួមក្នុងទម្រង់មួយចំនួននៃសកម្មភាពផ្នែករាងកាយ ការញ៉ាំអាហារដែលមានសុខភាពនិងទៀងទាត់ ការសរសេរពីអ្វីដែលជាអារម្មណ៍របស់ប្អូន ការស្តាប់តន្ត្រី ។ល។

**⊶ គន្លឹះសម្រាប់គ្រូបង្រៀន ៖**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ប្រាប់សិស្សថា ពួកគេនឹងមានឱកាសមួយនៅពេលធ្វើកិច្ចការផ្ទះរបស់ខ្លួនដើម្បីអានពីគន្លឹះនៃការគ្រប់គ្រងអារម្មណ៍តានតឹងដ៏មានតម្លៃនៅក្នុងសន្លឹកកិច្ចការរបស់ខ្លួនដែលនឹងជួយ

ពួកគេឱ្យកាត់បន្ថយ និងគ្រប់គ្រងស្ថានភាពដែលបង្កឱ្យមានអារម្មណ៍តានតឹងនៅក្នុងជីវិតរបស់គេ។ សូមមើលសន្លឹកកិច្ចការទំព័រទី១០៩។

☞ ចែករំលែកដូចខាងក្រោម ៖

- ក្រៅពីការគ្រប់គ្រងអារម្មណ៍តានតឹងដោយខ្លួនឯង ប្អូនត្រូវរៀនទទួលស្គាល់ស្ថានភាពនានាដែលអាចបង្កឱ្យប្អូនមានអារម្មណ៍តានតឹង ឬបង្កឱ្យមានការឆ្លើយតបដោយអារម្មណ៍តានតឹងចេញពីប្អូន។ សូមមើលរបៀបមួយចំនួនសម្រាប់គ្រប់គ្រងស្ថានភាពនេះ ៖

១. **រៀននិយាយថា«ទេ»** ៖ ការប្ដេជ្ញាចិត្តជ្រុលគឺជាប្រភពដ៏ធំមួយនៃអារម្មណ៍តានតឹងទោះបីជាសកម្មភាពដែលប្អូនចូលរួមគឺប្រកបដោយភាពរីករាយក្ដី ឧទាហរណ៍ ការចំណាយពេលជាមួយមិត្តភក្តិ។ ទោះបីសកម្មភាពដែលមានភាពរីករាយគឺជាវិធីមួយដើម្បីសម្រាកលម្ហែក្ដី ក៏សកម្មភាពទាំងនោះអាចក្លាយជាប្រភពមួយនៃអារម្មណ៍តានតឹងដែរនៅពេលដែលគេមិនបានប្រើប្រាស់ការគ្រប់គ្រងពេលវេលា។ ត្រូវមានភាពប្រាកដនិយម និងរៀបចំផែនការអាទិភាព។ គ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតរបស់ប្អូនដូចជា ការងារសាលា ជីវិតគ្រួសារ ជីវិតសង្គម សកម្មភាពតាមកម្មវិធីសិក្សាតាមរចនាសម្ព័ន្ធ ឬបន្ថែម *(កីឡា របាំ ។ល។)* ត្រូវមានតុល្យភាពដើម្បីកាត់បន្ថយអារម្មណ៍តានតឹងឱ្យនៅក្នុងកម្រិតអប្បបរមា។ ពេលខ្លះវាមានការពិបាកក្នុងការនិយាយថា «**ទេ**» ជាពិសេសប្រសិនបើប្អូនមានការព្រួយបារម្ភពីការធ្វើឱ្យអ្នកដទៃខកចិត្ត ឬទាស់ចិត្ត។ ប៉ុន្តែការរៀននិយាយថា«**ទេ**»បែបការទូតមានសារៈសំខាន់ចំពោះការកាត់បន្ថយស្ថានភាពដែលបង្កឱ្យមានអារម្មណ៍តានតឹងដែលយើងអាចជួបប្រទះ។

២. **ការរៀបចំឱ្យបានល្អ** ៖ អភិវឌ្ឍជំនាញរៀបចំដូចជា ការគ្រប់គ្រងពេលវេលា និងសមត្ថភាពបំបែកកិច្ចការធំមួយឱ្យទៅជាកិច្ចការតូចៗ និងដែលអាចសម្រេចបានភាគច្រើន។ ការធ្វើបែបនេះនឹងជួយប្អូនកាត់បន្ថយកម្រិតនៃអារម្មណ៍តានតឹងនៅក្នុងជីវិតប្រចាំថ្ងៃរបស់ប្អូន។

៣. **កំណត់អាទិភាព** ៖ កំណត់ និងទទួលស្គាល់ពីកិច្ចការសំខាន់ និងបន្ទាន់ដែលប្អូនចាំបាច់ត្រូវធ្វើ។ រៀបចំកិច្ចការរបស់ប្អូន និងអនុវត្តវាដោយខ្លួនឯងទៅតាមនោះ។

៤. **ការស្វែងរកជំនួយ** ៖ កសាងបណ្ដាញមួយជាមួយមិត្តភក្តិដែលជួយប្អូនឱ្យដោះស្រាយបញ្ហាតាមវិធីវិជ្ជមាន។ និយាយជាមួយមនុស្សពេញវ័យ ឬមិត្តភក្តិដែលទុកចិត្តដែលនឹងស្ដាប់ប្អូនពិតប្រាកដ និងមិនវិនិច្ឆ័យប្អូន ឬប្រតិកម្មជ្រុលហួសហេតុ។ ការនិយាយពីអារម្មណ៍តានតឹងនឹងជួយប្អូនឱ្យនិយាយចេញពីអារម្មណ៍នានា មានអារម្មណ៍ថាគេបានយល់ពីប្អូន និងជួយប្អូនឱ្យចាប់ផ្ដើមដោះស្រាយបញ្ហារបស់ប្អូន។

**៥. រក្សាវិធីឃាបចរិជ្ជមាន ៖** សុទិដ្ឋិនិយម និងអ្នកគិតបែបវិជ្ជមានទទួលបានសុខភាពល្អ មានអារម្មណ៍តានតឹងតិច និងមាន«សំណាង»ច្រើននៅក្នុងជីវិត។ ព្យាយាមកាត់បន្ថយការនិយាយទៅកាន់ខ្លួនឯងបែបអវិជ្ជមានតាមរយៈការជម្នះគំនិតបែបអវិជ្ជមានពីខ្លួនឯងដោយមានគំនិតវិជ្ជមានវិញ។ ទោះបីជាវាត្រូវការការអនុវត្តបន្តិចដើម្បីរៀបចំផ្លូវចិត្តបែបវិជ្ជមានក្តី វាពិតជាអាចផ្លាស់ប្តូរបទពិសោធន៍ទាំងមូលនៃជីវិតរបស់ប្អូន និងរបៀបដែលប្អូនត្រូវរស់នៅបាន។

**៦. ការគ្រប់គ្រងទំនាស់ ៖** ប្រសិនបើស្ថានភាពនៃទំនាស់មួយកំពុងតែធ្វើឱ្យប្អូនមានអារម្មណ៍តានតឹង ចូរប្អូនរៀនពីរបៀបដោះស្រាយ និងគ្រប់គ្រងទំនាស់។ ទំនាស់អាចកើតឡើងទាំងចំពោះទំនាក់ទំនងផ្ទាល់ខ្លួន និងវិជ្ជាជីវៈ។ វាមិនអាចចៀសផុតបានទេ។ ទំនាស់នឹងកើតឡើងនៅពេលណាដែលប្អូនមានទំនាក់ទំនងជាមួយមនុស្សដែលមានការរំពឹងទុកខុសៗគ្នា។ វាអាចកើតឡើងនៅពេលប្អូនចាប់ផ្តើមធ្វើការងារនៅថ្ងៃអនាគត ដោយប្អូនអាចនឹងមានថៅហ្វាយ ឬមិត្តរួមការងារដែលប្អូនអាចមានជម្លោះ ឬការខ្វែងគំនិតជាមួយពួកគេ។ វាមានសារៈសំខាន់ណាស់ក្នុងការរៀនសូត្រពីរបៀបស្វែងរកមធ្យោបាយសមស្របដើម្បីដោះស្រាយស្ថានភាពនៃទំនាស់ទាំងនេះដោយសារវាអាចនាំទៅរកអារម្មណ៍តានតឹង និងប៉ះពាល់ដល់ការអនុវត្តន៍ការងាររបស់ប្អូន។ វិវាទអាចបញ្ចៀសបានប្រសិនបើគេចាត់វិធានការតាំងពីដំបូងនៅក្នុងការពិភាក្សាមួយដើម្បីរំសាយកំហឹង និងសម្របសម្រួលការប្រាស្រ័យទាក់ទង។ ដើម្បីដោះស្រាយទំនាស់ ចូរចងចាំពីចំណុចសំខាន់ៗខាងក្រោមនៅពេលកំពុងរិះរកវិធីដោះស្រាយស្ថានភាពទំនាស់មួយ ៖

- វាមានសារៈសំខាន់ដែលដំបូងបំផុត និងសំខាន់បំផុតគឺត្រូវរក្សាភាពស្ងៀមស្ងាត់ និងផ្តោតទៅរកការឆ្លើយតបចំពោះស្ថានភាពជាជាងការមានប្រតិកម្ម។
- ត្រូវដឹងថា ប្អូនអាចចាប់ផ្តើមដោយយល់ស្របចំពោះអ្វីដែលប្អូនមិនយល់ស្រប។ ប្អូន និងមនុស្សម្នាក់ទៀតអាចមានទស្សនៈខុសគ្នាចំពោះបញ្ហាមួយ ហើយក៏អាចមានដំណោះស្រាយខុសគ្នាផងដែរចំពោះបញ្ហានោះ។ ចំណុចគន្លឹះគឺត្រូវមានលទ្ធភាពសម្រេចបាននូវចំណុចឯកភាពរួមគ្នាមួយដែលអាចទទួលយកបានសម្រាប់ភាគីពាក់ព័ន្ធទាំងពីរ។ វាក៏អាចធ្វើទៅបានដែរដែលប្អូនអាចយល់ស្របចំពោះការមិនយល់ស្របដោយមិនចាំបាច់វិនិច្ឆ័យ ឬមិនសប្បាយចិត្តនឹងគំនិតរបស់អ្នកដទៃ។ ត្រូវទទួលស្គាល់ថាមនុស្សអាចមានគំនិតខុសៗគ្នា។ ចូរបើកចិត្តឱ្យទូលាយ និងធ្វើអ្វីដែលដំណើរការល្អបំផុតសម្រាប់ប្អូន និងបុគ្គលដទៃទៀតដែរ។

☞ មានគន្លឹះជាច្រើនដែលអាចជួយដោះស្រាយទំនាស់បាន ដូចជាការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ការដោះស្រាយបញ្ហា ការចរចា ។ល។ ដែលយើងបានរៀនពីក្នុងម៉ូឌុលទី២។

សូមមើលសន្លឹកកិច្ចការរបស់ប្អូនទំព័រទី១៥ ស្ដីពីគន្លឹះនៃការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព។

- ☞ សរុបមេរៀនដោយចែករំលែកចំណុចដូចខាងក្រោម ៖
  - អារម្មណ៍តានតឹងគឺជាវិធីនៃការឆ្លើយតបនៃរាងកាយរបស់ប្អូនចំពោះការទាមទារប្រភេទណាមួយ។ វាអាចបង្កឡើងដោយសារបទពិសោធន៍ល្អ និងអាក្រក់។
  - អារម្មណ៍តានតឹងខ្លាំងអាចរំខានដល់ផលិតភាពរបស់ប្អូននិងមានឥទ្ធិពលលើសុខភាពរាងកាយ និងអារម្មណ៍របស់ប្អូន។
  - នៅពេលប្អូនមិនអាចគ្រប់គ្រងកិច្ចការគ្រប់យ៉ាងនៅក្នុងបរិយាកាសរបស់ប្អូនដែលធ្វើឱ្យប្អូនមានអារម្មណ៍តានតឹងបាន វាមិនមានន័យថាប្អូនមិនមានអំណាចទេ ទោះបីជាពេលនោះប្អូនកំពុងជាប់នៅក្នុងស្ថានភាពលំបាកមួយក៏ដោយ។
  - ចំណុចគន្លឹះគឺត្រូវមានលទ្ធភាពស្វែងរកវិធីដោះស្រាយ និងគ្រប់គ្រងអារម្មណ៍តានតឹងដែលសមស្របសម្រាប់ប្អូន។
  - នៅពេលខ្លះ មិនថានៅផ្ទះ សាលារៀន ឬនៅកន្លែងធ្វើការរបស់ប្អូននៅថ្ងៃអនាគតឡើយប្អូននឹងប្រឈមនឹងស្ថានភាពមួយដែលនាំឱ្យមានអារម្មណ៍តានតឹងមួយចំនួនផ្នែករាងកាយ និងផ្លូវចិត្ត។ ប្រសិនបើប្អូនបានដឹងរួចហើយនូវយន្តការ និងវិធីដោះស្រាយអារម្មណ៍តានតឹងរបស់ប្អូន ប្អូននឹងមានសមត្ថភាពកាន់តែប្រសើរឡើងក្នុងការដោះស្រាយស្ថានភាពបែបនេះនៅពេលអនាគត។
- ☞ ប្រសិនបើមានពេល បូកសរុបសារសំខាន់ៗពីមេរៀននេះឱ្យបានលឿន។




**កិច្ចការផ្ទះ ៖**

- ☞ មុនពេលសិស្ស បំបែកគ្នា ចំណាយពេល៥នាទីដើម្បីពន្យល់ពីកិច្ចការនៅផ្ទះរបស់ពួកគេ។
- ☞ ឱ្យពួកគេបើកសន្លឹកកិច្ចការរបស់ខ្លួននៅទំព័រទី១០៣។
  - ឱ្យពួកគេអាន«គន្លឹះសម្រាប់ការគ្រប់គ្រងអារម្មណ៍តានតឹង» បន្ទាប់មកសាកល្បងប្រើប្រាស់វាក្នុងជីវិតប្រចាំថ្ងៃរបស់គេ។
- ☞ ឱ្យសិស្សបើកសន្លឹកកិច្ចការរបស់ខ្លួននៅទំព័រទី១០៥។
  - អានសេចក្ដីណែនាំ បន្ទាប់មកពន្យល់ពីអ្វីដែលពួកគេត្រូវធ្វើ។
- ☞ រំឭកសិស្សពីសារៈសំខាន់នៃការយកសន្លឹកកិច្ចការរបស់ខ្លួនមកវិញនៅម៉ោងក្រោយ។

# សំណុំឯកសារសម្រាប់គ្រូបង្រៀន

## ឯកសារអំណានទី១២ ៖ ប័ណ្ណគំរូបង្ហាញពីស្ថានភាពចំនួន៤

| ប័ណ្ណស្ថានភាពទី១ ៖ ផ្ទះ | ប័ណ្ណស្ថានភាពទី២ ៖ សាលា |
|---|---|
| ប័ណ្ណស្ថានភាពទី៣ ៖ ជីវិតផ្ទាល់ខ្លួន<br>*(មិត្តភក្តិ ទំនាក់ទំនងក្នុងសង្គម បំណងប្រាថ្នា)* | ប័ណ្ណស្ថានភាពទី៤ ៖ ការងារនៅថ្ងៃអនាគត |

**សេចក្តីណែនាំ ៖**

- បត់ក្រដាសផ្ទាំងធំជា៤ផ្នែកស្មើៗគ្នា។
- លាក្រដាសផ្ទាំងធំវិញ។
- កាត់ក្រដាសតាមស្នាមបត់ដើម្បីបង្កើតស្ថានភាពបួនប្រភេទ។
- សរសេរឃ្លា ឬប្រយោគនៅក្នុងប័ណ្ណនីមួយៗដូចបង្ហាញខាងលើ។
- យកប័ណ្ណមកជាមួយលោកគ្រូ អ្នកគ្រូសម្រាប់ជំពូកនេះ។

## ឯកសារអំណានទី១៣ ៖ គន្លឹះសម្រាប់គ្រូបង្រៀន

**កត្តាធ្វើឱ្យមានអារម្មណ៍តានតឹងក្នុងជីវិត ៖ បញ្ជីចម្លើយដែលសិស្សអាចឆ្លើយ**

**គន្លឹះសម្រាប់គ្រូបង្រៀន ៖**

- ខាងក្រោមគឺជាបញ្ជីកត្តាដែលធ្វើឱ្យមានអារម្មណ៍តានតឹងដែលសិស្សអាចឆ្លើយ ឬលោកគ្រូ អ្នកគ្រូអាចបង្ហើបវាបាន ៖
  - សម្ពាធពីមិត្តភក្តិ ឬអ្នកដែលមានអាយុស្របាលគ្នា
  - ពុំមានពេលវេលាធ្វើកិច្ចការផ្សេងៗដែលយើងចង់ធ្វើ
  - ការយឺតយ៉ាវ
  - មានកិច្ចការសាលាច្រើនពេក
  - ការនិយាយជាសាធារណៈ
  - ការមើលថែប្អូន
  - ការឈ្លោះគ្នាជាមួយមិត្តភក្តិ
  - ការរឹតត្បិតឱ្យនៅតែផ្ទះ
  - កិច្ចការប្រចាំថ្ងៃនៅក្នុងផ្ទះ
  - ពុំមានពេលសម្រាក និងគេងត្រឹមត្រូវ(គ្រប់គ្រាន់)
  - មុខកើតមុនច្រើន
  - ការមករដូវ (ស្ត្រី)
  - ការបាត់បង់របស់អ្វីមួយដែលមានតម្លៃ
  - ការទៅជួបវេជ្ជបណ្ឌិត
  - ឪពុកម្តាយឈ្លោះប្រកែកគ្នា និងវាយតប់គ្នាជាប្រចាំ
  - ការព្រួយបារម្ភចំពោះការស្វែងរកការងារធ្វើ
  - កាលវិភាគបន្ទាន់ និងចង្អៀតជារៀងរាល់ថ្ងៃ
  - ការរើទៅរស់នៅផ្ទះថ្មី ឬការប្តូរទៅរៀននៅសាលារៀនថ្មី
  - សម្ពាធដែលតម្រូវឱ្យគេធ្វើឱ្យបានល្អទៅតាមមុខមាត់នៃជីវិតគ្រួសារ រូបរាងកាយ ឬគំនិតផ្សេងទៀតដែលវប្បធម៌តម្រូវឱ្យមាន
  - ការវិវត្តន៍រាងកាយ ៖ លឿនពេក ឬយឺតពេក
  - បញ្ហាគ្រួសាររួមមាន ទំនាស់ ការបំពាន និងគ្រឿងស្រវឹង

- បញ្ហាហិរញ្ញវត្ថុ និងប្រាក់
- បរិវេណរស់នៅមិនមានសុវត្ថិភាព
- ការបៀតបៀនតាមផ្លូវ

**សេចក្តីណែនាំ ៖**

- ថតចម្លងឯកសារនេះមួយច្បាប់។
- យកឯកសារនេះតាមខ្លួនសម្រាប់អនុវត្តសកម្មភាពនេះ។ ឬលោកគ្រូ អ្នកគ្រូអាចប្រើសៀវភៅណែនាំនេះដោយយោងលើទំព័រនេះ។

# មេរៀនទី៨ ៖ នរណាជាអ្នកដឹកនាំ?

➲ វត្ថុបំណងមេរៀន ៖

- ដើម្បីពិភាក្សា និងយល់ពីគុណសម្បត្តិរបស់អ្នកដឹកនាំ និងមានលទ្ធភាពទទួលស្គាល់គុណសម្បត្តិទាំងនោះចំពោះបុគ្គលណាម្នាក់។
- ដើម្បីរៀនពីការធ្វើជាអ្នកដឹកនាំនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់មនុស្សម្នាក់។

🕒 រយៈពេលមេរៀន ៖ ៤៥នាទី

✉ សារសំខាន់ៗ ៖

១. ភាពជាអ្នកដឹកនាំមិនមានន័យត្រឹមតែជាការដឹកនាំអ្នកដទៃទេ។ យើងទាំងអស់គ្នាមានគុណសម្បត្តិមួយចំនួនដែលអាចក្លាយជាអ្នកដឹកនាំនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់យើង។ លទ្ធភាពក្នុងការធ្វើការសម្រេចចិត្ត និងការទទួលខុសត្រូវលើជីវិតផ្ទាល់ខ្លួនរបស់ប្អូនក៏ជាជំនាញ (បំណិន)នៃភាពជាអ្នកដឹកនាំដែរ។

២. វាមានសារៈសំខាន់ដែលត្រូវស្គាល់ពីលក្ខណៈពិសេសនៃភាពជាអ្នកដឹកនាំផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ។ មនុស្សគ្រប់គ្នាមានសក្តានុពលក្នុងការអភិវឌ្ឍជំនាញ និងគុណវុឌ្ឍិនៃភាពជាអ្នកដឹកនាំ ដែលមានដូចជាជំនាញប្រាស្រ័យទាក់ទងល្អ សមត្ថភាពក្នុងការផ្តោត និងរៀបចំផែនការ ព្រមទាំងការទទួលខុសត្រូវ។

៣. នៅពេលប្អូនបានស្គាល់ពីលក្ខណៈពិសេសទាំងនេះហើយ ប្អូនអាចប្រើវាឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀតនៅក្នុងជីវិតផ្ទាល់របស់ប្អូន និងអភិវឌ្ឍវាបន្ថែមទៀតដើម្បីដឹកនាំអ្នកដទៃទៀតនៅថ្ងៃអនាគត។

## ១. ការរៀបចំ

📖 សម្ភារៈដែលត្រូវការ ៖

☞ សម្រាប់គ្រូបង្រៀន ៖ ក្តារខៀនហ្វីត ឬដីស ស្កុត និងកន្ត្រៃ។

☞ សម្រាប់សិស្ស ៖ ក្រដាសA4មួយសន្លឹក និងសម្ភារៈសរសេរ *(មួយឈុតក្នុងមួយក្រុម)*។

**ការរៀបចំទុកជាមុន ៖**

☞ អាន និងយល់លំនាំបង្រៀនឱ្យច្បាស់។

☞ ប្រមូលសម្ភារៈដែលត្រូវការផ្សេងៗទៀតទាំងអស់។

☞ សរសេរចំណងជើងមេរៀននៅលើក្ដារខៀន។

**🗝 គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- រំឭកសិស្សឱ្យចុះវត្តមាននៅពេលពួកគេចូលថ្នាក់រៀន។
- ពិនិត្យមើលថាតើពួកគេមានយកសន្លឹកកិច្ចការមកដែរឬទេ។ ប្រាប់សិស្សឱ្យទុកសៀវភៅកិច្ចការនៅលើតុ និងយកសម្ភារៈសរសេរមុនពេលចូលរៀន។
- សួរសិស្សថាតើពួកបានធ្វើកិច្ចការផ្ទះរបស់គេដែរឬទេ? អានពីគន្លឹះស្ដីពី «ការគ្រប់គ្រងអារម្មណ៍តានតឹង» និងព្យាយាមប្រើវានៅក្នុងជីវិតប្រចាំថ្ងៃរបស់ខ្លួន ព្រមទាំងបានធ្វើកិច្ចការនៅលើសន្លឹកកិច្ចការដែរឬទេ *(ការកំណត់ និងការកត់ត្រាអារម្មណ៍តានតឹងក្នុងសប្ដាហ៍កន្លងទៅ)*។

## ២. ដំណើរការបង្រៀន

### 📢 សេចក្ដីណែនាំ

☞ ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល«អារម្មណ៍»សិស្សនៅក្នុងថ្នាក់ដោយឱ្យសិស្សប្រើដៃរបស់ខ្លួនដើម្បីបង្ហាញពីកម្រិតថាមពលរបស់ពួកគេ។

☞ ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់សង្ខេបពីអ្វីដែលពួកគេបានរៀននៅម៉ោងមុន។

☞ ប្រាប់សិស្សថា មេរៀននៅថ្ងៃនេះជាមេរៀនចុងក្រោយរបស់ម៉ូឌុលទី៣ ៖ សមត្ថភាពធ្វើការងារ / ភាពឆ្លាតវៃ។

☞ អាន និងចង្អុលចំណងជើងមេរៀននៅលើក្ដារខៀន។ ឱ្យសិស្សទាយថាតើមេរៀនថ្ងៃនេះនឹងរៀនពីអ្វី។ ឱ្យសិស្សស្ម័គ្រចិត្ត២-៣នាក់ចែករំលែកគំនិតរបស់ពួកគេជាមួយក្រុម។

☞ ប្រាប់សិស្សថា មេរៀននៅថ្ងៃនេះនឹងជួយពួកគេឱ្យយល់ពី«ភាពជាអ្នកដឹកនាំ»និងអត្ថន័យរបស់វានៅក្នុងជីវិតរបស់យើង។

☞ សួរសំណួរដូចខាងក្រោម ៖

◈ តើប្អូនអាចគិតពីមនុស្សម្នាក់ដែលប្អូនស្គាល់ដែលជាអ្នកដឹកនាំនៅក្នុងបរិបទសាធារណៈដែរឬទេ?

☞ ទទួលយកចម្លើយមួយចំនួន។ ចម្លើយដែលអាចមានរួមមានដូចខាងក្រោម ៖

- ឈ្មោះបុគ្គលប្រវត្តិសាស្ត្រដូចជា ព្រះបាទជ័យវរ្ម័នទី៧ សម្ដេចសង្ឃជួនណាត ព្រះនាងឥន្ទ្រៈទេវី អាចារ្យ ហែម ចៀវ ។ល។

– ឈ្មោះអ្នកនយោបាយបច្ចុប្បន្នដូចជា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សម្តេចក្រឡាហោម ស ខេង លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន។ល។
– ឈ្មោះមនុស្សមកពីវិស័យភាពយន្ត ឬកីឡាពេញនិយមដូចជា លោក ទេព រិនដារ៉ូ លោកស្រី អម្ពរ ទេវី លោកស្រី ស៊ិន សៀវម៉ី ។ល។

☞ បែងចែកសិស្សជាក្រុមដែលមានគ្នា៥នាក់។

**🗝 គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- បែងចែកសិស្ស ទៅជាក្រុមតូចៗសម្រាប់សកម្មភាពមួយអាចត្រូវចំណាយពេលវេលាបន្តិច។ អនុវត្តតាមវិធីសាស្ត្រណាមួយក្នុងចំណោមវិធីសាស្ត្រដែលគេផ្តល់ឱ្យខាងក្រោម ឬបង្កើត វិធីសាស្ត្រផ្ទាល់របស់លោកគ្រូ អ្នកគ្រូដើម្បីអនុវត្តការគ្រប់គ្រងថ្នាក់រៀនឱ្យកាន់តែប្រសើរ។
  – **វិធីសាស្ត្រទី១** ៖ ដើរជុំវិញបន្ទប់ ហើយឱ្យសិស្សម្នាក់ៗរាប់លេខពី១-៥។ នៅពេលសិស្ស៥នាក់បានរាប់លេខពី១ទៅ៥រួចហើយ ឱ្យពួកគេរួមគ្នាបង្កើតជាក្រុមមួយ។ បន្តអនុវត្តតាមវិធីនេះរហូតដល់សិស្សគ្រប់គ្នាបានចូលទៅក្នុងក្រុមមួយ។

    ឬ
  – **វិធីសាស្ត្រទី២** ៖ ឱ្យសិស្សបែងចែកខ្លួនគេជា៤ក្រុមនៅតាមកន្លែងអង្គុយរបស់គេដោយធានាថាក្រុមនីមួយៗមានចំនួនសិស្សស្មើគ្នា។ ឧទាហរណ៍ ៖ សិស្សពាក់កណ្តាលដែលអង្គុយនៅខាងមុខចំនួន២ជួរគឺជាក្រុមទី១ សិស្ស២ជួរបន្ទាប់នៅជួរខាងមុខគឺជាក្រុមទី២។ អនុវត្តដូចគ្នានេះសម្រាប់សិស្ស២ជួរចុងក្រោយ។

☞ ឱ្យក្រុមនីមួយៗធ្វើដូចខាងក្រោម ៖
– ដាក់ឈ្មោះអ្នកដឹកនាំម្នាក់សម្រាប់ផ្នែកចំនួន៣ដូចដែលបានឆ្លុះបញ្ចាំងខាងក្រោម។
– ផ្តល់ឧទាហរណ៍ខាងក្រោមដើម្បីជួយសិស្សឱ្យយល់កាន់តែច្បាស់ ៖

| ១. ក្នុងជីវិតផ្ទាល់របស់ប្អូន | ២. នៅក្នុងសហគមន៍ | ៣. នៅក្នុងពិភពលោក |
| --- | --- | --- |
| ***ឧទាហរណ៍ ៖*** *អ្នកដឹកនាំនៅក្នុងជីវិតផ្ទាល់របស់ប្អូនអាចជាម្តាយ ឬឪពុក បងប្អូនបង្កើត មិត្តភក្តិ ឬសាច់ញាតិ ។ល។ របស់ប្អូន។* | *(នរណាម្នាក់ដែលប្អូនស្គាល់)* ***ឧទាហរណ៍ ៖*** *អ្នកដឹកនាំមកពីសហគមន៍របស់ប្អូនអាចជានរណាម្នាក់ដែលប្អូនបានឃើញទទួលតំណែងជាអ្នក ដឹកនាំ ដោយផ្លូវការ ឬក្រៅផ្លូវការ ពោលគឺស្ត្រីដែលជាអ្នកជិតខាងដែលដឹកនាំក្រុមជួយខ្លួនឯង (SHG) ឬនរណាម្នាក់ដែលបានកៀរគរសហគមន៍ឱ្យថែរក្សាអនាម័យ ។ល។* | *(នរណាម្នាក់ដែលជាបុគ្គលសាធារណៈ)* ***ឧទាហរណ៍ ៖*** *អ្នកដឹកនាំក្នុងនយោបាយក្នុងវិស័យកីឡា ក្នុងវិស័យអប់រំ ។ល ។* |

- នៅពេលក្រុមបានរកឃើញអ្នកដឹកនាំ៣នាក់នៅក្នុងផ្នែកដែលបានផ្តល់ឱ្យរួចហើយ ឱ្យសិស្សពិភាក្សា និងសរសេរលក្ខណៈពិសេស ឬបុគ្គលិកលក្ខណៈនីមួយៗដែលជាមូលហេតុធ្វើឱ្យពួកគេគិតថាបុគ្គលជាក់លាក់នោះគឺជាអ្នកដឹកនាំ។ តើគុណសម្បត្តិអ្វីខ្លះដែលពួកគេចូលចិត្តចំពោះបុគ្គលនីមួយៗក្នុងចំណោមបុគ្គលទាំងនោះ?
- ឱ្យសិស្សគូសរង្វង់លើគុណសម្បត្តិដែលអ្នកដឹកនាំមានជាទូទៅ និងបង្កើតបញ្ជីលក្ខណៈពិសេសរួមមួយ។
- ប្រាប់ក្រុមទាំងអស់ថា ពួកគេមានពេល ១០នាទី ដើម្បីពិភាក្សា និងបង្កើតបញ្ជីចុងក្រោយរបស់ខ្លួន។

☞ ឱ្យសិស្សម្នាក់មកពីក្រុមនីមួយៗឡើងចែករំលែកឧទាហរណ៍នៃអ្នកដឹកនាំរបស់ខ្លួននៅក្នុងផ្នែកទាំង៣ និងលក្ខណៈពិសេសនៃភាពជាអ្នកដឹកនាំរួមដែលគេរកឃើញនៅក្នុងចំណោមអ្នកដឹកនាំទាំង៣ប្រភេទ *(ក្នុងជីវិតផ្ទាល់ខ្លួន ក្នុងសហគមន៍ និងជាសាធារណៈ)*។

☞ ចម្លើយដែលអាចមានរួមមាន ៖

- គាត់ / នាងគិតពីគោលដៅរបស់ក្រុមជានិច្ច។
- គាត់ / នាងជាអ្នកផ្តួចផ្តើមគំនិត។
- គាត់ / នាងស្តាប់សមាជិកនៅក្នុងក្រុម និងយកគំនិតរបស់ពួកគេទៅពិចារណា។
- គាត់ / នាងគិតគូរពីអ្នកដទៃ និងបង្ហាញពីសមានចិត្ត។

– គាត់ / នាងមានការប្រាស្រ័យទាក់ទងល្អ និងជាវាគ្មិនល្អ។
– គាត់ /នាងមានភាពក្លាហាន ដាក់ខ្លួន និងមានសុចរិតភាព ។ល។

🗝 **គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

🕯 នៅពេលក្រុមធ្វើបទបង្ហាញ ប្រើក្តារខៀនដើម្បីកត់ត្រាលក្ខណៈពិសេសនៃភាពជាអ្នកដឹកនាំដែលសិស្សបានរកឃើញ។

## ៣. ការពង្រីកចំណេះដឹង

**ចំណុចសម្រាប់ការពិភាក្សា**

☞ ចូលក្នុងក្រុមធំវិញ។

☞ ចង្អុលទៅក្តារខៀនដែលមានបញ្ជីស្តីពីលក្ខណៈពិសេសនៃភាពជាអ្នកដឹកនាំ បន្ទាប់មកសួរសំណួរដូចខាងក្រោម ៖

– តើគុណសម្បត្តិដែលមាននៅលើក្តារខៀនគឺជាអ្វីមួយដែលមនុស្សមានតាំងពីកំណើត ឬប្អូនគិតថាពួកគេបង្កើតគុណសម្បត្តិទាំងនេះ?
– តើនរណាម្នាក់ និងមនុស្សគ្រប់គ្នាអាចក្លាយជាអ្នកដឹកនាំបានដែរឬទេ?

☞ ទទួលយកចម្លើយមួយចំនួន បន្ទាប់មកចែករំលែកចំណុចដូចខាងក្រោម ៖

– នរណាម្នាក់ និងគ្រប់គ្នាអាចអភិវឌ្ឍជំនាញភាពជាអ្នកដឹកនាំបាន។ គិតពីសមត្ថភាពនៃភាពជាអ្នកដឹកនាំផ្ទាល់ខ្លួនរបស់ប្អូន។ មនុស្សម្នាក់មិនចាំបាច់ត្រូវការមនុស្ស ឬក្រុមមួយ ដើម្បីក្លាយជាអ្នកដឹកនាំនោះទេ។ ការមានសមត្ថភាពក្នុងការធ្វើការសម្រេចចិត្ត និងទទួលខុសត្រូវលើជីវិតផ្ទាល់ខ្លួនរបស់ប្អូនក៏ជាជំនាញនៃភាពជាអ្នកដឹកនាំដែរ។
– មនុស្សម្នាក់ក៏អាចបង្ហាញពីសក្តានុពល និងគុណសម្បត្តិភាពជាអ្នកដឹកនាំនៅក្នុងជីវិតប្រចាំថ្ងៃរបស់គេដែរ។

☞ សួរសំណួរដូចខាងក្រោម ៖

– តើយើងដឹងដោយរបៀបណាថាតើយើងមានលក្ខណៈពិសេសនៃភាពជាអ្នកដឹកនាំ?
– តើយើងអាចប្រើគុណសម្បត្តិនៃភាពជាអ្នកដឹកនាំនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់យើងបានដោយរបៀបណា?

☞ ទទួលយកចម្លើយមួយចំនួន បន្ទាប់មកចែករំលែកចំណុចដូចខាងក្រោម ៖

– អ្នកដឹកនាំល្អគឺជាអ្នកផ្តួចផ្តើមសកម្មភាព និងជាអ្នកផ្តួចផ្តើមគំនិត។

- ពួកគេបង្ហាញពីសមត្ថភាពក្នុងការកំណត់គោលដៅច្បាស់លាស់ និងហ្មត់ចត់សម្រាប់ខ្លួន។
- ពួកគេមានជំនាញទំនាក់ទំនងល្អដែលអាចឱ្យពួកគេបង្ហាញពីតម្រូវការរបស់ខ្លួនយ៉ាងមានប្រសិទ្ធភាពដល់សមាជិកក្រុមរបស់ខ្លួន ព្រមទាំងស្តាប់សមាជិករបស់ខ្លួនដែរ។
- ទាំងនេះជាលក្ខណៈពិសេសដែលយើងម្នាក់ៗអាចអភិវឌ្ឍបាន។ ប្អូនៗទាំងអស់គ្នាត្រូវតែមានចំណុចមួយចំនួននៃភាពជាអ្នកដឹកនាំដែលមានសក្តានុពលភាពនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់ប្អូនមិនថាវាជាការទទួលខុសត្រូវ ឬការបង្ហាញសមត្ថភាពក្នុងការចរចាជាមួយឪពុកម្តាយរបស់ប្អូនពីការទៅផ្ទះមិត្តភក្តិរបស់ប្អូនជាដើម។ ដូច្នេះ គ្រប់ពេលដែលប្អូនជួបបញ្ហាមួយ ឬចាំបាច់ត្រូវចរចាពីអ្វីមួយជាមួយនរណាម្នាក់ នោះបានន័យថាគឺប្អូនកំពុងប្រើប្រាស់ជំនាញភាពជាអ្នកដឹកនាំរបស់ប្អូន ដោយសារជំនាញទាំងនេះក៏ជាការរួមបញ្ចូលនូវភាពជាអ្នកប្រាស្រ័យទាក់ទង អ្នកចរចា និងអ្នកដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាពដែរ។

☞ សួរសំណួរដូចខាងក្រោម ៖

  ◈ តើប្អូនអាចផ្តល់ឧទាហរណ៍មួយពីពេលវេលាណាមួយនៅក្នុងជីវិតផ្ទាល់របស់ប្អូនដែលប្អូនបានបង្ហាញពីលក្ខណៈពិសេសនៃភាពជាអ្នកដឹកនាំផ្ទាល់ខ្លួន ពោលគឺនៅពេលគេឱ្យប្អូនទទួលខុសត្រូវ ឬដឹកនាំអ្វីមួយដែរឬទេ?

☞ ទទួលយកចម្លើយមួយចំនួន បន្ទាប់មកចែករំលែកចំណុចដូចខាងក្រោម ៖

- វាមានសារៈសំខាន់ដែលត្រូវទទួលស្គាល់ពីការចាប់ផ្តើមយល់ពីសក្តានុពលភាពនៃភាពជាអ្នកដឹកនាំនៅក្នុងខ្លួនប្អូន។ ការចាប់ផ្តើមយល់ទាំងនេះគឺជាគុណសម្បត្តិដែលប្អូនអាចកែលម្អបានដើម្បីអភិវឌ្ឍជំនាញភាពជាអ្នកដឹកនាំឱ្យកាន់តែរឹងមាំ។ ឧទាហរណ៍មួយចំនួនមាន ៖
  - សមត្ថភាពរបស់ប្អូនក្នុងការគិតពីគោលដៅបច្ចុប្បន្នរបស់ប្អូនមានការផ្ចង់ផ្តោតល្អ និងការរៀបចំផែនការសម្រាប់គោលដៅនោះ*(វាអាចទាក់ទងនឹងការសិក្សារបស់ប្អូន)*។
  - មានសមត្ថភាពក្នុងការបង្ហាញពីតម្រូវការរបស់ប្អូនប្រកបដោយប្រសិទ្ធភាពទៅដល់សមាជិកគ្រួសារ មិត្តរួមថ្នាក់ ឬគ្រូរបស់ប្អូន ។ល។
  - មានភាពជឿជាក់។ ភាពជឿជាក់ឆ្លុះបញ្ចាំងពីទំនុកចិត្តលើខ្លួនឯង និងភាពប្រាកដប្រជាចំពោះអ្វីដែលប្អូនកំពុងអះអាង។ វាក៏បង្ហាញពីសមត្ថភាពដើម្បីឈរលើការពិតចំពោះអ្វីដែលប្អូនចង់ និងមិនងាករេដោយស្រួលទៅតាមកាលៈទេសៈនានាឡើយ។
  - ការទទួលខុសត្រូវចំពោះខ្លួនប្អូន ឬនៅពេលដែលគេឱ្យប្អូនទទួលខុសត្រូវចំពោះស្ថានភាពមួយ។
  - ការគិតពីចំណុចល្អរួមសម្រាប់អ្នកដទៃ ដូចជាគ្រួសារ សហគមន៍ ឬថ្នាក់របស់ប្អូននៅសាលា។

- ការមានភាពវិជ្ជមាន និងច្នៃប្រឌិត។

☞ សរុបមេរៀនដោយចែករំលែកចំណុចដូចខាងក្រោម ៖

- ប្អូនមិនដឹងទេថាស្ថានភាពអ្វីនៅក្នុងជីវិតដែលតម្រូវឱ្យប្អូនទទួលយកតួនាទី ឬមុខតំណែងក្នុងភាពជាអ្នកដឹកនាំទេ។
- នៅពេលប្អូនទទួលស្គាល់ និងធ្វើការដោយឈរលើសក្តានុពលភាពនៃភាពជាអ្នកដឹកនាំផ្ទាល់របស់ប្អូន ប្អូនអាចអភិវឌ្ឍជំនាញដែលធ្វើឱ្យប្អូនមានលទ្ធភាពដឹកនាំអ្នកផ្សេងទៀតប្រកបដោយប្រសិទ្ធភាពនៅពេលអនាគតមិនថាតែនៅក្នុងសហគមន៍ផ្ទាល់របស់ប្អូន ឬនៅកន្លែងធ្វើការរបស់ប្អូនទេ។ វាជាចំណុចសំខាន់ចំពោះការមានលទ្ធភាពបណ្តុះលក្ខណៈពិសេស និងជំនាញនៃភាពជាអ្នកដឹកនាំ។

☞ ប្រសិនបើមានពេល បូកសរុបសារសំខាន់ៗពីមេរៀននេះឱ្យបានឆាប់។

# ឧបសម្ព័ន្ធទី១

## សន្លឹកកិច្ចការសិស្ស

# សន្លឹកកម្មវិធីសិក្សា ៖ តើត្រូវស្វែងរកនៅកន្លែងណា?


| ផ្នែកលទ្ធភាពធ្វើការងារ ៖ ម៉ូឌុលទី៣ សមត្ថភាពធ្វើការងារ | | | | |
|---|---|---|---|---|
| ជំពូក | កូដមេរៀន និង សន្លឹកកិច្ចការ | ចំណងជើងមេរៀន | ចំណងជើងសន្លឹកកិច្ចការ | ទំព័រ |
| 1. យេនឌ័រ និងបំណងប្រាថ្នា | | | | 90 |
| | ជំពូក១៖ មេរៀនទី១ | តើគេបែងចែកការងារទៅតាមលក្ខណៈយេនឌ័រយ៉ាងដូចម្តេច? | តើនរណាធ្វើកិច្ចការនេះ? | 91 |
| | ជំពូក១៖ មេរៀនទី១ | តើគេបែងចែកការងារទៅតាមលក្ខណៈយេនឌ័រយ៉ាងដូចម្តេច? | ការឆ្លុះបញ្ចាំងរបស់ខ្ញុំ | 92 |
| | ជំពូក១៖ មេរៀនទី១ | តើគេបែងចែកការងារទៅតាមលក្ខណៈយេនឌ័រយ៉ាងដូចម្តេច? | សកម្មភាព និងលទ្ធផលរបស់ខ្ញុំ | 93 |
| 2. ការគូសផែនទីស្តីពីបំណងប្រាថ្នា និងការកំណត់គោលដៅ | | | | 94 |
| | ជំពូក២៖ មេរៀនទី៣ | ខ្ញុំប្រាថ្នាចង់បាន | ក្តីសុបិននិងបំណងប្រាថ្នារបស់ខ្ញុំ | 95-96 |
| | ជំពូក២៖ មេរៀនទី៤ | គោលដៅ និងការកំណត់គោលដៅ | គោលដៅដែលមានលក្ខណៈជាក់លាក់ អាចវាស់វែងបាន អាចសម្រេចបាន មានភាពឆ្លើយតប(ទាក់ទង) និងមានពេលវេលាច្បាស់លាស់ (ជ.វ.ស.ទ.ព / S.M.A.R.T)របស់ខ្ញុំ | 97-98 |
| | ជំពូក២៖ មេរៀនទី៤ | គោលដៅ និងការកំណត់គោលដៅ | ផែនការសកម្មភាពរបស់ខ្ញុំ | 99 |
| 3. ជំនាញដែលប្អូនអាចចង់បាន | | | | 100 |
| | ជំពូក៣៖ មេរៀនទី៦ | ការគ្រប់គ្រងពេលវេលា | តើថ្ងៃរបស់ខ្ញុំមានលក្ខណៈដូចម្តេច? | 101 |
| | ជំពូក៣៖ មេរៀនទី៦ | ការគ្រប់គ្រងពេលវេលា | ការផ្តល់អាទិភាពពេលវេលារបស់ខ្ញុំ | 102 |
| | ជំពូក៣៖ មេរៀនទី៧ | ការគ្រប់គ្រងអារម្មណ៍តានតឹង | សន្លឹកកិច្ចការចំណេះសិស្ស ៖ ការណែនាំពីការគ្រប់គ្រងអារម្មណ៍តានតឹង | 103-104 |
| | ជំពូក៣៖ មេរៀនទី៧ | ការគ្រប់គ្រងសម្ពាធផ្លូវអារម្មណ៍ | ការយល់ដឹងពីអារម្មណ៍តានតឹង និងមូលហេតុរបស់វា | 105-106 |

## ជំពូកទី១ ៖ យេនឌ័រ និងបំណងប្រាថ្នា



*ទិដ្ឋភាពទូទៅ*

«យេនឌ័រ និងបំណងប្រាថ្នា» គឺជាជំពូកទី១នៅក្នុងម៉ូឌុលទី ៣ «សមត្ថភាពធ្វើការងារ»។

ជំពូកនេះផ្តោតលើការជួយប្អូនឱ្យយល់ដឹងច្បាស់លាស់ពីរបៀបដែលយេនឌ័រមានផលជះលើអនាគតរបស់ប្អូនដែលពាក់ព័ន្ធនឹងការងារវិជ្ជាជីវៈ និងបំណងប្រាថ្នាផ្នែកអាជីពរបស់ប្អូន។

មេរៀននេះនឹងជួយប្អូនឱ្យអភិវឌ្ឍការយល់ដឹងមួយពីមូលហេតុនៃផលជះនេះ និងរបៀបពិនិត្យមើលចន្លោះខ្វះខាត ក្នុងលក្ខណៈមួយដែលមិនធ្វើឱ្យប្អូនបាក់ទឹកចិត្តក្នុងការសម្រេចគោលដៅជាអាជីពរបស់ប្អូន។

មេរៀននេះក៏ជំរុញការគិតរបស់ប្អូនឆ្ពោះទៅរកការយល់ពីសារៈសំខាន់សម្រាប់ក្មេងស្រីចូលរួមធ្វើការងារ ដែលមានប្រាក់កម្រៃ និងរបៀបដែលការចូលរួមនេះអាចផ្តល់ផលប្រយោជន៍ដល់ការរស់នៅរបស់ពួកគេ។

### *ជំពូកទី១ ៖ លទ្ធផលសិក្សា*

### *ជំពូកនេះនឹងជួយសិស្សឱ្យ ៖*

| | |
|---|---|
| 1. | យល់ដឹងអំពីរបៀបដែលគេបែងចែកការងារទៅតាមយេនឌ័រ និងរបៀបដែលយេនឌ័រអាចមានផលប៉ះពាល់លើប្រភេទការងារ ឬអាជីពដែលពួកគេប្រាថ្នាចង់ធ្វើ ឬជ្រើសរើសដើម្បីសម្រេចឱ្យបាន។ |
| 2. | រៀនសូត្រពីសារៈសំខាន់នៃការងារប្រកបដោយគុណប្រយោជន៍។ |

## តើនរណាធ្វើកិច្ចការនេះ?

### តើគេបែងចែកការងារទៅតាមលក្ខណៈយេនឌ័រយ៉ាងដូចម្តេច?

**សេចក្តីណែនាំ ៖**

- ចូរមើលប្រភេទការងារនីមួយៗដែលបានរៀបរាប់នៅក្នុងកូឡោនទី១។
- ចូរគិតថាតើនរណាដែលស័ក្តិសមធ្វើការងារប្រភេទនេះ បុរស ស្ត្រី ឬទាំងបុរសនិងស្ត្រី។
- ចូរគូសសញ្ញា(✓)លើប្រអប់នៅខាងស្តាំទៅតាមនោះ។

| ប្រភេទការងារ |  |  |  |
|---|---|---|---|
| គិលានុបដ្ឋាក | | | |
| វិស្វករ | | | |
| បុគ្គលិកសង្គមកិច្ច | | | |
| សន្តិសុខ | | | |
| អ្នករចនាម៉ូតសម្លៀកបំពាក់ | | | |
| អ្នកកែសម្ផស្ស | | | |
| ប្រធានផ្នែកលក់ | | | |
| ជំនាញកុំព្យូទ័រព័ត៌មានវិទ្យា | | | |
| គ្រូបង្រៀន | | | |
| ចុងភៅ | | | |

*សេចក្តីណែនាំ ៖*

- ចូរមើលចម្លើយរបស់ប្អូនខាងលើ រួចឆ្លើយនឹងសំណួរខាងក្រោម ៖
  - តើមានប្រភេទការងារជាក់លាក់ដែលតាមធម្មតាស្ត្រីជាអ្នកធ្វើនៅផ្ទះ និងបុរសជាអ្នកធ្វើនៅខាងក្រៅផ្ទះដែរឬទេ? គូសរង្វង់លើចម្លើយ «មាន» ឬ «មិនមាន» ដើម្បីឆ្លុះបញ្ចាំងពីចម្លើយរបស់ប្អូន។
  - ប្រសិនបើប្អូនគូសរង្វង់លើចម្លើយថា «មាន» ហេតុអ្វីបានជាប្អូនគិតថាវាមានលក្ខណៈបែបនេះ?

**មាន ៖** ..........................................................................................................................................

**មិនមាន ៖** ..................................................................................................................................

# ការឆ្លុះបញ្ចាំងរបស់ខ្ញុំ

## តើគេបែងចែកការងារទៅតាមលក្ខណៈយេនឌ័រយ៉ាងដូចម្តេច?

តើនរណាជាអ្នកធ្វើកិច្ចការទាំងនេះនៅក្នុងផ្ទះ?




គំនិតឆ្លុះបញ្ចាំង .....

តើខ្ញុំមានអារម្មណ៍ដូចម្តេចចំពោះរឿងនេះ? សូមរៀបរាប់ពីគំនិត និងអារម្មណ៍របស់ប្អូននៅទីនេះ។

ចែករំលែកកិច្ចការក្នុងផ្ទះ .....

តើប្អូនចង់ផ្លាស់ប្តូររបៀបដែលរឿងរ៉ាវទាំងនេះកំពុងកើតមានដែរឬទេ?
ប្រសិនបើចង់ តើចំណុចចំនួន៣ដែលប្អូនចង់ផ្លាស់ប្តូរមានអ្វីខ្លះ?.... តើប្អូនចង់ឱ្យវាផ្លាស់ប្តូរដោយរបៀបណា?

1. ....................................................................................................................

   ....................................................................................................................

2. ....................................................................................................................

   ....................................................................................................................

3. ....................................................................................................................

   ....................................................................................................................

កិច្ចការផ្ទះ




# សកម្មភាព និងលទ្ធផលរបស់ខ្ញុំ

## តើគេបែងចែកការងារទៅតាមលក្ខណៈយេនឌ័រយ៉ាងដូចម្ដេច?

តើមានអ្វីមួយបានផ្លាស់ប្តូរដែរឬទេនៅឯផ្ទះ?
ប្រសិនបើមាន តើមានការផ្លាស់ប្តូរអ្វីខ្លះ?
ប្រសិនបើមិនមាន តើអ្វីជាឧបសគ្គរបស់ប្អូនក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរទាំងនេះ?

.................................................................................................................................

.................................................................................................................................

.................................................................................................................................

គូសរង្វង់លើរូបភាពមួយឬច្រើនដើម្បីបង្ហាញពីអារម្មណ៍របស់ប្អូនចំពោះការផ្លាស់ប្តូរដែលប្អូន បានគ្រោងទុក និងវឌ្ឍនភាពនាពេលបច្ចុប្បន្នរបស់វា។



## ជំពូកទី ២ ៖ ការគូសផែនទីស្តីពីបំណងប្រាថ្នា និងការកំណត់គោលដៅ




### ទិដ្ឋភាពទូទៅ

ម៉ូឌុលទី៣៖ ជំពូកទី២ មានគោលដៅជួយសិស្សឱ្យពង្រឹងនូវការយល់ដឹងពីសារៈសំខាន់ក្នុងការកំណត់ពីចំណាប់អារម្មណ៍ និងបំណងប្រាថ្នាផ្ទាល់ខ្លួនរបស់គេ បន្ទាប់មកចាត់វិធានការជាក់លាក់ឆ្ពោះទៅរកការកំណត់គោលដៅតាមទិសដៅនោះ។

ក្មេងស្រីតែងតែប្រឈមនឹងបញ្ហាជាប់ជាប្រចាំមួយចំពោះលទ្ធភាពធ្វើឱ្យមានតុល្យភាពលើទំនួលខុសត្រូវនៅក្នុងផ្ទះ និងកិច្ចការសាលា។ ក្រោយម៉ោងសិក្សា ក្មេងស្រីមួយចំនួនអាចចូលរួមក្នុងសកម្មភាពកម្មវិធីសិក្សាបន្ថែម ឬធ្វើការងារក្រៅម៉ោងនៅក្រៅផ្ទះរបស់ខ្លួន។ ដូចនេះ ទាក់ទងនឹងចំណុចស្នូលនៃការឆ្លើយតបទៅនឹងតម្រូវការចំពោះមុខក្នុងជីវិតរស់នៅប្រចាំថ្ងៃ ពួកគេមានពេលតិចតួចណាស់សម្រាប់ខ្លួនឯង។

ជំពូកនេះនឹងធ្វើឱ្យសិស្សយល់ដឹងពីរបៀបកំណត់គោលដៅដែលមានលក្ខណៈជាក់លាក់ពិតប្រាកដ និងអាចសម្រេចបាន ព្រមទាំងរបៀបដែលពួកគេអាចគិត និងធ្វើការឆ្ពោះទៅរកការសម្រេចបានគោលដៅរបស់ខ្លួន។

*ជំពូកទី២ ៖ លទ្ធផលសិក្សា*

*ជំពូកនេះនឹងជួយសិស្សឱ្យ៖*

1. មានលទ្ធភាពគិត និងកំណត់ពីចំណាប់អារម្មណ៍ និងបំណងប្រាថ្នាផ្ទាល់របស់ខ្លួន។
2. ដើម្បីយល់ថាតើគោលដៅជាអ្វី និងរបៀបកំណត់គោលដៅទាំងនោះ។

# ក្ដីសុបិន និងបំណងប្រាថ្នារបស់ខ្ញុំ

*ខ្ញុំប្រាថ្នាចង់បាន*

*នៅពេលដែលប្អូនគិតពីបំណងប្រាថ្នាផ្នែកអាជីពរបស់ប្អូន វាមានសារៈសំខាន់ដែលប្អូនត្រូវចាំទុកក្នុងចិត្តពី ចំណាប់អារម្មណ៍ និងលទ្ធភាពរបស់ប្អូន។*

**សេចក្ដីណែនាំ ៖**

- ចូររៀបរាប់ពីក្ដី**សុបិន និងចំណាប់អារម្មណ៍**របស់ប្អូននៅក្នុង**រង្វង់ពណ៌ផ្កាឈូក**
- ចូររៀបរាប់ពី**ចំណុចខ្លាំង និងលទ្ធភាព**របស់ប្អូននៅក្នុង**រង្វង់ពណ៌លឿង**

យោងតាមចម្លើយរបស់ប្អូនពីចំណុចទាំង២ខាងលើ ចូរប្អូនរៀបរាប់ពីជម្រើសការងារដែលអាចមាន ដែលបើកឱកាសឱ្យប្អូនស្វែងរកនៅក្នុងរង្វង់ពណ៌បៃតង



*សេចក្ដីណែនាំ ៖*

- ត្រូវចងចាំក្នុងចិត្តពីចំណាប់អារម្មណ៍ និងលទ្ធភាពរបស់ប្អូន។
- ចាត់ចំណាត់ថ្នាក់តាមលំដាប់លំដោយពីជម្រើសការងារកំពូល(សំខាន់បំផុត)ចំនួន២ សម្រាប់ខ្លួនប្អូនផ្ទាល់។

| ចំណាត់ថ្នាក់ជម្រើសការងារ | ចំណាប់អារម្មណ៍របស់ខ្ញុំ | លទ្ធភាពរបស់ខ្ញុំ |
|---|---|---|
| ១. | | |
| ២. | | |

កិច្ចការក្នុងថ្នាក់

## គោលដៅដែលមានលក្ខណៈជាក់លាក់ អាចវាស់វែងបាន អាចសម្រេចបាន មានភាពឆ្លើយតប(ទាក់ទង) និងមានពេលវេលាច្បាស់លាស់ (ជ.វ.ស.ទ.ព / S.M.A.R.T.) របស់ខ្ញុំ

### គោលដៅ និងការកំណត់គោលដៅ

- ចូរឆ្លុះបញ្ចាំងពីជីវិតរបស់ប្អូន និងគិតពីគោលដៅសំខាន់ៗចំនួនមួយ ឬច្រើនដែលប្អូនចង់សម្រេចឱ្យបាន។
- ចូរសរសេរគោលដៅទាំងនោះនៅទីនេះ(ប្អូនអាចពិចារណាទៅមើលសន្លឹកកិច្ចការក្នុងផ្នែកមុនស្តីពី«ក្តីសុបិនរបស់ខ្ញុំ ចំណាប់អារម្មណ៍របស់ខ្ញុំ» *នៅទំព័រទី ៩៦*)



*សេចក្តីណែនាំ ៖*

- ឥឡូវនេះ ចូរកំណត់គោលដៅសំខាន់បំផុតរបស់ប្អូនផ្ទាល់ ដោយឆ្លុះបញ្ចាំងទៅលើវាម្តងមួយៗ និងឆ្លើយសំណួរខាងក្រោម ៖
  - តើគោលដៅនេះលើកទឹកចិត្តខ្ញុំដែរឬទេ? តើវាមានសារៈសំខាន់ចំពោះខ្ញុំដែរឬទេ?
  - តើគោលដៅនេះបានជួយខ្ញុំឱ្យកែលម្អសមត្ថភាពផ្ទាល់ខ្លួនរបស់ខ្ញុំ និងធ្វើឱ្យប្រសើរឡើងនូវក្តីសង្ឃឹមនាពេលអនាគតរបស់ខ្ញុំដែរឬទេ?
- នៅពេលដែលប្អូនបានកំណត់គោលដៅសំខាន់បំផុតរបស់ប្អូនរួចហើយ ចូរគូសសញ្ញា (✓) លើគោលដៅនោះ។

កិច្ចការក្នុងថ្នាក់

*ជ.វ.ស.ទ.ព*

*តើគោលដៅរបស់ប្អូនមានលក្ខណៈ ជ.វ.ស.ទ.ព (S.M.A.R.T) ដែរឬទេ?*

- ជ - ធ្វើឱ្យវាមានលក្ខណៈជាក់លាក់ ៖ បង្កើតសេចក្តីថ្លែងពីគោលដៅរបស់ប្អូន។ ចូរប្រើពាក្យថា «ខ្ញុំនឹង» ដើម្បីធ្វើឱ្យវាមានភាពជាក់លាក់។

..........................................................................................................................................

- វ - ធ្វើឱ្យវាមានលក្ខណៈអាចវាស់វែងបាន ៖ តើប្អូននឹងដឹងដោយរបៀបណានៅពេលដែលប្អូនសម្រេចបានគោលដៅរបស់ខ្លួន?

..........................................................................................................................................

- ស - ធ្វើឱ្យវាមានលក្ខណៈអាចសម្រេចបាន ៖ តើប្អូននឹងធ្វើការឆ្ពោះទៅរកការសម្រេចគោលដៅរបស់ប្អូនដោយរបៀបណា? ចូរកំណត់សកម្មភាពដំបូងរបស់ប្អូននៅទីនេះ។ តើប្អូននឹងធ្វើអ្វី? ប្រើប្រាស់សន្លឹកកិច្ចការបន្ទាប់ *(ទំព័រទី៩)* និងកំណត់ *ពីវិធានការ*ដែល*អាចធ្វើសកម្មភាពបាន* ដែលប្អូនត្រូវធ្វើដើម្បីសម្រេចគោលដៅរបស់*ប្អូន*។

កិច្ចការដំបូងដែលខ្ញុំត្រូវធ្វើគឺ ..........................................................................................

..........................................................................................................................................

- ទ - ធ្វើឱ្យវាមានលក្ខណៈទាក់ទងគ្នា ៖ តើគោលដៅនេះមានតម្លៃក្នុងការខិតខំប្រឹងប្រែងដើម្បីសម្រេចឱ្យបានដែរឬទេ? សូមពន្យល់ពីមូលហេតុ។

..........................................................................................................................................

..........................................................................................................................................

- ព - ធ្វើឱ្យវាមានពេលវេលាជាក់លាក់ ៖ តើគោលដៅនេះនឹងត្រូវសម្រេចបាននៅពេលណា? ចូរបញ្ជាក់ពីពេលវេលាឱ្យបានច្បាស់លាស់។

..........................................................................................................................................

..........................................................................................................................................

កិច្ចការក្នុងថ្នាក់

# ផែនការសកម្មភាពរបស់ខ្ញុំ

## គោលដៅ និងការកំណត់គោលដៅ

### សេចក្តីថ្លែងគោលដៅរបស់ខ្ញុំ

ខ្ញុំនឹង ..........................................................................................................................

*ផែនការជាជំហានៗរបស់ខ្ញុំដើម្បីសម្រេចគោលដៅរបស់ខ្ញុំ*

សេចក្តីណែនាំ ៖

- ចូររៀបរាប់ពីសកម្មភាព ឬកិច្ចការយ៉ាងតិចចំនួន៥ដើម្បីជួយប្អូនឱ្យសម្រេចគោលដៅបាន។
- ចូរព្យាយាមកំណត់ពីកាលបរិច្ឆេទដែលជាចំណុចដៅសម្រាប់កិច្ចការនីមួយៗដែលមិនជាការងារប្រចាំថ្ងៃ។ កំណត់កាលបរិច្ឆេទដែលជាចំណុចដៅសម្រាប់កិច្ចការប្រចាំសប្តាហ៍។

| ល.រ | សកម្មភាព ឬកិច្ចការ | ធនធានដែលខ្ញុំត្រូវការ | កាលបរិច្ឆេទដែលជាចំណុចដៅ | កាលបរិច្ឆេទបញ្ចប់ (ត្រូវបំពេញ) |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |
| ៥ | | | | |
| ៦ | | | | |

*ឧបសគ្គ ឬបញ្ហាដែលអាចកើតមាន*

សេចក្តីណែនាំ ៖

- តើមានឧបសគ្គដែលអាចកើតមានអ្វីខ្លះដែលខ្ញុំអាចព្យាករណ៍ថានឹងជួបប្រទះនៅពេលកំពុងសម្រេចគោលដៅរបស់ខ្ញុំ?
- តើមានដំណោះស្រាយ ឬសកម្មភាពអ្វីខ្លះដែលខ្ញុំអាចធ្វើដើម្បីជម្នះឧបសគ្គទាំងនោះ?

| ល.រ | ឧបសគ្គ ឬបញ្ហា | ដំណោះស្រាយ និងសកម្មភាព |
|---|---|---|
| ១ | | |
| ២ | | |
| ៣ | | |
| ៤ | | |
| ៥ | | |

តើខ្ញុំត្រូវឱ្យរង្វាន់ខ្លួនឯងបែបណា ក្រោយពេលខ្ញុំសម្រេចគោលដៅរបស់ខ្ញុំ?

..........................................................................................................................

## ជំពូកទី៣ ៖ ជំនាញដែលប្អូនអាចចង់បាន



*ទិដ្ឋភាពទូទៅ*

ក្មេងស្រីជំទង់ឆ្លងកាត់ការប្រែប្រួលរូបរាងកាយ និងអារម្មណ៍ជាច្រើននៅពេលពួកគេផ្លាស់ប្តូរវ័យពីក្មេងស្រីវ័យជំទង់ទៅជាមនុស្សស្រីពេញវ័យ។ តាមរយៈការប្រែប្រួលនេះ ពួកគេក៏បានរៀនសូត្រពីការដោះស្រាយនូវសម្ពាធជាច្រើនពីសាលា ការងារផ្ទះ និងទំនួលខុសត្រូវក្នុងគ្រួសារផងដែរ។ ជារឿយៗ ពួកគេដឹងដោយខ្លួនឯងចំពោះស្ថានភាពផ្សេងៗដែលពួកគេត្រូវធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗដែលនឹងប៉ះពាល់ដល់ការរស់នៅ និងអនាគតរបស់ពួកគេ។

ដើម្បីធ្វើឱ្យសិស្សមានទំនុកចិត្តលើសមត្ថភាពក្នុងការរកដំណោះស្រាយសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ខ្លួន ការធ្វើសេចក្តីសម្រេចចិត្ត និងការធ្វើការឆ្ពោះទៅរកបំណងប្រាថ្នារបស់ខ្លួន ពួកគេត្រូវតែអភិវឌ្ឍជំនាញផ្សេងៗដូចជា ភាពជាអ្នកដឹកនាំ ការធ្វើសេចក្តីសម្រេចចិត្ត ព្រមទាំងការគ្រប់គ្រងពេលវេលា និងអារម្មណ៍តានតឹង។

មេរៀននេះ នឹងនាំសិស្សឱ្យរៀនសូត្រពីជំនាញទាំងនេះ ក្នុងលក្ខណៈមួយដែលធ្វើឱ្យពួកគេកាន់តែមានភាពច្បាស់លាស់ចំពោះខ្លួនឯង និងបំណងប្រាថ្នាពេលអនាគតរបស់ខ្លួន ព្រមទាំងមានលទ្ធភាពធ្វើការជាប់ជាប្រចាំឆ្ពោះទៅរកការសម្រេចបានគោលដៅនាពេលអនាគតរបស់ខ្លួន។

*ជំពូកទី៣៖ លទ្ធផលសិក្សា*

**ជំពូកនេះនឹងជួយសិស្សឱ្យ ៖**

1. មានលទ្ធភាពយល់ពីការធ្វើសេចក្តីសម្រេចចិត្ត និងចេះថ្លឹងថ្លែងពីផលវិបាកនៃ ការសម្រេចចិត្តដែលគេបានធ្វើ។
2. យល់ពីតម្លៃពេលវេលា និងមានលទ្ធភាពគ្រប់គ្រងពេលវេលារបស់ខ្លួនបានកាន់តែប្រសើរ។
3. មានលទ្ធភាពកំណត់ពីមូលហេតុនៃអារម្មណ៍តានតឹងចំពោះការរស់នៅរបស់ខ្លួន និងសិក្សាពីរបៀបគ្រប់គ្រងវា។
4. មើលឃើញពីលក្ខណៈសម្បត្តិក្នុងភាពជាអ្នកដឹកនាំ ដែលជាគុណសម្បត្តិផ្ទាល់ខ្លួនដែលពួកគេមាន ហើយដែលគេអាចអភិវឌ្ឍបន្ថែមទៀតបាន។

# ***តើថ្ងៃរបស់ខ្ញុំមានលក្ខណៈដូចម្តេច?***

*ការគ្រប់គ្រងពេលវេលា*

សេចក្តីណែនាំ ៖

- បែងចែកនាឡិកាទី១ជា៤ផ្នែក ដោយផ្អែកលើចំនួនពេលវេលាប៉ាន់ស្មានដែលប្អូនចាប់ផ្តើមថ្ងៃថ្មីរបស់ប្អូន។
- សរសេររៀបរាប់ពីសកម្មភាពទាំងអស់ដែលប្អូនធ្វើក្នុងផ្នែកនីមួយៗ ដែលជាសកម្មភាពប្រចាំថ្ងៃ។

នាឡិកាទី 1




*សេចក្តីណែនាំ ៖*

- ចូរឆ្លុះបញ្ចាំងពីសកម្មភាពប្រចាំថ្ងៃរបស់ប្អូន។គូសរង្វង់លើសកម្មភាពក្នុងផ្នែកនីមួយៗទៅតាមអាទិភាព ៖
  - សកម្មភាពដែលមាន**អាទិភាពជាងគេ**ដែលប្អូនត្រូវតែធ្វើ *(គូសរង្វង់ពណ៌បៃតង)*។
  - សកម្មភាពដែលមាន**អាទិភាពមធ្យម**ដែលប្អូនអាចពឹងឱ្យអ្នកដទៃអនុវត្តជំនួសបាន*(គូសរង្វង់ពណ៌ខៀវ)*
  - សកម្មភាពដែលមាន**អាទិភាពទាប** ដែលប្អូនមិនចាំបាច់ធ្វើ *(គូសរង្វង់ពណ៌ក្រហម)*។

# ការចាត់អាទិភាពលើពេលវេលារបស់ខ្ញុំ

## ការគ្រប់គ្រងពេលវេលា

សេចក្ដីណែនាំ ៖

- ចូរបែងចែកនាឡិកាទី២ជាបួនផ្នែកដូចដែលអ្នកបានធ្វើលើនាឡិកាទី១ដែរ។
- ចូរសរសេររៀបរាប់ការងារដែលប្អូនចង់ធ្វើ ប៉ុន្តែមិនមានពេលធ្វើទេ។

នាឡិកាទី ២




*សេចក្ដីណែនាំ ៖*

- ចូរឆ្លុះបញ្ចាំងពីបញ្ជីសកម្មភាពខាងលើដែលប្អូនចង់ធ្វើ ប៉ុន្តែមិនមានពេលធ្វើ។
- កំណត់សកម្មភាព១ឬ២ ដែលបន្ទាន់បំផុត ឬសំខាន់បំផុតសម្រាប់ប្អូន។
- គូរវង្វង់តាមពណ៌ដែលប្អូនចូលចិត្ត។ ដាក់វាជំនួសសកម្មភាពដែលមានអាទិភាពទាប ឬមធ្យម ក្នុងនាឡិកាទី១។
- ប្រើពណ៌ដែលប្អូនចូលចិត្តដើម្បីសរសេរសកម្មភាពទាំងនេះនៅក្នុងនាឡិកាទី១។ គូសចោល សកម្មភាពនានាដែលប្អូនបានដាក់ជំនួស។

# សន្លឹកកិច្ចការចំណេះដឹងសិស្ស ៖ ការណែនាំពីការគ្រប់គ្រងអារម្មណ៍តានតឹង

## ការគ្រប់គ្រងអារម្មណ៍តានតឹង

សេចក្ដីណែនាំ ៖

- ចូរអានផ្នែកខាងក្រោមនេះ ដែលជាវិធីសាស្ត្រកាត់បន្ថយអារម្មណ៍តានតឹងដោយខ្លួនឯង និងរបៀប ដោះស្រាយវិវាទ។ ព្យាយាម និងអនុវត្តចំណុចណាមួយជារៀងរាល់ថ្ងៃ។

*វិធីសាស្ត្រកាត់បន្ថយអារម្មណ៍តានតឹងដោយខ្លួនឯង*

- ហាត់ប្រាណ។ វាអាចជួយកាត់បន្ថយអារម្មណ៍តានតឹង និងបង្កើតកម្លាំង។
- បរិភោគអាហារឱ្យបានទៀតទាត់។ ការបរិភោគអាហារដែលមានអាហារូបត្ថម្ភ។ ការទទួលទានម្ហូបអាហារមានជាតិស្ករ និងខ្លាញ់ខ្ពស់នឹងធ្វើឱ្យអារម្មណ៍មានភាពមិននឹងនរ។
- ត្រូវនិយាយថាទេចំពោះគ្រឿងញៀន គ្រឿងស្រវឹង និងបារី។ សារធាតុទាំងនេះមិនមែនជាវិធីសាស្ត្រវិជ្ជមានក្នុងការគ្រប់គ្រងអារម្មណ៍តានតឹងទេ ហើយបើទោះបីជាវាអាចធ្វើឱ្យបញ្ហារបស់ប្អូនធូរស្រាលមួយរយៈពេលក្ដី ពួកវានឹងបង្កើតឱ្យមានអារម្មណ៍តានតឹងបន្ថែមទៀតដោយជៀសពុំរួច ឬ បង្កើននូវការរំជួលចិត្តរបស់ប្អូនកាន់តែខ្លាំង។
- សម្រាក និងគេងឱ្យបានគ្រប់គ្រាន់។ គេផ្ដល់អនុសាសន៍ឱ្យគេងឱ្យបានជាអប្បបរមាចំនួន៨ម៉ោងក្នុងមួយថ្ងៃ។ ការអស់កម្លាំងនឹងបង្កើននូវអារម្មណ៍តានតឹងរបស់ប្អូនដោយស្វ័យប្រវត្តិ និងមានផលជះលើសមត្ថភាពក្នុងការមានប្រតិកម្មទៅលើស្ថានភាពនានាប្រកបដោយភាពចាស់ទុំ។
- សម្រាក។ ចំណាយពេលវេលាសម្រាក ឬធ្វើសកម្មភាពដែលប្អូនចូលចិត្ត។ ការចំណាយពេល១៥នាទីនៅម្នាក់ឯងដោយគ្មានការរំខាន អាចធ្វើឱ្យប្អូនមានភាពស្រស់ថ្លាគ្រប់គ្រាន់ដើម្បីដោះស្រាយគ្រប់បញ្ហាដែលប្អូនត្រូវធ្វើ និងធ្វើឱ្យប្អូនមានអារម្មណ៍កាន់តែធូរស្រាល។
- ស្ដាប់តន្ត្រីរងំៗដើម្បីបន្ធូរអារម្មណ៍។
- ចេញដើរទៅខាងក្រៅផ្ទះ។
- សរសេររៀបរាប់អំពីអារម្មណ៍របស់ប្អូនចូលក្នុងទិនានុប្បវត្តិ ឬសៀវភៅកំណត់ហេតុ។
- រៀនហាត់ប្រាណដើម្បីបន្ធូរអារម្មណ៍ ដូចជាការដកដង្ហើមចេញឱ្យអស់ពីពោះបច្ចេកទេសបន្ធូរ(សម្រួល) សាច់ដុំ សមាធិ យូហ្គា ។ល។ ការធ្វើលំហាត់ប្រាណផ្លូវដង្ហើម គឺជាវិធីសាស្ត្រដ៏ល្អមួយក្នុងការកាត់បន្ថយអារម្មណ៍តានតឹងនៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ លំហាត់ប្រាណទាំងនេះគឺមានលក្ខណៈងាយស្រួលរៀន និងធ្វើតាមប្អូនអាចធ្វើបាននៅនឹងកន្លែង និងគ្រប់ពេលវេលានៅពេលដែលប្អូនមានអារម្មណ៍ថាកម្រិតនៃអារម្មណ៍តានតឹងកំពុងកើនឡើង ហើយជួយប្អូនឱ្យមានអាម្មណ៍ល្អភ្លាមៗ។ លំហាត់ប្រាណមួយដែលមានប្រសិទ្ធភាពគឺ «ការស្រូបខ្យល់ដង្ហើមដែលមានសេចក្ដីស្ងប់ចូល» និង«ការបញ្ចេញខ្យល់ដង្ហើមដែលមានអារម្មណ៍តានតឹងចេញ»។
- សាកល្បងពិគ្រោះយោបល់ជាមួយនឹងអ្នកពិគ្រោះយោបល់វេជ្ជសាស្ត្រក្នុងករណីដែលប្អូនមានអារម្មណ៍ថាត្រូវការនិយាយជាមួយនរណាម្នាក់ផ្សេងទៀត។

***<u>វិធីសាស្ត្រដោះស្រាយទំនាស់</u>***

**សាកល្បងបច្ចេកទេសមួយចំនួនក្នុងចំណោមបច្ចេកទាំងនេះដើម្បីដោះស្រាយទំនាស់នានាក្នុងជីវិតរបស់ប្អូនៗ**

- ស្ដាប់ដើម្បីឱ្យយល់អំពីស្ថានភាពដែលកើតចេញពីទស្សនៈទានរបស់មនុស្សគ្រប់គ្នា *(ការយល់ចិត្ត)*។
- ឆ្លើយតបទៅនឹងស្ថានភាពជំនួសឱ្យការមានប្រតិកម្មទៅលើស្ថានភាពនោះ។
- បង្ហាញពីរឿងរបស់ប្អូនឱ្យបានច្បាស់លាស់ ដោយភាពអត់ធ្មត់ និងប្រកបដោយទំនុកចិត្ត។
- មិនត្រូវស្ទាក់ស្ទើរក្នុងការទទួលស្គាល់ ឬទទួលយកកំហុសរបស់ប្អូនឡើយ ប្រសិនបើវា ជាការពិត។
- ផ្តោតការយកចិត្តទុកដាក់លើចំណុចវិជ្ជមាន។ វាមានសារៈសំខាន់ក្នុងការស្វែងរកចំណុចរួមមួយចំនួន ឬបង្កើតឱ្យមានចំណុចរួមរវាងប្អូន និងអ្នកដែលប្អូនមានទំនាស់ជាមួយ។
- ផ្តោត ឬនិយាយទៅលើបញ្ហា មិនមែនទៅលើមនុស្សនោះទេ។ ឧទាហរណ៍នៅកន្លែងការងារ ប្រសិនបើគេមិនបានបំពេញភារកិច្ចឱ្យបានចប់ទាន់ពេលវេលាទេ ដូច្នេះជាជាងការស្ដីបន្ទោសលើនរណាម្នាក់ដោយនិយាយថា «អ្នកតែងតែធ្វើឱ្យការងាររញ៉េរញ៉ៃ» ប្អូនគួរនិយាយថា «យើងត្រូវពិនិត្យមើលឱ្យបានដិតដល់ជាងនេះពីមូលហេតុដែលភាពយឺតយ៉ាវនេះនៅតែបន្តកើតមាន»។
- ធ្វើការងារឆ្ពោះទៅរកចំណុចល្អរួមគ្នា។ ការដឹងថាតើទំនាស់ធ្វើឱ្យស្ថានភាពមានភាពធ្ងន់ធ្ងរកម្រិត ណាក៏ដោយវាមានសារៈសំខាន់ណាស់ក្នុងការដោះស្រាយទំនាស់នោះនៅកន្លែងធ្វើការដើម្បីឱ្យប្អូន និងអ្នកផ្សេងទៀតអាចធ្វើដំណើរឆ្ពោះទៅរកចំណុចកាន់តែល្អប្រសើរដែលមាននៅក្នុងចិត្តដូចជា ជោគជ័យក្នុងគម្រោងការងារមួយជាដើម។

# ការយល់ដឹងអំពីអារម្មណ៍តានតឹង និងមូលហេតុរបស់វា

## ការគ្រប់គ្រងសម្ពាធផ្លូវអារម្មណ៍

សេចក្ដីណែនាំ ៖

- ចូរឆ្លុះបញ្ចាំង និងគិតពីព្រឹត្តិការណ៍ជាច្រើនដែលធ្វើឱ្យប្អូនមានអារម្មណ៍តានតឹងកាលពីសប្ដាហ៍មុន។
- ប្រើប្រាស់តារាងខាងក្រោមដើម្បីបំពេញទិន្នន័យដែលសមស្រប។
- សម្រាប់ការណែនាំ សូមមើល «ផ្នែកជំនួយ» ដែលបានផ្ដល់ជូនខាងក្រោម។

| | កូឡោនទី ១<br>កាលបរិច្ឆេទ និងពេលវេលា | កូឡោនទី ២<br>ហេតុការណ៍<br>នរណា-ជាអ្វី-ឯណា? | កូឡោនទី ៣<br>កម្រិតនៃអារម្មណ៍តានតឹង<br>ទាប-មធ្យម-ខ្ពស់ | កូឡោនទី ៤<br>ប្រតិកម្មរបស់ខ្ញុំ | កូឡោនទី ៥<br>ការគ្រប់គ្រងអារម្មណ៍តានតឹង<br>វិធីសាស្ត្រដែលខ្ញុំអាចគ្រប់គ្រងអារម្មណ៍តានតឹងរបស់ខ្ញុំ |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |

| ផ្នែកជំនួយ ៖ រៀបបំពេញទិន្នន័យត្រឹមត្រូវចូលក្នុងតារាងខាងលើ។ | | | | |
|---|---|---|---|---|
| **កូឡោនទី ១** | **កូឡោនទី ២** | **កូឡោនទី ៣** | **កូឡោនទី ៤** | **កូឡោនទី ៥** |
| សរសេរកាលបរិច្ឆេទ និងពេលវេលានៃហេតុការណ៍ដែលធ្វើឱ្យប្អូនមានអារម្មណ៍តានតឹង | បំពេញព័ត៌មានលម្អិតស្ដីពីហេតុការណ៍ដែលធ្វើឱ្យប្អូនមានអារម្មណ៍តានតឹង<br>- តើនរណាធ្វើឱ្យប្អូនមានអារម្មណ៍តានតឹង? (អ្នកពាក់ព័ន្ធ)<br>- តើអ្វីដែលធ្វើឱ្យប្អូនមានអារម្មណ៍តានតឹង<br>- តើអារម្មណ៍តានតឹងនោះកើតឡើង នៅកន្លែងណា? | បង្ហាញពីកម្រិតនៃអារម្មណ៍តានតឹងដែលប្អូនមាន។<br>ចូរសរសេរថាទាប មធ្យម ឬខ្ពស់ដោយប្រៀបធៀបជាមួយហេតុការណ៍នីមួយៗ។ | តើប្អូនមានអារម្មណ៍ និងប្រតិកម្មបែបណាចំពោះអារម្មណ៍តានតឹងដែលកើតមានក្នុងព្រឹត្តិការណ៍នោះ? | លើកឡើងពីវិធីសាស្ត្រដែលប្អូនត្រូវគ្រប់គ្រង អារម្មណ៍តានតឹងនេះ។ តើប្អូនត្រូវធ្វើអ្វីខ្លះ? |

# ឧបសម្ព័ន្ធទី២

## ទម្រង់វាយតម្លៃសិស្ស

ពិន្ទុសរុប
........../៣០

# កម្រងសំណួរការធ្វើតេស្តចំណេះដឹងសិស្ស
# សម្រាប់ក្មេងស្រី ពេញវ័យ (ម៉ូឌុល ៣)

វិទ្យាល័យ/អនុវិទ្យាល័យ..............................ខេត្ត/ក្រុង....................ស្រុក/ខណ្ឌ....................ឃុំ/សង្កាត់..................
ឈ្មោះគ្រូបង្រៀន................................ភេទ..............ឈ្មោះសិស្ស..................................ភេទ............ថ្នាក់ទី................
កាលបរិច្ឆេទការធ្វើតេស្តៈ ថ្ងៃទី................ខែ.........................ឆ្នាំ.................

| **ខ្លឹមសារ** | **ពិពណ៌នាសកម្មភាព** | **ឥស្សេងៗ** |
|---|---|---|
| | **ម៉ូឌុលទី៣**: *សមត្ថភាពធ្វើការសម្រេចចិត្ត* | |
| **ជំពូកទី១៖ យេនឌ័រ និងបំណងប្រាថ្នា** | | |
| ១.១. យេនឌ័រក្នុងការងារមានន័យដូចម្តេច?<br>លទ្ធផល<br>☐ | ☐ក. គឺជាការបង្ហាញពីប្រភេទការងារដែលបុរស និងស្ត្រីមិនអាចធ្វើជាមួយគ្នាបាន។ | |
| | ☐ខ. គឺជាការយល់ច្បាស់ពីប្រភេទការងាររបស់បុរស និងស្ត្រី។ | |
| | ☐គ. គឺជាដំណើរការដែលបុរស និងស្ត្រីមានសិទ្ធធ្វើការដូចគ្នា និងមានការសម្រេចចិត្តដោយមិនគិតពី តួនាទី ឬ ភេទឡើយ។ | |
| | ☐ឃ. គឺជាដំណើរការដែលបុរស និងស្ត្រីធ្វើការជាមួយគ្នា តែបុរសជាអ្នកគ្រប់គ្រង និងធ្វើការសម្រេចចិត្ត។ | |
| | ☐ង. មិនច្បាស់។ | |
| ១.២. នៅពេលដែលស្ត្រីម្នាក់មានការងារល្អមួយធ្វើ តើស្ត្រីនោះនិងមានការប្រែប្រួលយ៉ាងដូចម្តេច?<br>លទ្ធផល<br>☐ | ☐ក. ធ្វើឱ្យស្ត្រីនោះមានគេស្គាល់ និងរាប់អានច្រើនជាងមុន។<br>☐ខ. ធ្វើឱ្យស្ត្រីមានលុយចាយច្រើនជាងមុន។<br>☐គ. ធ្វើឱ្យស្ត្រីនោះមានទំនួលខុសត្រូវខ្ពស់ជាងមុនលើផ្នែកសេដ្ឋកិច្ចនៅក្នុងគ្រួសារ។<br>☐ឃ. ធ្វើឱ្យស្ត្រីមានភាពជឿជាក់ និងម្ចាស់ការលើខ្លួនឯង មានសិទ្ធទទួលបានអំណាច និងធនធានកាន់តែប្រសើរ និងបង្កើនសិទ្ធក្នុងការសម្រេចចិត្តនៅកម្រិតគ្រួសារ។<br>☐ង. មិនច្បាស់។ | |

| | | |
|---|---|---|
| **ជំពូកទី២៖ ការរៀបចំសេចក្ដីចង់បាន និងការកំណត់គោលដៅ** | | |
| ២.១. គោលដៅ និងការកំណត់គោលដៅមានសារៈសំខាន់ដូចម្ដេច? លទ្ធផល ☐ | ☐ក. មានសារៈសំខាន់ខ្លាំងសម្រាប់មនុស្សគ្រប់រូប។ | |
| | ☐ខ. មិនសូវសំខាន់ឡើយ។ | |
| | ☐គ. ធ្វើឱ្យមនុស្សមានទិសដៅជីវិតច្បាស់លាស់ និងចេះរៀបចំផែនការដើម្បីសម្រេចគោលដៅរបស់ខ្លួនដែលបានកំណត់។ | |
| | ☐ឃ. ធ្វើឱ្យមនុស្សដឹងពីទិសដៅដែលត្រូវទៅ និងសម្រេចឱ្យបាន។ | |
| | ☐ង. មិនច្បាស់។ | |
| **ជំពូកទី៣៖ ជំនាញដែលអ្នកចង់បាន** | | |
| ៣.១. តើការសម្រេចចិត្តមានន័យដូចម្ដេច? លទ្ធផល ☐ | ☐ក. គឺការធ្វើការជ្រើសរើសរវាងជម្រើសច្រើន ដោយធ្វើការពិចារណាតិចតួច។ | |
| | ☐ខ. គឺការធ្វើការជ្រើសរើសរវាងជម្រើសច្រើន ដោយឆ្លងកាត់ការពិចារណាយ៉ាងហ្មត់ចត់មុននិងសម្រេចចិត្ត។ | |
| | ☐គ. ជាការចង់បានរបស់អ្វីមួយ។ | |
| | ☐ឃ. គឺការធ្វើការជ្រើសរើសរវាងជម្រើសច្រើន។ | |
| | ☐ង. មិនច្បាស់។ | |
| ៣.២. តើធ្វើដូចម្ដេចដើម្បីគ្រប់គ្រងពេលវេលាឱ្យមានប្រសិទ្ធភាព? លទ្ធផល ☐ | ☐ក. គោរពពេលវេលាក្នុងការសិក្សា។ | |
| | ☐ខ. កំណត់ពេលវេលាឱ្យបានច្បាស់លាស់ក្នុងការធ្វើអ្វីមួយ។ | |
| | ☐គ. ត្រូវរៀបចំផែនការពេលវេលា និងអនុវត្តផែនការ។ | |
| | ☐ឃ. ត្រូវធ្វើផែនការ និងបែងចែកឱ្យដាច់រវាងកិច្ចការបន្ទាន់ និងកិច្ចការសំខាន់ និងកំណត់នូវកិច្ចការអាទិភាពផងដែរ។ | |
| | ☐ង. មិនច្បាស់។ | |

| | | |
|---|---|---|
| **៣.៣. នរណាជាអ្នកដឹកនាំ?**<br><br>**លទ្ធផល**<br>☐ | ☐ក. គឺជាមនុស្សដែលមានមុខមាត់ស្អាត និងរាងកាយមាំមួន។ | |
| | ☐ខ. គឺជាមនុស្សដែលមានទ្រព្យច្រើន និងរាងកាយមាំមួន។ | |
| | ☐គ. គឺជាមនុស្សដែលមានទ្រព្យសម្បត្តិច្រើន។ | |
| | ☐ឃ. មនុស្សគ្រប់រូបគឺជាអ្នកដឹកនាំ។ | |
| | ☐ង. មិនច្បាស់។ | |